ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការយល់ដឹងពីការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន នៅខេត្តស្ទឹងត្រែង៖ ករណីសិក្សាមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង

# An Understanding of Lesson Study Implementation in Stung Treng៖ Case Study of Stung Treng Regional Teacher Training Center

ដោយ / By

**សឺុយ វង្សស៊ី**

**SEUY VONGSY**

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៧-២០១៩

ឧបត្ថមដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation ( CIESF )

ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

## និក្ខេបបទ

# ការយល់ដឹងពីការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន នៅខេត្តស្ទឹងត្រែង៖ ករណីសិក្សាមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង

# An Understanding of Lesson Study Implementation in Stung Treng៖ Case Study of Stung Treng Regional Teacher Training Center

ដោយ / By
**ស៊ើយ វង្សស៊ី**
**SEUY VONGSY**

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦
ឯកទេស៖ គ្រប់គ្រងអប់រំ
ឆ្នាំសិក្សា ២០១៧-២០១៩

សាស្ត្រាចារ្យដឹកនាំ៖ លោកបណ្ឌិត សិត សេង
សាស្ត្រាចារ្យដឹកនាំរង៖ លោកស្រី ប៊ុន សុផានី

ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា
Supported by Cambodia International Education Support Foundation ( CIESF )

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ៩៧២៩ អយក. ១៥

(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ រីក៉ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យូន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈូក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។ ៤

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# **សេចក្តីប្រកាសអះអាងរបស់បេក្ខជន**

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា “**ការយល់ដឹងពីការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅខេត្តស្ទឹងត្រែងៈករណីសិក្សានៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង**” សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង ។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ សាកលវិទ្យាល័យណា ឬ វិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់នៅក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះ ពិតជាស្រាវជ្រាវដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន ។

ថ្ងៃ អង្គារ ១៤ កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០១៩

**ហត្ថលេខាបេក្ខជន**

**ស៊ើយ ចន្ទស៊ី**

# លិខិតបញ្ជាក់

**លោកបណ្ឌិត សិត សេង** ជាសាស្ត្រាចារ្យដឹកនាំ

**លោកស្រី ប៊ុន សុផានី** ជាសាស្ត្រាចារ្យដឹកនាំរង

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

**លោក ស៊ើយ ចន្ទស៊ី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ការយល់ដឹងពីការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅខេត្តស្ទឹងត្រែង៖ ករណីសិក្សានៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង**" ពិតប្រាកដមែន។

ថ្ងៃ អង្គារ ១៤ កើត ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០១៩

.......................................

**បណ្ឌិត សិត សេង**
នាយកវិទ្យាស្ថានគរុកោសល្យ
រាជធានីភ្នំពេញ

.......................................

**លោកស្រី ប៊ុន សុផានី**
នាយិការងវិទ្យាស្ថានជាតិអប់រំ

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងធំធេងចំពោះក្រសួងអប់រំ យុវជន និងកីឡា និងវិទ្យាស្ថានជាតិអប់រំ ព្រមទាំងអង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា (Cambodia International Education Support Foundation (CIESF) ដែលបានរៀបចំឱ្យមានកម្មវិធីអាហារូបករណ៍នេះឡើង ដែលជាឱកាសល្អមួយសម្រាប់ខ្ញុំបាទបានមកចូលរួមសិក្សានៅក្នុងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអប់រំ និងផែនការអប់រំនេះ ក្នុងការពង្រឹង និងពង្រីកចំណេះដឹងបន្ថែម ដើម្បីបានរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិ។

សូមថ្លែងអំណរគុណជាអតិបរិមាចំពោះឯកឧត្តម លោក លោកស្រី ជាសាស្ត្រាចារ្យទាំងអស់ ដែលបានលះបង់ពេលវេលាដ៏មានតម្លៃរបស់លោកក្នុងការចែករំលែកនូវចំណេះដឹង និងបទពិសោធដែលមិនអាចកាត់ថ្លៃបាន ដល់ខ្ញុំបាទយើងខ្ញុំទាំងអស់គ្នា។ ជាងនេះទៅទៀត ខ្ញុំបាទសូមថ្លែងអំណរគុណជាពិសេសចំពោះ លោកសាស្ត្រាចារ្យបណ្ឌិត **សិត សេង** ដែលជាគ្រូដឹកនាំ និងលោកស្រី **ប៊ុន សុជានី** គ្រូដឹកនាំរង ដោយលោកទាំងពីរបានលះបង់ពេលវេលាដ៏មានតម្លៃ ក្នុងការជួយណែនាំបង្ហាញផ្លូវឆ្ពោះទៅដល់គោលដៅ។ សូមអរគុណដល់មិត្តភ័ក្តិទាំងអស់ដែលតែងតែជួយពន្យល់ណែនាំ និងចែករំលែកនូវបទពិសោធល្អៗ ទាំងពេលកំពុងសិក្សា និងពេលកំពុងស្រាវជ្រាវ ។

សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់អ្នកម្តាយ និងលោកឪពុកដ៏មានគុណ ដែលបានចែកឋានទៅលោកខាងមុខ ដែលលោកតែងតែស្ថិតនៅក្នុងចិត្តកូនចាំជួយជំរុញលើកទឹកចិត្តគ្រប់ពេលវេលា ។ សូមអរគុណដល់ភរិយា និងប្អូនៗប្រុសស្រី ក្មួយប្រុសស្រីទាំងអស់ ដែលតែងតែជាកម្លាំងចិត្ត គាំទ្រ និងផ្តល់ជាកម្លាំងចិត្តគ្រប់ពេលវេលារហូតទទួលបានជោគជ័យដូចថ្ងៃនេះ។

សូមថ្លែងអំណរគុណដល់លោក លោកស្រីជានាយករង មន្ត្រី និងគ្រូឧទ្ទេសនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង ដែលបានបង្កលក្ខណៈងាយស្រួល និងបានចំណាយពេលវេលាដ៏មានតម្លៃរបស់ខ្លួន ក្នុងការបំពេញកម្រងសំណួរដែលទាក់ទងទៅនឹងប្រធានបទស្រាវជ្រាវមួយនេះ ឱ្យសម្រេចបានទៅតាមការគ្រោងទុក។

ខ្ញុំសូមប្រសិទ្ធិពរដ៏បវរមហាប្រសើរ ជូនចំពោះ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ទទួលបាននូវសុខភាពល្អបរិបូរណ៍ សុភមង្គល និងជោគជ័យគ្រប់ភារកិច្ច ព្រមទាំងទទួល បាននូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ!**

# មូលន័យសង្ខេប

ការសិក្សាលើប្រធានបទស្តីពី *"ការយល់ដឹងពីការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅខេត្តស្ទឹងត្រែង៖ ករណីសិក្សាមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង"* នាពេលនេះ ធ្វើឡើងស្របពេលជាមួយនឹងកំណែទម្រង់វិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានលើកឡើងពីការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន។ ការសិក្សាស្រាវជ្រាវនេះមានគោលបំណង ១. ស្វែងយល់ពីការយល់ដឹង និងបញ្ហាប្រឈមនៃការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង ២. ស្វែងយល់ពីទស្សនៈយល់ឃើញជារួមរបស់គ្រូទៅលើការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន។ ការស្រាវជ្រាវនេះត្រូវបានធ្វើឡើងតាមបែបគុណវិស័យផង និងតាមបែបបរិមាណវិស័យផង។ ភាគសំណាកក្នុងការស្រាវជ្រាវគឺគ្រូឧទ្ទេស គ្រូឧទ្ទេសបង្គោល នាយករង និង តំណាងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដោយប្រើកម្រងសំណួរជាឧបករណ៍ស្រាវជ្រាវឲ្យសំណាកបំពេញ។ ជាលទ្ធផល គ្រូភាគច្រើនបាន យល់ដឹងច្បាស់ និងអនុវត្តបានល្អលើការរៀបចំផែនការមេរៀន (Plan)។ ការរអនុវត្តការបង្រៀន និងការសង្កេត (Do) ការពិភាក្សាការបង្រៀន និងរៀន (Check) និងការធ្វើសកម្មភាពកែលម្អបន្ត (Action) នៃដំណើរការសិក្សាមេរៀន។ ទាំងនេះបានឆ្លុះបញ្ចាំងឲ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការលើកកម្ពស់គុណភាពបង្រៀនរបស់ពួកគាត់។ តែទោះបីជាយ៉ាងណាក៏ដោយក៏នៅមានបញ្ហាប្រឈមខ្លះកើតឡើង ដែលមានជាអាទិ៍ គ្រូមួយចំនួនតូចចូលរួមសិក្សាមេរៀនមិនបានទៀងទាត់ ការគាំទ្រថវិកា និងសម្ភារៈលើការអនុវត្តការសិក្សាមេរៀននៅមានកំណត់នៅឡើយ។ តែទោះបីជាយ៉ាងនេះក្តី គ្រូឧទ្ទេសនៅមានទស្សនៈយល់ឃើញជារួមថា ការអនុវត្តការសិក្សាមេរៀនគឺពិតជាបានជួយអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនរបស់ពួកគាត់ បានជួយបង្កើនទំនាក់ទំនង និងសាមគ្គីភាពផ្ទៃក្នុងល្អ ហើយលទ្ធផលសិក្សារបស់គរុសិស្សបានល្អជាងមុន។ ជាសេចក្តីសន្និដ្ឋាន ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង ពិតជាចំណែកមួយល្អក្នុងការចូលរួមអភិវឌ្ឍការបង្រៀនរបស់គ្រូឧទ្ទេស និងការរៀនរបស់គរុសិស្ស។ កម្មវិធីនេះពិតជាបានរួមចំណែកដល់ការអនុវត្តគោលនយោបាយអប់រំ និងកំណែទម្រង់វិស័យអប់រំនៅកម្ពុជា។

# Abstract

The study on an understanding of lesson study Implementation in Stung Treng province៖ case study of Stung Treng Regional Teacher Training Center at the present time is going with the educational reform of Ministry of Education Youth and Sport on advancing teacher qualifications. This study aims at 1) learning about understandings and challenges of lesson study implementation. 2) Learning about general perspectives of teacher trainers at Stung Treng Regional Teacher Training Center. The study uses both, quantitative and qualitative research. The samples in this research are teacher trainers, senor trainers, vice directors. As results, most teacher trainers have good understanding and practicing on lesson plan (Plan), teaching practice and observation (Do), discussing after teaching and learning (Check), and action to improve their own individual lessons (Action). These are reflecting on their efforts in order to promote their teaching qualifications. Even though, there are some challenges. A few teacher trainers who are participants still absent during the lesson study meeting. Budget and materials supports are limited and also technical support. However, teacher trainers have positive perspectives that lesson study implementation really helps developing their teaching capacity, have good relationship and harmony among participants and teacher trainees' output is better. Conclusion, lesson study at Stung Teng Regional Teacher Training Center is a good part in developing teacher's teaching profession and student learning. This practice is really a part of educational policy implementing and educational reform in Cambodia.

# មាតិកា


| | ទំព័រ |
|---|---|
| សេចក្តីប្រកាសអះអាងរបស់បេក្ខជន | i |
| លិខិតបញ្ជាក់ | ii |
| សេចក្តីថ្លែងអំណរគុណ | iii |
| មូលន័យសង្ខេប | iv |
| Abstract | v |
| មាតិកា | vi |
| បញ្ជីតារាង រូបភាព និងក្រាប | ix |
| ជំពូកទី១ | ១ |
| សេចក្តីផ្តើម | ២ |
| ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ | ២ |
| ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ | ៤ |
| ១.៣ គោលបំណងនៃការស្រាវជ្រាវ | ៦ |
| ១.៤ សំណួរស្រាវជ្រាវ | ៦ |
| ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ | ៧ |
| ១.៦ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ | ៧ |
| ១.៧ រចនាសម្ព័ន្ធស្រាវជ្រាវ | ៨ |
| ជំពូកទី២ | ៩ |
| រំឭកទ្រឹស្តី | ១០ |
| ២.១. និយមន័យនិងពន្យល់ពាក្យគន្លឹះ | ១០ |
| ២.២. ប្រវត្តិនៃកាសិក្សាស្រាវជ្រាវមេរៀន | ១៤ |
| ២.៣. ការសិក្សាស្រាវជ្រាវមេរៀននៅកម្ពុជា | ១៦ |
| ជំពូកទី៣ | ៣១ |
| វិធីសាស្រ្តស្រាវជ្រាវ | ៣២ |
| ៣.១. វិធីសាស្រ្តនៃការស្រាវជ្រាវ | ៣២ |
| ៣.២. ការជ្រើសរើសភាគសំណាក | ៣២ |
| ៣.៣. ឧបករណ៍ស្រាវជ្រាវ | ៣៣ |

៣.៤. ការប្រមូលទិន្នន័យ ៣៤
៣.៥. ការវិភាគទិន្នន័យ ៣៥
ជំពូកទី៤ ៣៧
លទ្ធផល និងការពិភាក្សា ៣៨
៤.១. ស្ថានភាពទូទៅនៃការសិក្សាមេរៀន ៣៨
៤.១.១. អំពីការចូលរួមវគ្គបំប៉ន ៣៨
៤.១.២. ការយល់ដឹងជារួមលើខ្លឹសារ ៤១
៤.២. ការរៀបចំផែនការមេរៀន (Plan) ៤២
៤.២.១. ការយល់ដឹងលើការរៀបចំមេរៀន ៤២
៤.២.២. ការអនុវត្តលើការរៀបចំមេរៀន ៤៦
៤.២.១. បញ្ហាប្រឈមលើការរៀបចំមេរៀន ៥២
៤.៣. ការអនុវត្តការបង្រៀន និងការសង្កេត (Do) ៥៣
៤.៣.១. ការយល់ដឹងលើការបង្រៀន និងការសង្កេត ៥៣
៤.៣.២. ការអនុវត្តលើការបង្រៀន និងការសង្កេត ៥៤
៤.៣.៣. បញ្ហាប្រឈម ៥៥
៤.៤. ការពិភាក្សាលើការបង្រៀន និងរៀន (Check) ៥៦
៤.៤.១. ការយល់ដឹងលើការពិភាក្សាការបង្រៀន និងរៀន ៥៦
៤.៤.២. ការអនុវត្តលើការពិភាក្សាការបង្រៀន និងរៀន ៥៧
៤.៤.៣. បញ្ហាប្រឈម ៦១
៤.៥. ការធ្វើសកម្មភាពកែលម្អបន្ត (Action) ៦២
៤.៥.១. ការយល់ដឹងលើការកែលម្អបន្ត ៦២
៤.៥.២. ការអនុវត្តលើសកម្មភាពកែលម្អបន្ត ៦៣
៤.៥.៣. បញ្ហាប្រឈម ៦៥
៤.៦. លទ្ធផលសិក្សារបស់សិស្ស ៦៥
៤.៦.១. លទ្ធផលកម្មសិក្សាគរុកោសល្យ ៦៥
៤.៦.២. លទ្ធផលសិក្សាប្រចាំឆ្នាំ ៦៧
៤.៧. ទស្សនៈយល់ឃើញជារួម ៦៩
ជំពូកទី៥ ៧៨
សេចក្ដីសន្និដ្ឋាន និងសំណូមពរ ៧៩

៥.១. សេចក្តីសន្និដ្ឋាន................................................ ៧៩
៥.២. សំណូមពរ................................................ ៨១
ឯកសារយោង................................................ ៨៥
ឧបសម្ព័ន្ធ................................................ ៨៧
ឧបសម្ព័ន្ធទី១៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា........................ ៨៨
ឧបសម្ព័ន្ធទី២៖ លិខិតឧទ្ទេសនាមចុះប្រមូលទិន្នន័យ................................ ៨៩
ឧបសម្ព័ន្ធទី៣៖ កម្រងសំណួរ................................................ ៩០
ឧបសម្ព័ន្ធទី៤៖ ................................................ ៩៨
១. គណៈកម្មការមេប្រយោគ................................................ ៩៨
២. គណៈកម្មការការពារនិក្ខេបបទ................................................ ៩៩
៣. គណៈកម្មការកណ្តាល................................................ ១០០

# បញ្ជីតារាង រូបភាព និងក្រាប


| ល.រ | ចំណងជើងតារាង | ទំព័រ |
|---|---|---|
| 1 | ភាពខុសគ្នារវាងការសិក្សាមេរៀន និងការអភិវឌ្ឍវិជ្ជាជីវៈពីមុន | ១៣ |
| 2 | សមាសភាពក្រុមសិក្សាស្រាវជ្រាវមេរៀន | ១៨ |
| 3 | ភារកិច្ច និងដំណើរការនៅក្នុងដំណាក់កាលរៀបចំមេរៀន | ១៩ |
| 4 | ដំណើរការនៃការពិភាក្សាលើការបង្រៀន និងរៀន | ២៣ |
| 5 | ប្រភេទនៃអនុសាសន៍ដែលបានផ្តល់ក្នុងការពិភាក្សាក្រោយពីការបង្រៀនចប់ | ២៦ |
| 6 | ឧទាហរណ៍ការរៀបចំកាលវិភាគសម្រាប់ការសិក្សាស្រាវជ្រាវមេរៀន | ២៨ |
| | **ចំណងជើងរូបភាព** | |
| 1 | គំនូសបង្ហាញពីការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន | ១១ |
| 2 | គំនូសបង្ហាញពីវដ្តនៃការសិក្សាស្រាវជ្រាវមេរៀន | ១២ |
| 3 | វដ្តនៃការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន | ១៧ |
| 4 | អ្នកសង្កេតការបង្រៀនពីមុន និងអ្នកសង្កេតការបង្រៀនបែបគោលវិធីសិស្សមជ្ឈមណ្ឌល | ២១ |
| 5 | ឧបករណ៍សង្កេតការបង្រៀន និងរៀន | ២២ |
| 6 | គំនូសតាងលំនាំគំរូសម្របសម្រួលការខ្វែងគំនិតដែលមានប្រសិទ្ធភាព | ២៧ |
| | **ចំណងជើងក្រាប** | |
| 1 | ការចូលរួមវគ្គបំប៉នការសិក្សាស្រាវជ្រាវមេរៀនរបស់គ្រូ | ៣៩ |
| 2 | កម្រិតយល់ដឹងលើខ្លឹមសារការសិក្សាមេរៀន | ៤១ |
| 3 | កម្រិតយល់ដឹងលើការចាត់តាំងគ្រូបង្រៀន | ៤២ |
| 4 | ការយល់ដឹងរបស់គ្រូលើការរៀបចំក្រុមសិក្សាមេរៀន | ៤៣ |
| 5 | ការយល់ដឹងរបស់គ្រូលើការរៀបចំកិច្ចតែងការបង្រៀន | ៤៤ |
| 6 | ការយល់ដឹងរបស់គ្រូលើការពិភាក្សាកិច្ចតែងការបង្រៀន | ៤៥ |
| 7 | ការយល់ដឹងរបស់គ្រូលើការសរសេរកិច្ចតែងការសម្រេច | ៤៥ |
| 8 | ការអនុវត្តការរៀបចំក្រុមសិក្សាមេរៀន | ៤៦ |
| 9 | ការអនុវត្តការពិភាក្សាលើកិច្ចតែងការបង្រៀន | ៤៨ |
| 10 | កម្រិតនៃការចូលរួមជាបុគ្គល | ៤៩ |

| | | |
|---|---|---|
| 11 | ការចូលរួមរបស់ក្រុមសិក្សាមេរៀន | ៥០ |
| 12 | ការអនុវត្តបង្រៀនសាកល្បងក្នុងក្រុម | ៥១ |
| 13 | ការយល់ដឹងរបស់គ្រូលើការបង្រៀន និងការសង្កេត | ៥៤ |
| 14 | ការអនុវត្តការបង្រៀន និងសង្កេត | ៥៥ |
| 15 | ការយល់ដឹងលើការពិភាក្សាការបង្រៀន និងរៀន | ៥៧ |
| 16 | ការពេញចិត្តលើការដឹកនាំរបស់គ្រូឧទ្ទេសបង្គោល | ៥៨ |
| 17 | ការពេញចិត្តចំពោះអ្នកសម្របសម្រួល | ៥៩ |
| 18 | ការអនុវត្តការពិភាក្សាលើការបង្រៀន និងរៀន | ៦០ |
| 19 | ការយល់ដឹងរបស់គ្រូលើសកម្មភាពកែលម្អបន្ត | ៦២ |
| 20 | ការអនុវត្តសកម្មភាពកែលម្អបន្តរបស់គ្រូ | ៦៣ |
| 21 | ការគាំទ្រពីគណៈគ្រប់គ្រងសាលា | ៦៤ |
| 22 | លទ្ធផលកម្មសិក្សារបស់គរុសិស្សជំនាន់ទី៣៦ | ៦៦ |
| 23 | លទ្ធផលកម្មសិក្សាគរុសិស្សជំនាន់ទី៣៦ និង៣៧ | ៦៧ |
| 24 | លទ្ធផលសិក្សារបស់គរុសិស្សជំនាន់ទី៣៦ | ៦៨ |
| 25 | លទ្ធផលសិក្សារបស់គរុសិស្សជំនាន់ទី៣៦ និង៣៧ | ៦៨ |

# ជំពូកទី ១
# សេចក្តីផ្តើម

# ជំពូកទី១
## សេចក្តីផ្តើម

### ១.១- លំនាំបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យ ប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០។ ដើម្បីសម្រេចចក្ខុវិស័យនេះ ការកសាងធនធានមនុស្សឲ្យមានសមត្ថភាពខ្ពស់គឺជាគន្លឹះមួយយ៉ាងសំខាន់បំផុត សម្រាប់ឆ្លើយតបទៅនឹងបរិបទសកលភាវូបនីយកម្ម សមាហរណកម្មក្នុងតំបន់ និងធានាបានការប្រកួតប្រជែងក្នុងទីផ្សារពលកម្មបើកចំហរ។ ប្រការនេះតម្រូវឲ្យក្រសួងអប់រំ យុវជន និងកីឡាបំពេញតួនាទីចម្បងក្នុងការកសាងនិងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ ដែលជាធាតុយ៉ាងសំខាន់លើគ្រប់វិស័យដើម្បីកសាងសង្គមកម្ពុជាឲ្យក្លាយជាសង្គមរីកចម្រើនដោយផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន (ក្រសួង អយក,២០១៦)។ ម្យ៉ាងវិញទៀត ដោយសារសង្គមជាតិមានការអភិវឌ្ឍរីកចម្រើនឥតឈប់ឥតឈរ ទើបធ្វើឲ្យវិស័យអប់រំបានដើរតួនាទីយ៉ាងសំខាន់ និងត្រូវបានយកចិត្តទុកដាក់កែលម្អទាំងផ្នែកបរិមាណ និងគុណភាពឲ្យបានល្អប្រសើរ។ ដើម្បីធានាឲ្យកិច្ចការនេះទទួលបានជោគជ័យ រាជរដ្ឋាភិបាលបានចាត់ទុកគុណភាពអប់រំនៅគ្រប់កម្រិតសិក្សាទាំងអស់ជាចំណុចអាទិភាពក្នុងការអភិវឌ្ឍប្រទេសជាតិ ដែលតម្រូវឲ្យអ្នកពាក់ព័ន្ធទាំងអស់មានការឯកភាពលើការពង្រឹងលទ្ធផលសិក្សារបស់សិស្ស (ក្រសួង អយក,២០១៣)។ រាជរដ្ឋាភិបាលកម្ពុជា (២០១៩) បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត ដោយបានបញ្ជាក់ថាការសិក្សាពេញមួយជីវិតជាដំណើរការរៀនសូត្រទាំងនៅក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និង មិនផ្លូវការចាប់តាំងពីកំណើតរហូតដល់ជរា ដើម្បីអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងគុណសម្បទា ឲ្យក្លាយជាពលរដ្ឋល្អចេះរួមរស់ដោយក្តីសុខដុមនៅក្នុងសង្គម និងដើម្បីឆ្លើយតបនឹងទីផ្សារការងារក្នុងបរិបទថ្មី។

គុណភាពអប់រំជាកត្តាដ៏សំខាន់មួយក្នុងការអភិវឌ្ឍធនធានមនុស្ស ដែលទាមទារឲ្យក្រសួងអប់រំយុវជន និងកីឡាត្រូវមានការត្រួតពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំដោយផ្អែកលើច្បាប់ គោលនយោបាយ សេចក្តីណែនាំ និងគោលការណ៍នានាដើម្បីឲ្យសម្រេចតាមយុទ្ធសាស្ត្រវិស័យអប់រំ និងវិធានការកំណែទម្រង់វិស័យអប់រំ (ក្រសួង អយក,២០១៥)។ បន្ថែមលើនេះ ការងារអធិការកិច្ចពិតជាមានតួនាទីយ៉ាងសំខាន់ណាស់

ក្នុងការពង្រឹងគុណភាពអប់រំ ជាពិសេសវាបានជំរុញបុគ្គល និងអង្គភាពនីមួយៗបំពេញការងារប្រកបដោយប្រសិទ្ធភាព និងមានទំនួលខុសត្រូវខ្ពស់ (ក្រសួង អយក, ២០០៨)។ គុណភាពអប់រំត្រូវផ្សាភ្ជាប់នឹងមជ្ឈដ្ឋានបីសំខាន់ គឺគោលនយោបាយ សាលារៀន និងគ្រួសារសហគម។ ការអប់រំប្រកបដោយគុណភាព ត្រូវធានាការចូលរួមសម្រេចលទ្ធផលសិក្សារបស់សិស្សទាំងអស់គ្នា ត្រូវមានភាពពាក់ព័ន្ធនឹងបរិបទសេដ្ឋកិច្ចសង្គម និងតម្រូវការអភិវឌ្ឍរបស់បុគ្គលដែលស្របគ្នាជាមួយនិងដំណើរអភិវឌ្ឍរបស់សង្គម និងត្រូវមានគណនេយ្យភាព (Angeline & Leon , ២០១២)។ ម្យ៉ាងទៀត បើនិយាយពីគុណភាពអប់រំក៏ត្រូវនិយាយផងដែរពីសុខភាព ការហូបចុក ការចូលរួមរៀនសូត្ររបស់សិស្ស ការគាំទ្រពីគ្រួសារ និងសហគម មានបរិយាកាសរៀនសូត្រល្អ សុវត្ថិភាព មានការការពារ និងមានការផ្តល់នូវធនធានសិក្សាគ្រប់គ្រាន់។ លើសពីនេះទៅទៀត ខ្លឹមសារសិក្សាត្រូវឆ្លុះបញ្ចាំងនូវភាពទាក់ទងគ្នារវាងកម្មវិធីសិក្សា សម្ភារៈសិក្សា និងជំនាញមូលដ្ឋានរបស់ពួកគេ។ ក្នុងដំណើរការបង្រៀន គ្រូត្រូវប្រើវិធីសាស្រ្តបង្រៀនតាមបែបគោលវិធីសិស្សមជ្ឈ-មណ្ឌល ដោយមានការគ្រប់គ្រងថ្នាក់រៀនយ៉ាងល្អ និងការវាយតម្លៃសាលារៀនប្រកបដោយជំនាញ ដើម្បីសម្រួលដល់ការរៀន និងកាត់បន្ថយនូវភាពមិនស៊ីគ្នា។ លទ្ធផលសម្រេចបានដែលរួមមានចំណេះដឹង បំណិន និងឥរិយាបទនឹងត្រូវផ្សាភ្ជាប់ទៅនឹងគោលដៅអប់រំជាតិ និងការចូលរួមជាវិជ្ជាមានក្នុងសង្គម (UNICEF, 2000)។ ជាមួយគ្នានេះ គុណភាពអប់រំបានមកពីលក្ខណៈច្រើនយ៉ាង ដូចជាគុណភាពសិស្ស គុណភាពបរិស្ថានសិក្សា មានជាអាទិ៍ កត្តារូបរាង កត្តាចិត្តសង្គម ភាពអហិង្សា ការផ្តល់សេវាកម្មគុណភាពខ្លឹមសារនៃកម្មវិធីសិក្សា គុណភាពនៃដំណើរការបង្រៀន លក្ខខណ្ឌធ្វើការងាររបស់គ្រូបង្រៀន និងគុណភាពលទ្ធផលសិក្សា (S.G.N Eze, 2017)។

ជាការពិតណាស់ បើនិយាយពីគុណភាពអប់រំ ក៏ត្រូវនិយាយផងដែរពីគុណភាពគ្រូបង្រៀន ដូចបានលើកឡើងនៅក្នុងកំណែទម្រង់វិស័យអប់រំ។ គ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់ ជាគន្លឹះក្នុងការជួយសិស្សឲ្យសម្រេចបានលទ្ធផលល្អប្រសើរក្នុងការសិក្សា។ បច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡាកំពុងយកចិត្តទុកដាក់រៀបចំឯកសារគតិយុត្ត ការជ្រើសរើស ការបណ្តុះបណ្តាល ការគាំទ្រគ្រប់ផ្នែក និងបង្កើតយន្តការទាក់ទាញអ្នកដែលមានសមត្ថភាពខ្ពស់ឲ្យចូលបម្រើការក្នុងវិជ្ជាជីវៈគ្រូបង្រៀន។ ការបណ្តុះបណ្តាលគ្រូបង្រៀនដ៏មានប្រសិទ្ធភាពគឺជាគន្លឹះនៃកំណែទម្រង់ប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន(ក្រសួង អយក, ២០១៥)។ គុណភាពគ្រូបង្រៀនមានទំនាក់ទំនងយ៉ាងខ្លាំងនឹងលទ្ធផលសិក្សារបស់សិស្ស ដូចដែលអ្នកប្រាជ្ញមួយចំនួនបានលើកឡើងថា គ្រូបង្រៀន

ដែលមានចំណេះដឹងខ្លឹមសារគរុកោសល្យទាប ធ្វើឲ្យលទ្ធផលសម្រេចបានរបស់សិស្សទាបដែរ។ គុណភាពគ្រូបង្រៀនធ្វើឲ្យគ្រូខ្លួនឯងមានប្រសិទ្ធភាព និងភាពសក្តិសិទ្ធិក្នុងការបង្រៀន និងជាគុណភាពដែលមានឥទ្ធិពលលើលទ្ធផលសិក្សារបស់សិស្ស (Aina & Olanipekun, 2015)។ ដើម្បីឲ្យសិស្សបានរៀនសូត្រពូកែទាំងអស់គ្នា កាត់បន្ថយអត្រាបោះបង់ការសិក្សា កាត់បន្ថយអវត្តមាននិងកាត់បន្ថយអត្រាត្រួតថ្នាក់ គ្រូគប្បីចេះរៀបចំក្រុមសិស្សជួយសិស្ស ជំរុញលើកទឹកចិត្តសិស្សក្នុងការសិក្សា បិទតាំងស្នាដៃសិស្សក្នុងថ្នាក់ បង្កភាពស្និទ្ធស្នាលជាទីកក់ក្តៅរបស់សិស្ស រៀបចំបរិស្ថានថ្នាក់រៀន សាលារៀនល្អ និងឲ្យសិស្សឡើងបង្ហាញសមត្ថភាពក្នុងថ្នាក់ជាមួយសមូហភាពសិស្ស។ ការរៀបចំរបស់គ្រូទាំងនេះនឹងធ្វើឲ្យសិស្សជក់ចិត្តដាក់អារម្មណ៍ក្នុងការសិក្សា ដែលជាកត្តាសន្ទុះចិត្តនិងជាថាមពលជំរុញខាងក្នុងរបស់សិស្សឆ្ពោះទៅសម្រេចការសិក្សា ដោយឆ្លុះឲ្យឃើញតាមរយៈសមត្ថភាព និងគុណភាពគ្រូបង្រៀនជាកត្តាកំណត់ (លី ហាក់សេង, ២០១២)។

## ១.២- ចំណោទបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡា និងសាលារៀនក៏បានយកចិត្តទុកដាក់លើការធ្វើវិក្រឹតការគ្រូបង្រៀនដែរ។ ការធ្វើវិក្រឹតការគ្រូបង្រៀននៅនឹងកន្លែង តាមរយៈការប្រជុំបច្ចេកទេស ការប្រជុំគរុកោសល្យ វគ្គបំប៉នខ្លីៗជាដើម ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីលើកកម្ពស់ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនឲ្យកាន់តែប្រសើរឡើង ដែលប្រការនេះនឹងធ្វើឲ្យការបង្រៀនរបស់គ្រូ និងការរៀនរបស់សិស្សទទួលបានលទ្ធផលល្អ។ ក្រសួងអប់រំ យុវជន និងកីឡា, (១៩៩៦) បានចង្អុលបង្ហាញថា ការបំប៉នគ្រូជាការងារមួយដែលត្រូវយកចិត្តទុកដាក់បំផុត និងត្រូវរក្សាឲ្យបាននូវចរិតបី គឺទ្រឹស្តីផ្សាភ្ជាប់ទៅនឹងការប្រតិបត្តិជាក់ស្តែង សម្របទៅនឹងប្រព័ន្ធដែលត្រូវបំប៉ន និងមានលក្ខណៈវិទ្យាសាស្ត្រ ដែលត្រូវអនុវត្តតាមរយៈការធ្វើថ្នាក់និទស្សន៍ ដំបូន្មានគរុកោសល្យ ការបំប៉នពីចម្ងាយ និងការណែនាំគរុកោសល្យ ដើម្បីឲ្យការបំប៉នគ្រូទទួលបានជោគជ័យ ។ បន្ថែមពីលើនេះ ក្រសួងអប់រំក៏បានកសាងស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ស្តង់ដារសមត្ថភាពនាយកសាលារៀន ស្តង់ដារគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងផែនការគោលស្តីពីការអភិវឌ្ឍគ្រូបង្រៀនសម្រាប់ជាត្រីវិស័យចង្អុលប្រាប់អ្នកអប់រំ និងអ្នកពាក់ព័ន្ធទាំងអស់រៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន កម្មវិធីវិក្រឹតការនានា ដើម្បីកសាងសមត្ថភាពគ្រូបង្រៀន ឲ្យឆ្លើយតបទៅនឹងការរីកចម្រើននៃយុគសម័យបច្ចេកវិទ្យា និងការអភិវឌ្ឍសង្គមដោយផ្អែកលើពុទ្ធិ (ក្រសួង អយក, ២០១៣)។ ជាមួយការខិតខំប្រឹងប្រែងនេះ

ក្រសួងអប់រំបានបើកវគ្គបំប៉នជាច្រើនដល់គ្រូ ដូចជា ភាសាអង់គ្លេស ICT កម្មវិធីសាលាកុមារមេត្រី ការអប់រំបញ្ចូលគ្នា ថ្នាក់គួប អំណានដំបូង ជាដើម។ ជាក់ស្តែង ការបំប៉នលើកម្មវិធីអប់រំបញ្ចូលគ្នា គឺជាការងារសំខាន់មួយរួមចំណែកលើកកម្ពស់គុណភាពការបង្រៀន និងរៀនឲ្យកាន់តែប្រសើរឡើង ដោយលោកគ្រូអ្នកគ្រូត្រូវចេះស្វែងយល់ខ្លឹម-សារ និងសកម្មភាពឲ្យច្បាស់លាស់ ទន់ភ្លន់ សមស្របតាមពេលវេលា និងមជ្ឈដ្ឋានជាក់ស្តែង ដើម្បីជួយសិស្សទទួលបានលទ្ធផលសិក្សាល្អប្រសើរ (ក្រសួង អយក, ២០១២)។ មួយវិញទៀត ការរៀបចំកម្មវិធីរៀនអក្សរដំបូង គឺជាកម្មវិធីសំខាន់ផងដែរក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន ដែលមានគោលបំណងលើកកម្ពស់គុណភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរនៅតាមសាលារៀនបឋមសិក្សា និងជាការពង្រឹងគុណភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀននៅសាលាគរុកោសល្យទៀតផង (ក្រសួង អយក, ២០១១)។

ទន្ទឹមនឹងនេះ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែងបានអនុវត្តកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនតាមរយៈការសិក្សាស្រាវជ្រាវមេរៀនតាំងពីឆ្នាំ ២០០៨ មកម្ល៉េះ ក្រោមកិច្ចសហការរវាងក្រសួងអប់រំ យុវជន និងកីឡា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ JICA តាមរយៈគម្រោង STEPSAM2 ដែលមានគោលបំណងលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រ នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ហើយជាលទ្ធផលឃើញថា គ្រូឧទ្ទេសនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូមានការអភិវឌ្ឍជាបណ្តើរៗ ឯការរៀនរបស់សិស្សក៏មានការប្រែប្រួល ដូចជា សញ្ញាណនៃការគិត ការវិភាគ សំយោគ ការធ្វើពិសោធន៍មេរៀនវិទ្យាសាស្ត្រ ផ្ទុយពីការបង្រៀនតាមលំនាំពីមុន (ក្រសួង អយក, ២០១១)។ ក្នុងឆ្នាំ ២០១៥ដោយមានការគាំទ្របច្ចេកទេស និងសម្ភារៈពី VVOB សហការជាមួយនិងនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការនៃក្រសួងអប់រំ យុវជន និងកីឡា ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនបានបន្តរហូតមកតាមរយៈការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន។ ចាប់ពីឆ្នាំសិក្សា ២០១៧-២០១៨ មកដល់បច្ចុប្បន្ន មូលនិធិ Cambodia Charitably Trust (CCT) បានឧបត្ថម្ភលើការអនុវត្តកម្មវិធីសិក្សាស្រាវជ្រាវមេរៀនដល់គ្រូឧទ្ទេស ដើម្បីជំរុញឲ្យគ្រូឧទ្ទេសអនុវត្តការសិក្សាស្រាវជ្រាវមេរៀននេះតាមក្រុមមុខវិជ្ជាធំទាំងបួន ជាប្រយោជន៍ឲ្យការបង្រៀន និងរៀនទទួលបានប្រសិទ្ធភាពខ្ពស់។

ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន ដែលទទួលបានជោគជ័យទៅបានគឺអាស្រ័យលើការចូលរួមពីសំណាក់លោកគ្រូអ្នកគ្រូ និងអ្នកពាក់ព័ន្ធនានា ដែលជួយជំរុញដំណើរការសិក្សាមេរៀនឲ្យប្រព្រឹត្តទៅដោយរលូន។ ម្យ៉ាងទៀត ការអនុវត្តការសិក្សា

មេរៀនមានដំណើរការល្អទៅបាន គឺត្រូវផ្អែកលើអ្នកអនុវត្តផ្ទាល់ ពោលគឺគ្រូឧទ្ទេស ថាតើពួកគាត់មានទស្សនៈយល់ឃើញល្អ ពេញចិត្ត និងរីករាយក្នុងការទទួលយកការសិក្សាមេរៀនមកប្រតិបត្តិក្នុងវិជ្ជាជីវៈគ្រូបង្រៀនរបស់ខ្លួនឬទេ? ឬគ្រាន់តែជាការធ្វើតាមភារកិច្ចដែលគណៈគ្រប់គ្រងសាលារៀន និងក្រសួងអប់រំបានប្រគល់ជូនតែប៉ុណ្ណោះ? តើគ្រូពិតជាបានយល់ដឹងច្បាស់ពីខ្លឹមសារនៃការសិក្សាមេរៀនគ្រប់គ្នាឬទេ? តើគ្រូអនុវត្តការសិក្សាមេរៀនបានកម្រិតណា? ទាំងនេះនៅតែជាបញ្ហា ដែលជំរុញទឹកចិត្តឲ្យអ្នកស្រាវជ្រាវ និងគណៈគ្រប់គ្រងសាលាចង់ដឹង ដើម្បីធ្វើជាមូលដ្ឋានក្នុងការស្វែងរកដំណោះស្រាយ និងធ្វើសេចក្តីសម្រេចចិត្តឲ្យឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងផង និងជួយឲ្យការសិក្សាស្រាវជ្រាវមេរៀនក្នុងសាលាទទួលបានជោគជ័យ។

## ១.៣- គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងពិនិត្យមើលការយល់ដឹងពីការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង សំដៅលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈគ្រូឧទ្ទេសឲ្យកាន់តែប្រសើរឡើង និងចូលរួមចំណែកលើកកម្ពស់គុណភាពអប់រំ តាមកំណែទម្រង់របស់ក្រសួងអប់រំយុវជន និងកីឡា។

ការស្រាវជ្រាវនេះគឺផ្តោតជាសំខាន់លើវត្ថុបំណង ២ សំខាន់ គឺៈ

១. ស្វែងយល់ពីការយល់ដឹង និងបញ្ហាប្រឈមនៃការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង ។

២. ស្វែងយល់ពីទស្សនៈយល់ឃើញរបស់គ្រូឧទ្ទេស ចំពោះការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង ។

## ១.៤- សំណួរស្រាវជ្រាវ

សំណួរស្រាវជ្រាវខាងក្រោមត្រូវបានកំណត់ ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃស្រាវជ្រាវខាងលើៈ

១. តើគ្រូឧទ្ទេសនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែងមានការយល់ដឹងកម្រិតណាពីការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន? តើមានបញ្ហាប្រឈមអ្វីខ្លះ?

២. តើគ្រូឧទ្ទេសនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែងមានទស្សនៈយល់ឃើញជារួមយ៉ាងដូចម្តេច ចំពោះការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននេះ?

## ១.៥- សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើកនេះ ជាប្រយោជន៍មួយដ៏មានសារៈសំខាន់ក្នុងការផ្ដល់ព័ត៌មានជាមូលដ្ឋានសម្រាប់គណៈគ្រប់គ្រងអង្គភាព និងអ្នកពាក់ព័ន្ធ ដូចខាងក្រោម៖

១. ជួយដល់គណៈគ្រប់គ្រងឲ្យបានដឹងច្បាស់ពីកម្រិតសមត្ថភាពគ្រូក្នុងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅក្នុងអង្គភាពរបស់ខ្លួន។

២. ជួយដល់គណៈគ្រប់គ្រងក្នុងការរៀបចំការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនឲ្យកាន់ តែល្អប្រសើរឡើងនៅថ្ងៃខាងមុខ។

៣. ជួយដល់គណៈគ្រប់គ្រងឲ្យបានដឹងពីបញ្ហាប្រឈមនានាដែលកើតមានឡើងក្នុងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន ដើម្បីមានវិធានការដោះស្រាយបានទាន់ពេលវេលា។

៤. ជួយជំរុញការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនឲ្យកាន់តែប្រសើរឡើង។

៥. ជាចំណេះដឹងថ្មីជួយដល់គណៈគ្រប់គ្រង និងអ្នកពាក់ព័ន្ធក្នុងការរៀបចំផែនការកែលម្អសកម្មភាពលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀននាពេលអនាគត។

៦. ជាមេរៀនបទពិសោធមួយ សម្រាប់ឲ្យអង្គភាព ឬសាលារៀនផ្សេងទៀតយកជាគំរូ។

## ១.៦- ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៦.១ ដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ពុំបានពិនិត្យមើលការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនគ្រប់មុខវិជ្ជាទេ ដោយផ្ដោតជាសំខាន់តែទៅលើមុខវិជ្ជាធំចំនួន៤គឺគណិតវិទ្យា វិទ្យាសាស្ត្រ សិក្សាសង្គម និងភាសាខ្មែរ។ មូលហេតុដែលអ្នកស្រាវជ្រាវជ្រើសរើសមុខវិជ្ជាធំចំនួន៤នេះ គឺផ្អែកលើការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ) សហការជាមួយមូលនិធិ CCT កំណត់យកមុខវិជ្ជាធំទាំងបួនខាងលើជាអទិភាពក្នុងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន ដោយបានចែកចេញជាពីរក្រុម គឺក្រុមគណិត (គណិតវិទ្យា និងភាសាខ្មែរ) និងក្រុមវិទ្យាសាស្ត្រ (វិទ្យាសាស្ត្រ និងសិក្សាសង្គម)។

### ១.៦.២ វិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ជាករណីសិក្សាដែលត្រូវបានធ្វើឡើងចំពោះតែមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង ខេត្តស្ទឹងត្រែងតែប៉ុណ្ណោះ។

## ១.៧- រចនាសម្ព័ន្ធស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកជា ៥ជំពូកធំៗ៖

**ជំពូកទី១៖** សេចក្តីផ្តើម ក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវបានលើកឡើងពីលំនាំបញ្ហា ចំណោទបញ្ហា សំណួរស្រាវជ្រាវ គោលបំណង និងដែនកំណត់និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ។

**ជំពូកទី២៖** រំលឹកទ្រឹស្តី នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវបានប្រមូលទ្រឹស្តីចាស់ៗពីអ្នកសិក្សាស្រាវជ្រាវមុនៗដែលពាក់ព័ន្ធទៅនឹងប្រធានបទនេះដើម្បីធ្វើជាគំនិតសម្រាប់ធ្វើការស្រាវជ្រាវ និងបង្កើតស្នាដៃថ្មី ។

**ជំពូកទី៣៖** វិធីសាស្ត្រស្រាវជ្រាវ ជំពូកនេះអ្នកសិក្សាស្រាវជ្រាវបានបង្ហាញនូវឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ វិធីជ្រើសរើសសំណាក និងវិធីសាស្ត្រក្នុងការវិភាគទិន្នន័យជាដើម ។

**ជំពូកទី៤៖** លទ្ធផល និងការពិភាក្សា នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវបានយកទិន្នន័យដែលប្រមូលបានមកវិភាគ និងបកស្រាយយ៉ាងក្បោះក្បាយ ដើម្បីរកឱ្យឃើញនូវកម្រិតយល់ដឹង ការអនុវត្ត បញ្ហាប្រឈម និងទស្សនៈយល់ឃើញជារួម ។

**ជំពូកទី៥៖** សេចក្តីសន្និដ្ឋាន និងសំណូមពរ ជាផ្នែកមួយទៀតដែលអ្នកសិក្សាស្រាវជ្រាវត្រូវធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានយកមកវិភាគ ព្រមទាំងផ្តល់ជាសំណូមពរមួយចំនួនក្នុងបំណងចូលរួមចំណែក ធ្វើឱ្យការអនុវត្តការសិក្សាស្រាវ-ជ្រាវមេរៀនប្រសើរឡើងថែមទៀត។

# ជំពូកទី ២
# រំលឹកទ្រឹស្តី

# ជំពូកទី២
# រំលឹកទ្រឹស្តី

នៅក្នុងជំពូកនេះអ្នកស្រាវជ្រាវបានផ្តោតខ្លាំងទៅលើនិយមន័យ ពាក្យគន្លឹះ ប្រវត្តិនៃការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន និងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅកម្ពុជា ដែលមានការបកស្រាយពន្យល់ដូចខាងក្រោម៖

## ២.១. និយមន័យ និងពន្យល់ពាក្យគន្លឹះ

ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះ អ្នកស្រាវជ្រាវបានសិក្សាទៅលើឯកសារ មួយចំនួន ដែលបានឲ្យនិយមន័យទៅលើពាក្យថា "**ការសិក្សាស្រាវជ្រាវមេរៀន**" ឬជាភាសា អង់គ្លេសថា "Lesson Study" ដែលមានខ្លឹមសារដូចខាងក្រោម៖

ក្រសួងអប់រំ យុវជន និងកីឡា (២០១១) បានឲ្យនិយមន័យការសិក្សាស្រាវជ្រាវមេរៀនថា ជាដំណើរការអភិវឌ្ឍវិជ្ជាជីវៈ ដែលគ្រូត្រូវធ្វើការជាប្រព័ន្ធជាមួយអ្នករួមការងារ ដើម្បីពិនិត្យ និងអភិវឌ្ឍការបង្រៀនរបស់ពួកគេ។

Frances Haithcock (2010) បានហៅការសិក្សាស្រាវជ្រាវមេរៀនថា ជាដំណើរការ អភិវឌ្ឍវិជ្ជាជីវៈដែលត្រូវបានគេប្រើក្នុងការសិក្សាវិជ្ជាជីវៈ ដើម្បីផ្តល់ឱកាសឲ្យគ្រូបង្កើតនូវគំរូ មួយសម្រាប់អនុវត្តការបង្រៀនប្រកបដោយគុណភាពខ្ពស់។

Cerbin and Kopp. (2011) សំដៅទៅលើក្រុមគ្រូតូចមួយដែលធ្វើការរួមគ្នាតាមវដ្តជា ប្រព័ន្ធទាំងការធ្វើផែនការ ការបង្រៀន ការសង្កេត ការធ្វើឲ្យប្រសើរឡើង និងការឆ្លុះបញ្ចាំងលើមេរៀនជាក់លាក់។ ការសិក្សាស្រាវជ្រាវមេរៀនត្រូវឆ្លុះបញ្ចាំងលើតម្រូវការនៃការសិក្សារបស់សិស្ស ឬក៏បញ្ហាវិធីសាស្ត្របង្រៀន ហើយវាក៏បានផ្តល់នូវឱកាសឲ្យគ្រូត្រួតពិនិត្យលើការអនុវត្តរបស់ខ្លួន ដើម្បីអភិវឌ្ឍការបង្រៀនសិស្សឲ្យទទួលបានលទ្ធផលល្អប្រសើរ។

Pete Dudley (2011) ការសិក្សាស្រាវជ្រាវមេរៀន គឺជាទម្រង់ជាក់លាក់មួយនៃការសិក្សាស្រាវជ្រាវសកម្មភាពថ្នាក់រៀន ដោយឆ្លុះបញ្ចាំងទៅលើការអភិវឌ្ឍការប្រើចំណេះដឹងរបស់គ្រូ ដែលតម្រូវឲ្យគ្រូត្រូវសហការគ្នាជាក្រុមធ្វើផែនការ ធ្វើការបង្រៀន ធ្វើការសង្កេត និង ធ្វើការវិភាគការបង្រៀន និងរៀនក្នុងការសិក្សាស្រាវជ្រាវមេរៀន។

Karmelita Pjanić (2014) ថាការសិក្សាស្រាវជ្រាវមេរៀន គឺជាដំណើរការមួយដែលគ្រូបង្រៀនប្រឹងប្រែងធ្វើឡើងជាប្រព័ន្ធ ដើម្បីអភិវឌ្ឍវិធីសាស្ត្របង្រៀនរបស់ពួកគេតាមរយៈការធ្វើការងារជាមួយគ្រូបង្រៀនដទៃទៀត ដើម្បីពិនិត្យនិងផ្តល់ដំបូន្មាន

បច្ចេកទេសបង្រៀនឲ្យគ្នាទៅវិញទៅមក។ ដោយការសហការធ្វើការងាររបស់គ្រូលើការសិក្សាស្រាវជ្រាវមេរៀន និងផ្តោតលើការធ្វើផែនការការបង្រៀន ការសង្កេត ការផ្តល់ព័ត៌មានត្រឡប់ និងការផ្តល់ដំបូន្មានមេរៀន ដើម្បីឆ្លុះបញ្ចាំងនិងដឹកនាំការងារនេះ។

Peter Dudley (2019) បានលើកឡើងថា ការសិក្សាស្រាវជ្រាវមេរៀន គឺជាវិធីសិក្សាស្វែងយល់ពីវិជ្ជាជីវៈប្រកបដោយសក្តានុពល ដែលអាចធ្វើឲ្យប្រសើរឡើងនូវការបង្រៀន និងរៀន ចំណេះដឹងអនុវត្ត និងចំណេះដឹងមុខវិជ្ជារបស់គ្រូបង្រៀន។ វាមិនត្រឹមតែជួយសម្រេចលទ្ធផលសិក្សារបស់សិស្ស និងការសិក្សាវិជ្ជាជីវៈរបស់គ្រូប៉ុណ្ណោះទេ ថែមទាំងមានការនិយមចូលចិត្តពីសំណាក់គ្រូទាំងអស់ដែលអនុវត្តវាទៀតផង។

Maths Development Team (2017) ការសិក្សាស្រាវជ្រាវមេរៀន គឺជាដំណើរការនៃការធ្វើការរួមគ្នារបស់គ្រូបង្រៀន ដើម្បីដោះស្រាយនូវបញ្ហាជាក់លាក់ដែលពួកគាត់បានជួបប្រទះក្នុងការបង្រៀន និងរៀន។ ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន គឺក្នុងគោលបំណងអភិវឌ្ឍការបង្រៀន និងរៀន តាមរយៈការអភិវឌ្ឍវិធីសាស្រ្តបង្រៀន។

Teacher Development Trust (2015) ថា ការសិក្សាស្រាវជ្រាវមេរៀន គឺជាការស្រាវជ្រាវដឹកនាំដោយគ្រូបង្រៀនតាមគំរូបែបជប៉ុន ដែលក្រុមគ្រូបង្រៀនធ្វើការរួមគ្នាដើម្បីរកឲ្យឃើញនូវគោលដៅជាក់លាក់មួយ សម្រាប់អភិវឌ្ឍការរៀនសូត្ររបស់សិស្សពួកគេ ដោយការសហការរបស់គ្រូដែលបានចូលរួម ការរៀបចំផែនការ ការបង្រៀន និងការសង្កេតមេរៀនជាបន្តបន្ទាប់ ការពិភាក្សា ការឆ្លុះបញ្ចាំង និងការផ្តល់ធាតុចូល ដើម្បីធ្វើឲ្យការបង្រៀនរបស់ពួកគេប្រសើរឡើង។

រូបភាពទី១: គំនូសបង្ហាញពីការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន




ប្រភព: Teacher Development Trust, 2015

The Lesson Study Group (2018) លើកឡើងថា ការសិក្សាស្រាវជ្រាវមេរៀនជាការសិក្សាវិជ្ជាជីវៈ សម្រាប់ជំរុញចិត្តគ្រូក្នុងការបង្រៀននិងរៀន។ វាគឺជាវដ្តនៃការរិះរកសម្រាប់ជួយគ្រូពិសោធ សង្កេត និងអភិវឌ្ឍឡើង។ គ្រូត្រូវធ្វើការងាររួមគ្នាជាក្រុមនៅក្នុងសាលារៀន ដើម្បីជួយជំរុញ គ្រូនិងសិស្សឲ្យមានចំណាប់ក្នុងការបង្រៀន និងរៀន។ សូមពិនិត្យមើលគំនូសតាងខាងក្រោម៖

រូបភាពទី២: គំនូសបង្ហាញពីវដ្តនៃការសិក្សាស្រាវជ្រាវមេរៀន




ប្រភព: The Lesson Study Group, 2018

The Lesson Study Group (2018) ដដែលនេះក៏បានបញ្ជាក់ថា ការសិក្សាស្រាវជ្រាវមេរៀនខុសពីការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនពីមុន ដោយបានលើកយកចំណុច ៣ មកបង្ហាញ ដូចខាងក្រោម៖

1.ជំហរនៃការសិក្សា (A Learning Stance): ការសិក្សាស្រាវជ្រាវមេរៀនខុសពីការណែនាំ ឬការហ្វឹកហាត់ដែលវាផ្តោតលើតម្រូវការដោយស្មើភាពគ្នា។ សូម្បីតែអ្នកជំនាញក៏ត្រូវគេរំពឹងថានឹងដាក់សំណួរដ៏វែឆ្លាតអំពីការរៀនរបស់សិស្សដែរ។

2.ចែករំលែកភាពជាម្ចាស់ និងទំនួលខុសត្រូវ (Shared Ownership and Responsibility): ពេលដែលក្រុមសិក្សាមេរៀនធ្វើការជាមួយគ្នា សមាជិកក្រុមត្រូវមានអារម្មណ៍ថា មេរៀនជារបស់ពួកយើងទាំងអស់គ្នា មិនមែនជារបស់អ្នក ឬរបស់ខ្ញុំឡើយ។ សមាជិកទាំងអស់ត្រូវមើលឲ្យឃើញនូវវិភាគទានរបស់សមាជិកក្រុមទាំងអស់ ហើយខិតខំជំរុញការអភិវឌ្ឍវិជ្ជាជីវៈរបស់សមាជិកក្នុងក្រុមឲ្យប្រសើរឡើង។

3.សង្កត់ធ្ងន់លើសិស្ស មិនមែនគ្រូទេ (Emphasis on Students, Not the Teacher): ការសិក្សាស្រាវជ្រាវមេរៀនផ្តោតលើការរៀន និងការអភិវឌ្ឍរបស់សិស្ស។ វាផ្តល់នូវឱកាសដ៏កម្រ និងមានតម្លៃសម្រាប់គ្រូស្ថិតនៅក្នុងថ្នាក់រៀនយ៉ាងស្ងៀមស្ងាត់ ដើម្បីសង្កេតមើលការរៀនរបស់សិស្ស ដោយមិនចាំបាច់រៀបចំ ឬផ្តល់ការណែនាំដល់សិស្ស។

តារាងទី១: ភាពខុសគ្នារវាងការសិក្សាមេរៀន និងការអភិវឌ្ឍវិជ្ជាជីវៈពីមុន

| **ការអភិវឌ្ឍវិជ្ជាជីវៈពីមុន**<br>**Traditional Professional Development** | **ការសិក្សាស្រាវជ្រាវមេរៀន**<br>**Lesson Study** |
|---|---|
| ចាប់ផ្តើមជាមួយនឹងចម្លើយ<br>Begins with answer | ចាប់ផ្តើមជាមួយនឹងសំណួរ<br>Begins with question |
| ខ្លឹមសារបានមកពីចំណេះដឹងខាងក្រៅរបស់គ្រូ<br>Content driven by outside trainer | ខ្លឹមសារបានមកពីការរិះរករបស់សិស្ស<br>Content driven by participant inquiry |
| ទំនាក់ទំនងតាមលំដាប់ឋានានុក្រម<br>Relationships are hierarchical | ទំនាក់ទំនងពីគ្នាទៅវិញទៅមក<br>Relationships are reciprocal |
| ស្រាវជ្រាវរួចអនុវត្ត<br>Research informs practice | អនុវត្តតាមរយៈការស្រាវជ្រាវ<br>Practice is research |

ប្រភព: The Lesson Study Group, 2018

សរុបជារួមមកឃើញថា ការឲ្យនិយមន័យ និងការពន្យល់ពាក្យខាងលើនេះមានលក្ខណៈប្រហាក់ប្រហែលគ្នា ដែលអាចឲ្យអ្នកស្រាវជ្រាវសរុបបានថា ការសិក្សាស្រាវជ្រាវមេរៀន គឺជាដំណើរការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនជាប្រព័ន្ធ និងឥតឈប់ឈរក្នុងគោលបំណងដើម្បីលើកកម្ពស់ការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព។ ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន អាចមានការខុសប្លែកគ្នាខ្លះអាស្រ័យនឹងបរិបទនៃប្រទេស វប្បធម៌ និងទីកន្លែងនីមួយៗ តែទោះជាយ៉ាងណាក៏ដោយ ការអនុវត្តនេះត្រូវតែមានការរៀបចំផែនការ ការបង្រៀន ការត្រួតពិនិត្យ ការបង្រៀន និងការរៀបចំសកម្មភាពសិក្សាបន្ត។

## ២.២.ប្រវត្តិនៃការសិក្សាស្រាវជ្រាវមេរៀន

នៅក្នុងសំណេររបស់ Naomichi (2010) បានរៀបរាប់ថា ក្នុងកំឡុងដើមសម័យ **ម៉ីជី** (Meiji) ឆ្នាំ1868-1912 នៅប្រទេសជប៉ុន រដ្ឋាភិបាល **ម៉ីជី** បានណែនាំនូវប្រព័ន្ធសង្គមតាមបែបលោកខាងលិច សម្រាប់ធ្វើទំនើបកម្មធនធាននានារបស់ប្រទេស ដោយបានរួមបញ្ចូលទាំងប្រព័ន្ធសាលារៀនផង។ នៅឆ្នាំ 1817 ប្រព័ន្ធសាលារៀនថ្មីមួយ ដែលមានឈ្មោះថា "Gaku-sei" (ប្រព័ន្ធសាលារៀន) ត្រូវបានរដ្ឋាភិបាលដាក់ឲ្យដំណើរការ។ មុននោះមានតែ "Terakoya (សាលាបឋមសិក្សាសម្រាប់សាធារណៈទូទៅ)" និង "Hankou [សាលារដ្ឋតាមតំបន់សម្រាប់ក្រុមកុលសម្ព័ន្ធ(feudal clans)]" ប៉ុណ្ណោះ ដែលមិនបានគ្រប់គ្រងដោយរដ្ឋាភិបាល។ ដូច្នេះ ប្រព័ន្ធសាលារៀនទំនើបនៅក្នុងប្រទេសជប៉ុនគឺចាប់ផ្ដើមជាមួយប្រព័ន្ធសាលារៀន "Gaku-sei" ដែលរួមមានសាកលវិទ្យាល័យ "Dai-gaku" សាលាវិទ្យាល័យ "Tyu-gaku" និងសាលាបឋមសិក្សា "Syo-gaku"។ រដ្ឋាភិបាល **ម៉ីជី** បានខិតខំប្រឹងប្រែងពង្រីកសាលាបឋមសិក្សាទូទាំងប្រទេស និងអភិវឌ្ឍប្រព័ន្ធសាលារៀនចាប់ពីការអប់រំបឋមសិក្សាឡើងទៅ ក្នុងគោលបំណងដើម្បីធ្វើឲ្យការអប់រំមនុស្សដែលមានទេពកោសល្យក្លាយជាជនឈានមុខគេ។ ក្នុងសម័យនេះ បញ្ហាបន្ទាន់ គឺត្រូវអនុវត្តអរិយធម៌ និងបច្ចេកវិទ្យាលោកខាងលិច ដើម្បីកសាងប្រទេសដ៏ទំនើបមួយដូចបណ្ដាប្រទេសលោកខាងលិច។ ហេតុផលនេះហើយ បានតម្រូវឲ្យសាលារៀនត្រូវតែផ្ដល់ជូនប្រទេសជាតិនូវការបណ្ដុះបណ្ដាលធនធានមនុស្សដ៏សមរម្យ។ ដូចគ្នានេះដែរ Karmelita (2014) បានលើកឡើងថា ការសិក្សាស្រាវជ្រាវមេរៀនត្រូវបានគេអនុវត្តនៅក្នុងសម័យ **ម៉ីជី** (Meiji) នៃប្រទេសជប៉ុន នៅក្នុងសាលាបណ្ដុះបណ្ដាលគ្រូបង្រៀនក្នុងទីក្រុងតូក្យូ (Tokyo Normal School) ដែលក្រោយមកសាលារៀននេះបានប្រែក្លាយជាសាកលវិទ្យាល័យ Tsukuba នៅក្នុងទស្សវត្តឆ្នាំ 1870។ វាជាវិធីសង្កេតការបង្រៀនមួយ

នៅក្នុងថ្នាក់ទាំងមូល ដែលមានពាក្យជាភាសាជប៉ុនថា jugyo kenkyuu ដែលក្រោយមកទៀតត្រូវលោក Makoto Yoshida ប្រើពាក្យជាភាសាអង់គ្លេសថា Lesson Study ឬ Research Lesson នៅឆ្នាំ១៩៩៩ ក្នុងការសិក្សាថ្នាក់បណ្ឌិតរបស់លោក។

ការសិក្សាស្រាវជ្រាវមេរៀនមានដើមកំណើតដំបូងនៅក្នុងប្រទេសជប៉ុន ហើយបានរីកសាយដល់បណ្តាប្រទេសជាច្រើននៅលើសកលលោក ដោយមានគ្រូជាច្រើនបានអនុវត្តកម្មវិធីនេះ មិនត្រឹមតែនៅក្នុងប្រទេសជប៉ុនប៉ុណ្ណោះទេ សូម្បីតែនៅក្នុងប្រទេសអង់គ្លេសក៏ត្រូវបានគេចាត់បញ្ចូលជាផ្នែកមួយនៃកម្មវិធីគ្រូនាំមុខគេ ដែលផ្តល់ថវិកាដោយក្រសួងអប់រំរបស់អង់គ្លេសនៅឆ្នាំ 2007 ដោយគេជឿថាវាធ្វើឲ្យមានការរីកចម្រើនដល់លទ្ធផលស្តែងចេញរបស់សិស្ស (Foghlam, 2015)។ សហរដ្ឋអាមេរិកបានចាប់អនុវត្តការសិក្សាស្រាវជ្រាវមេរៀនតាមបែបជប៉ុន (jugyou kenkyuu) ជាលើកដំបូងនៅចុងទសវត្សឆ្នាំ 1990 ។ ចាប់តាំងពីពេលនោះមក គ្រូបង្រៀននិងអ្នកអប់រំជាច្រើនបានចាប់អារម្មណ៍និងបានចូលរួមក្នុងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនយ៉ាងខ្លាំងក្លា ដោយគេបានរាយការណ៍ថា ការសិក្សាស្រាវជ្រាវមេរៀនមានផលប៉ះពាល់ជាវិជ្ជមានលើការរៀនរបស់សិស្ស (Tad, 2018)។ ប្រទេសចិនធ្លាប់មានប្រវត្តិយូរអង្វែងណាស់មកហើយក្នុងការអភិវឌ្ឍការបង្រៀននិងរៀន តាមរយៈសហគមសិក្សាវិជ្ជាជីវៈផ្អែកលើសាលារៀន ដែលគេហៅថា ការសិក្សាស្រាវជ្រាវរបស់គ្រូបង្រៀន។ ការសិក្សាស្រាវជ្រាវមេរៀនក៏ត្រូវគេអនុវត្តផងដែរចំពោះប្រទេសនៅអាមេរិកខាងត្បូង អាហ្វ្រិចខាងត្បូង និងអូស្ត្រាលី។ ដូចគ្នាផងដែរ ចំពោះបណ្តាប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍មានដូចជា ប្រទេសឥណ្ឌូនេស៊ី និងម៉ាឡេស៊ី (Brian & Susie, 2011)។ ក្រៅពីនេះ នៅសាំងហ្គាព័រ ក្រសួងអប់រំបានជំរុញឲ្យមានការសិក្សាវិជ្ជាជីវៈជាក្រុម ដែលជាគំនិតផ្តួចផ្តើមឲ្យគ្រូបង្រៀនធ្វើការងារជាក្រុមរួមគ្នា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពវិជ្ជាជីវៈរបស់គ្រូនិងជាប្រយោជន៍ដល់ការរៀនរបស់សិស្ស។ ការសិក្សាស្រាវជ្រាវមេរៀនគឺជាវិធីមួយដែលអាចឲ្យគ្រូបង្រៀនចូលរួមក្នុងការសិក្សាវិជ្ជាជីវៈខាងលើនេះបាន។ វាជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយជាច្រើនដែលគេប្រើនៅក្នុងក្រុមសិក្សាវិជ្ជាជីវៈ ហើយវាកាន់តែមានប្រជាប្រិយភាពខ្លាំងឡើងៗ នៅក្នុងប្រទេសសាំងហ្គាព័រ (Irene, 2011)។ ជាមួយនឹងគុណសម្បត្តិដ៏ធំធេងនេះ ប្រទេសសាំងហ្គាព័រមានទិសដៅអនាគតចំនួន ៤ គឺ ទី១ អភិវឌ្ឍបណ្តាញក្រុមសិក្សាស្រាវជ្រាវមេរៀនសាំងហ្គាព័រ ទី២ ភ្ជាប់ទំនាក់ទំនងជាមួយសមាគមសិក្សាស្រាវជ្រាវមេរៀនពិភាពលោក ក្រុមសិក្សាស្រាវជ្រាវមេរៀននៅស៊ីហ្គាកូ នៅមហាវិទ្យាល័យ Mills អភិវឌ្ឍសម្ភារៈបង្រៀនតាមវិបសាយ ដើម្បីជួយដល់

គ្រូ និងការស្រាវជ្រាវមេរៀននិងពិភាក្សាជាសាធារណៈ (N.I.E, 2007)។ ចំណែកនៅប្រទេសឥណ្ឌូនេស៊ីវិញឃើញថា មានកត្តាធំ ៣ សំខាន់ដែលធ្វើឲ្យការសិក្សាស្រាវជ្រាវមេរៀនស្ថិតនៅ និងផ្សព្វផ្សាយបានទូលំទូលាយ។ ទី១ ការអនុវត្តនយោបាយយ៉ាងខ្លាំងក្លាដើម្បីធានាគុណភាពអប់រំ ដោយបានបង្កើតច្បាប់អប់រំថ្មីនៅឆ្នាំ២០០៣ ទី២ គឺកំណែទម្រង់អប់រំសំខាន់ៗ ដែលរួមមាន ការធ្វើវិមជ្ឈការអប់រំទៅឲ្យការិយាល័យអប់រំស្រុកជាអង្គភាពរដ្ឋបាល និងជាអ្នកធ្វើគោលនយោបាយអប់រំដោយស្វ័យត និងផ្តល់ថវិកាដល់សាលារៀន និងស្រុក រួមគ្នាធ្វើឲ្យគុណភាពអប់រំប្រសើរឡើង។ ធ្វើកំណែទម្រង់គ្រូបង្រៀន ដោយបង្កើតច្បាប់ស្តីពីគ្រូបង្រៀននៅឆ្នាំ២០០៥ ដើម្បីលើកទឹកចិត្តគ្រូចូលរួមក្នុងការសិក្សាស្រាវជ្រាវមេរៀនឲ្យទទួលបានវិញ្ញាបនបត្រគ្រូ និងអនុវត្តកម្មវិធីចូលរួមក្នុងសាលារៀនសម្រាប់គ្រូចេញថ្មី។ ទី៣ គឺការចូលរួមជាប្រចាំរបស់អ្នកអប់រំគ្រូ សាកលវិទ្យាល័យអប់រំគ្រូ ដូចជា បង្កើតភាពជាដៃគូរវាងគ្រូពីសាកលវិទ្យាល័យនិងរដ្ឋបាលថ្នាក់មូលដ្ឋានឬថ្នាក់ជាតិ ដឹងពីគោលនយោបាយគាំទ្រស្ថាប័ន និងហិរញ្ញវត្ថុ បន្តកសាងធនធានមនុស្ស និងគាំទ្រដល់គ្រូ អ្នកគ្រប់គ្រងសាលារៀន ជាដើម (Keiko, 2017)។ នៅក្នុងកំណែទម្រង់ចលនាអប់រំឆ្នាំ 1999-2009 របស់ប្រទេសថៃ ក្រសួងអប់រំថៃ អង្គការរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលបានផ្តល់ការគាំទ្រដល់ការអភិវឌ្ឍកម្មវិធីសិក្សា និងគម្រោងផ្សេងៗ ដើម្បីធ្វើឲ្យប្រសើរឡើងនូវគុណភាពអប់រំ។ មកដល់ឆ្នាំ ២០០២ ការសិក្សាស្រាវជ្រាវមេរៀនបែបជប៉ុនមួយ ក៏បានចូលមកក្នុងសាលារៀននៅខេត្តខនកែនប្រទេសថៃ។ អ្នកស្រាវជ្រាវគឺ លោកបណ្ឌិត ម៉ៃទ្រី អ៊ីនប្រាស៊ីថា បានចាប់ផ្តើមអនុវត្តការសិក្សាស្រាវជ្រាវមេរៀនជាមួយគរុនិស្សិតស្ម័គ្រចិត្ត ១៥ នាក់ បង្រៀនគណិតវិទ្យានៅតាមសាលាមធ្យមសិក្សាចំនួន ៧ នៅខេត្តខនកែន (Maitree, 2010)។

សរុបមក ការសិក្សាស្រាវជ្រាវមេរៀនមានដើមកំណើតនៅប្រទេសជប៉ុន ហើយមានដំណើររីកចម្រើន និងបានផ្សព្វផ្សាយដល់បណ្តាប្រទេសជាច្រើននៅលើសកលលោក ដូចជា នៅអាមេរិក អឺរ៉ុប អាហ្វ្រិច អាស៊ី និងអាស៊ីអាគ្នេយ៍ ក្នុងនោះមានប្រទេសកម្ពុជាយើងដែរ។

## ២.៣.ការសិក្សាស្រាវជ្រាវមេរៀននៅកម្ពុជា

ការសិក្សាស្រាវជ្រាវមេរៀនមាន ៤ ដំណាក់កាលសំខាន់ គឺការរៀបចំមេរៀន (Plan) ការអនុវត្តការបង្រៀននិងការសង្កេត (Do) ការពិភាក្សាកែលម្អលើការបង្រៀន (Check) និង ការធ្វើសកម្មភាពកែលម្អការបង្រៀនក្នុងក្រុមបន្ទាប់ពីការពិភាក្សាកែលម្អក្នុងក្រុមរួច (Action)។

រូបភាពទី៣៖ វដ្តនៃការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន




ប្រភព: STEPSAM2, (២០១១)

## ក. គុណសម្បត្តក្នុងការសិក្សាស្រាវជ្រាវមេរៀន

ដោយផ្អែកលើបទពិសោធ នៃការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅតាមបណ្តាប្រទេសជាច្រើនឃើញថា ការសិក្សាស្រាវជ្រាវមេរៀននឹងជួយដល់គ្រូបង្រៀន៖

-ជួយកែលម្អការបង្រៀននិងរៀន តាមរយៈការខិតខំប្រឹងប្រែងរបស់ផ្ទាល់ខ្លួនរបស់ គ្រូ ទោះបីគ្រូមានបទពិសោធ និងមានទម្លាប់ផ្សេងគ្នាក៏ដោយ។

-ជួយគ្រូឲ្យចេះសហការគ្នាក្នុងជំនាក់កាលនីមួយៗនៃការរៀបចំផែនការ ការអនុវត្ត និងកការកែលម្អមេរៀន ដែលជាកត្តាសំខាន់ក្នុងការលើកកម្ពស់ការបង្រៀនឲ្យមានប្រសិទ្ធភាព។

-ជួយគ្រូឲ្យចេះចែករំលែកបទពិសោធ និងចេះរៀនសូត្រពីគ្នាទៅវិញទៅមកដើម្បីអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនឲ្យប្រសើរឡើង។

-ជួយផ្តល់ឱកាសសម្រាប់អ្នកបង្រៀន និងអ្នកសង្កេតវាយតម្លៃ ឲ្យជំរុញការសិក្សាស្វែងយល់មិនចេះចប់។

## ខ. ការបង្កើតក្រុមសិក្សាស្រាវជ្រាវមេរៀន

សាលារៀននីមួយៗ ដែលអនុវត្តការសិក្សាស្រាវជ្រាវមេរៀន ត្រូវបង្កើតក្រុមសិក្សា ស្រាវជ្រាវមេរៀន ដោយត្រូវបញ្ចូលបុគ្គលិកពាក់ព័ន្ធទាំងអស់នៅក្នុងសាលា និងត្រូវកំណត់ ពីសមាសភាពក្រុមសិក្សាស្រាវជ្រាវមេរៀន និងតួនាទីរបស់ពួកគេ។

តារាងទី២៖ សមាសភាពក្រុមសិក្សាស្រាវជ្រាវមេរៀន

| **សមាសភាពក្រុមសិក្សាមេរៀន** | **តួនាទី** |
|---|---|
| នាយក ឬ នាយករង | ដឹកនាំ និងត្រួតពិនិត្យការអនុវត្តការសិក្សាមេរៀន |
| ប្រធានការិយាល័យសិក្សា | ជួយសម្រួលខាងផ្នែករដ្ឋបាល |
| ប្រធានក្រុមបច្ចេកទេស | សម្របសម្រួលការពិភាក្សាមុន និងក្រោយបង្រៀន |
| គ្រូឧទ្ទេស ឬ គ្រូបង្រៀន | រៀបចំកិច្ចតែងការបង្រៀន ធ្វើការនង្រៀន និង សង្កេតថ្នាក់ ពិភាក្សាលើកការបង្រៀន និងរៀន |

ប្រភព: ក្រសួង អយក. (២០១១)

ក្រៅពីបុគ្គលិកខាងលើ អ្នកផ្សេងទៀតដែលជាគ្រូ ឬជាអ្នកជំនាញតាមមុខវិជ្ជានៅ ក្នុងសាលារៀន ឬមន្ទីរ ឬការិយាល័យអប់រំក៏អាចចូលរួមនៅក្នុងការសិក្សាស្រាវជ្រាវមេរៀនបានដែរ។ គ្រប់សមាជិកទាំងអស់គួរយល់ដឹងអំពីដំណើរការនៃការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន និងចូលរួមពិភាក្សាជាមួយគ្រូដទៃ ដើម្បីបានសិក្សារៀនសូត្រពីគ្នាទៅវិញទៅមក មិនមែនជាការបង្រៀនពីគ្រូម្នាក់ទៅគ្រូម្នាក់ទៀតឡើយ។ ជាងនេះទៅទៀត នៅក្នុងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ឬសាលារៀនចំណោះទូទៅ គេអាចបង្កើតក្រុមសិក្សាស្រាវជ្រាវមេរៀនតាមមុខវិជ្ជា ឬពីរមុខបញ្ចូលគ្នាក៏បាន។ សូម្បីតែនៅពេលគរុសិស្សចុះធ្វើកម្មសិក្សាគរុកោសល្យ ក៏គេអាចអនុវត្តការសិក្សាស្រាវជ្រាវមេរៀនបានដែរ ដោយមានគរុសិស្ស គ្រូណែនាំ និងគ្រូឧទ្ទេសជាសមាជិក។

### គ.ដំណើរការនៃការសិក្សាស្រាវជ្រាវមេរៀន

ដូចបានរៀបរាប់ខាងលើ ការសិក្សាស្រាវជ្រាវមេរៀនមានបួនដំណាក់កាល គឺការរៀបចំមេរៀន ការអនុវត្តការបង្រៀននិងការសង្កេត ការពិភាក្សាកែលម្អលើការបង្រៀន និងការធ្វើសកម្មភាពកែលម្អបន្ត។

**១. ការរៀបចំមេរៀន (Plan)**

ការរៀបចំមេរៀន ជាការរៀបចំកិច្ចតែងការបង្រៀនផង និងជាការរៀបចំសកម្មភាពជាច្រើនផង ដោយត្រូវការពេលវេលាពីរឬបីសប្តាហ៍ដើម្បីបញ្ចប់។ សកម្មភាព

រៀបចំមេរៀនរួមមាន ការសិក្សាលើខ្លឹមសារដែលត្រូវបង្រៀន ការរៀបចំកាលវិភាគ ការរៀបចំកិច្ចតែងការបង្រៀន ការពិភាក្សាលើកិច្ចតែងការបង្រៀនជាមួយសមាជិក ការធ្វើការបង្រៀនសាកល្បង ការកែលម្អកិច្ចតែងការបង្រៀន ជាដើម។ តារាងខាងក្រោមនេះនឹងបង្ហាញពីភារកិច្ច និងដំណើរការសម្រាប់ការរៀបចំមេរៀន។

តារាងទី៣៖ ភារកិច្ច និងដំណើរការនៅក្នុងដំណាក់កាលរៀបចំមេរៀន

| ជំហាន | ភារកិច្ចរបស់គ្រូបង្រៀន | |
|---|---|---|
| | កម្រិតដំបូង | កម្រិតខ្ពស់ |
| | ការចាត់តាំងគ្រូបង្រៀន | |
| ១ | ក្រុមសិក្សាស្រាវជ្រាវមេរៀនពិភាក្សាគ្នា ដើម្បីចាត់តាំងគ្រូបង្រៀនឲ្យឡើងបង្រៀន ហើយកំណត់ថ្ងៃជួបគ្នា និងថ្ងៃត្រូវឡើងបង្រៀន ព្រមទាំងប្រធានបទបង្រៀន។ | ដូចគ្នានឹងកម្រិតដំបូងដែរ |
| | ការរៀបចំកិច្ចតែងការបង្រៀន | |
| ២ | ឲ្យគ្រូបង្រៀនដែលបានចាត់តាំងឡើងបង្រៀន ដោយធ្វើការសិក្សាខ្លឹមសារមេរៀន និងសរសេរ កិច្ចតែងការបង្រៀន ។ | គ្រូដែលបានចាត់ឲ្យឡើងបង្រៀនត្រូវសិក្សាខ្លឹមសារមេរៀន រចនាសម្ព័ន្ធកម្មវិធីសិក្សា វិភាគពីកម្រិតយល់របស់សិស្ស ខ្លឹមសារដែលមានទំនាក់ទំនងគ្នា រួចទើបចាប់ផ្តើមសរសេរកិច្ចតែងការបង្រៀន និងប្លង់បង្រៀនជាមួយគ្នាតែម្តង។ |
| | ការពិភាក្សាលើកិច្ចតែងការបង្រៀន | |
| ៣ | ក្រុមសិក្សាស្រាវជ្រាវមេរៀន ពិនិត្យមើលកិច្ចតែងការបង្រៀន ថាតើសមស្របដែលអាចនាំឲ្យសម្រេចលទ្ធផលសិក្សារំពឹងទុកឬទេ? ការបង្រៀនសាកល្បងអាចធ្វើក្នុងក្រុមបាន។ | ក្រុមសិក្សាស្រាវជ្រាវមេរៀន ពិនិត្យលើកិច្ចតែង ការបង្រៀនយ៉ាងហ្មត់ចត់ថាតើវាសមស្របដែលអាចនាំឲ្យសម្រេចលទ្ធផលសិក្សារំពឹងទុកឬទេ? មានទំនាក់ទំនងរវាងមេរៀនមុននិងមេរៀក្រោយឬទេ? វិធីសាស្ត្របង្រៀនស្របនឹងសិស្សឬទេ? |
| | ការសរសេរកិច្ចតែងការសម្រេច | |
| ៤ | គ្រូបង្រៀនដែលបានចាត់ឲ្យឡើងបង្រៀនត្រូវកែលម្អកិច្ចតែងការបង្រៀន ដោយផ្អែកលើអនុសាសន៍ដែលបានផ្តល់ក្នុងជំហានទី៣ រួចរៀបចំសម្រាប់ឡើងបង្រៀនសិស្សក្នុងថ្នាក់។ | ដូចគ្នានឹងកម្រិតដំបូងដែរ |

ប្រភព: ក្រសួង អយក. (២០១១)

ការពិភាក្សានៅក្នុងជំហានទី៣ ដោយសមាជិកក្រុមសិក្សាស្រាវជ្រាវមេរៀន ត្រូវប្រើឧបករណ៍កែលម្អកិច្ចតែងការបង្រៀន ដែលឧបករណ៍នេះមានចំណុច ៥ សំខាន់ គឺ ការទាក់ទាញ វត្ថុបំណង សកម្មភាព ការគិត និងការយល់ដឹង។ មួយវិញទៀត គ្រូបង្រៀននៅក្នុងកម្រិតដំបូង គ្រាន់តែផ្តោតទៅលើការបង្រៀនដែលមាននៅក្នុងកិច្ចតែងការបង្រៀនប៉ុណ្ណោះ ឯគ្រូបង្រៀននៅក្នុងកម្រិតខ្ពស់ ត្រូវគិតវិភាគលើទំនាក់ទំនងរវាងមេរៀននឹងស្ថានភាពរបស់សិស្សម្នាក់ៗ។ ការចាប់ផ្តើមអនុវត្តការសិក្សាស្រាវជ្រាវមេរៀនដំបូងត្រូវផ្តើមពីកម្រិតដំបូង ហើយអភិវឌ្ឍជាបណ្តើរៗ ឆ្ពោះទៅរកកម្រិតខ្ពស់ ដោយប្រើពេលវេលាពីបីទៅបួនឆ្នាំ។

**២. ការអនុវត្តការបង្រៀន និងការសង្កេត (Do)**

ក្រោយពេលរៀបចំកិច្ចតែងការបង្រៀនរួចហើយ គ្រូដែលបានចាត់តាំងឲ្យឡើងបង្រៀន ត្រូវបង្រៀនទៅតាមកិច្ចតែងការដែលបានរៀបចំ និងកែលម្អក្នុងដំណាក់កាលរៀបចំមេរៀន។ ក្រុមសិក្សាស្រាវជ្រាវមេរៀនត្រូវជួបជុំគ្នានៅក្នុងថ្នាក់រៀន ដើម្បីសង្កេតមើលវិធីបង្រៀនរបស់គ្រូ និងរបៀបរៀនរបស់សិស្ស ព្រមទាំងអ្វីផ្សេងទៀតដែលសិស្សបានរៀន និងមិនបានរៀននៅក្នុងម៉ោងនោះ។ ចំណុចសំខាន់ដែលអ្នកសង្កេតត្រូវយកចិត្តទុកដាក់ គឺកម្រិតនៃការសម្រេចវត្ថុបំណង គុណភាព និងភាពសមស្របនៃសកម្មភាពបង្រៀននិងរៀន វិធីគិត និងជម្រៅនៃការគិតរបស់សិស្ស។

**ការណែនាំសម្រប់អ្នកបង្រៀន៖**

-ត្រូវយកចិត្តទុកដាក់ខ្ពស់លើសិស្សនិងការរៀនរបស់គេ ជាជាងផ្តោតតែទៅលើកិច្ចតែងការបង្រៀន។

-ត្រូវគិតថាអ្នកសង្កេតមិននៅក្នុងថ្នាក់រៀនទេ

-ត្រូវសម្រួលអារម្មណ៍ ហើយត្រូវគិតថា ការបង្រៀននេះមិនមែនជាការវាយតម្លៃលោកគ្រូអ្នកគ្រូទេ តែវាជាឱកាសឲ្យលោកគ្រូអ្នកគ្រូ និងសហការីអភិវឌ្ឍវិធីសាស្ត្របង្រៀនតែប៉ុណ្ណោះ។

**ការណែនាំសម្រាប់អ្នកសង្កេត៖**

-ត្រូវយកចិត្តទុកដាក់លើសកម្មភាពបង្រៀននិងរៀន ដែលកើតមានជាក់ស្តែងនៅក្នុងម៉ោងបង្រៀននេះ ដោយមិនផ្តោតតែទៅលើកិច្ចតែងការ។

-ត្រូវព្យាយាមឈរ ឬដើរទៅសង្កេតសិស្សឲ្យបានជិត ប៉ុន្តែមិនត្រូវរំខានសិស្ស ឬជជែកជាមួយអ្នកសង្កេតផ្សេងទៀតឡើយ។

-សូមកត់ត្រាលម្អិតអំពីការបង្រៀន និងរៀន រួមទាំងឃ្លាប្រយោគដែល

សិស្សធ្វើបាន ទំនាក់ទំនងរវាងគ្រូនិងសិស្ស របៀបដែលសិស្សធ្វើខុស និងរបៀបកែកំហុស ដើម្បីធ្វើការសម្រេចចិត្តឲ្យបានត្រឹមត្រូវពេលផ្តល់យោបល់កែលម្អ។

**ការសង្កេតការបង្រៀន និងរៀន៖**

ជាធម្មតា អ្នកសង្កេតការបង្រៀន និងរៀនតែងតែអង្គុយនៅតុផ្នែកខាងក្រោយនៃថ្នាក់រៀនពេញមួយម៉ោងសិក្សា ដើម្បីសង្កេតមើលការបង្រៀនរបស់គ្រូ និងការរៀនរបស់សិស្ស។ អ្នកសង្កេតតែងតែមើលលើគ្រូបង្រៀន ជាជាងមើលលើការបង្រៀន។ បើយើងមានបំណងធ្វើឲ្យសម្រេចបាននូវការអប់រំតាមគោលវិធីសិស្សមជ្ឈមណ្ឌល នោះការសង្កេតការបង្រៀនត្រូវផ្តោតទៅលើសិស្សជាចម្បង។ រូបខាងក្រោមនេះនឹងបង្ហាញពីការសង្កេតការបង្រៀនពីមុន និងការសង្កេតការបង្រៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល។

រូបភាពទី៤៖ អ្នកសង្កេតការបង្រៀនពីមុន និងអ្នកសង្កេតការបង្រៀន
បែបគោលវិធីសិស្សមជ្ឈមណ្ឌល




ប្រភព: ក្រសួង អយក, (២០១១)

## ឧបករណ៍សង្កេតការបង្រៀន និងរៀន៖

អ្នកសង្កេតការបង្រៀន និងរៀន ដែលជាសមាជិកក្រុមសិក្សាស្រាវជ្រាវមេរៀន ត្រូវប្រើឧបករណ៍សង្កេតការបង្រៀន ដើម្បីជាជំនួយដល់អ្នកសង្កេតក្នុងការកត់ត្រាសកម្មភាពបង្រៀនរបស់គ្រូ និងសកម្មភាពរៀនរបស់សិស្សទៅតាមពេលនីមួយៗ។

រូបភាពទី៥៖ ឧបករណ៍សង្កេតការបង្រៀន និងរៀន

**ឧបករណ៍សង្កេតការបង្រៀន និងរៀន**

ចែកនៅពេលណា? → មុនការបង្រៀនចាប់ផ្ដើម

អ្នកណាជាអ្នកបំពេញ? → គ្រប់សមាជិកក្រុមសិក្សាស្រាវជ្រាវមេរៀន (បំពេញម្នាក់មួយសន្លឹក)

សរសេរពេលណា? → កំឡុងពេលសង្កេតការបង្រៀន និងរៀន

កាលបរិច្ឆេទ៖............................ ឈ្មោះសាលា៖...................................

ឈ្មោះអ្នកសង្កេត៖..............................................................................

ចំណងជើងមេរៀន ឬប្រធានបទ៖........................................................

ឈ្មោះគ្រូបង្រៀន៖..............................................................................

| ម៉ោង | សកម្មភាពសិស្ស | សកម្មភាពគ្រូ |
|---|---|---|
| | | |

ប្រភព: ក្រសួង អយក, (២០១១)

### ៣. ការពិភាក្សាលើការបង្រៀន និងរៀន (Check)

បន្ទាប់ពីបានបង្រៀន និងសង្កេតការបង្រៀនចប់ សមាជិកក្រុមសិក្សាស្រាវជ្រាវមេរៀនត្រូវពិភាក្សាគ្នា ដែលការពិភាក្សានេះមិនត្រឹមតែដើម្បីកែលម្អការបង្រៀន និងរៀន ហើយនិងវិធីសាស្ត្របង្រៀនរបស់គ្រូដែលឡើងបង្រៀនប៉ុណ្ណោះទេ តែក៏ដើម្បីផ្តល់ឱកាសឲ្យសមាជិកក្រុមសិក្សាស្រាវជ្រាវមេរៀន និងគ្រូផ្សេងទៀតបានសិក្សាស្វែងយល់ និងផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមក សម្រាប់ជាការអភិវឌ្ឍការបង្រៀនរបស់ខ្លួនឯងផងដែរ។ ការពិភាក្សានេះត្រូវធ្វើជាដំណាក់ៗ ដូចតារាងខាងក្រោម៖

#### ដំណើរការពិភាក្សា

តារាងទី៤៖ ដំណើរការនៃការពិភាក្សាលើការបង្រៀន និងរៀន

| សកម្មភាព | កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល |
|---|---|
| ០. ចាត់តាំងអ្នកសម្របសម្រួលម្នាក់ និងលេខាកត់ត្រាម្នាក់ | -ត្រូវជ្រើសរើសអ្នកផ្សេងក្រៅពីគ្រូដែលបានបង្រៀន។ |
| ១. ចំណាប់អារម្មណ៍របស់គ្រូដែលឡើងបង្រៀន | -ឲ្យគ្រូដែលឡើងបង្រៀន បង្ហាញចំណាប់អារម្មណ៍អំពីការបង្រៀនរបស់គាត់។<br>-ឲ្យគ្រូដែលឡើងបង្រៀនពន្យល់នូវចំណុចដែលគាត់គិតថាធ្វើបានល្អ និងចំណុចដែលគាត់យល់ថាលំបាក។ |
| ២. ការពិភាក្សាអំពីការបង្រៀន និងរៀន | |
| -ចំណុចល្អ | -សមាជិកម្នាក់ៗត្រូវបញ្ចេញមតិយ៉ាងហោចមួយយោបល់។<br>-ឲ្យសមាជិកម្នាក់ៗផ្តល់ឧទាហរណ៍ទាក់ទងនឹងចំណុចដែលគាត់គិតថាល្អ។<br>-ត្រូវព្យាយាមបង្កើតបរិយាកាសល្អក្នុងការពិភាក្សា។ |
| -ចំណុចសំខាន់ត្រូវកែលម្អជាមួយគំនិតដែលអាចសាកល្បងបាន | -សមាជិកម្នាក់ៗត្រូវបញ្ចេញមតិយ៉ាងហោចមួយយោបល់។<br>-ត្រូវផ្តោតតែទៅលើ ថាតើត្រូវធ្វើដូចម្តេចដើម្បីឲ្យសិស្សបានរៀនច្រើនជាងមុន។<br>-ត្រូវជំរុញការពិភាក្សារវាងសមាជិកនិងសមាជិក មិនមែនតែរវាងសមាជិកនិងគ្រូដែលឡើងបង្រៀននោះទេ។ |
| ៣. ការបូកសរុបការពិភាក្សា | -ចែករំលែកលទ្ធផលនៃការពិភាក្សា និងមើលទៅលើចំណុចសំខាន់ដែលបានមកពីការពិភាក្សា សម្រាប់ឲ្យសិក្ខាកាមទាំងអស់កែលម្អការបង្រៀនរៀងៗខ្លួន។ |

ប្រភព: ក្រសួង អយក, (២០១១)

**គោលការណ៍ទូទៅនៃការពិភាក្សា៖**

ដើម្បីឲ្យការពិភាក្សាដំណើរការរលូនល្អ តួនាទីរបស់អ្នកសម្របសម្រួលគឺពិតជាសំខាន់ណាស់ ព្រោះការពិភាក្សារបស់សមាជិកក្នុងក្រុមអាចទទួលបានចំណេះដឹងច្រើន ឬ តិចពីការសិក្សាស្រាវជ្រាវមេរៀន គឺវាអាស្រ័យទៅលើគុណភាពនៃការដឹកនាំការពិភាក្សារបស់អ្នកសម្របសម្រួល។ ទោះបីជាយ៉ាងណាក៏ដោយ ការពិភាក្សានេះត្រូវគោរពទៅតាមគោលការណ៍ទូទៅមួយចំនួនដូចខាងក្រោម៖

-ការផ្តល់យោបល់ត្រូវផ្អែកលើភស្តុតាងជាក់លាក់ ដែលដកស្រង់ចេញពីការសង្កេតការបង្រៀន និងរៀន។

-ការផ្តល់យោបល់ត្រូវតែបញ្ជាក់ឲ្យច្បាស់ពីចំណុចសំខាន់ត្រូវកែលម្អ និងត្រូវអមដោយគំនិតអាចសាកល្បងបាន។

ឧ. បើសិនខ្ញុំបង្រៀន ខ្ញុំនឹង...

-ការពិភាក្សាត្រូវផ្តោតតែទៅលើការកែលម្អការបង្រៀន និងរៀន ការរិះគន់ទៅលើអ្នកឡើងបង្រៀនត្រូវបានហាមឃាត់។

-របាយការណ៍នៃការពិភាក្សាត្រូវរក្សាទុកនៅការិយាល័យសិក្សា។ ប្រធានក្រុមសិក្សាស្រាវជ្រាវមេរៀនត្រូវចែករបាយការណ៍នេះដល់ក្រុមផងដែរ។

**ឧបករណ៍សម្រាប់ប្រើក្នុងការពិភាក្សាក្រោយបង្រៀនចប់៖**

លេខាកត់ត្រាត្រូវកត់ត្រារាល់ការពិភាក្សាទាំងអស់ ដោយតម្រូវឲ្យប្រើនូវឧបករណ៍កត់ត្រានៃការពិភាក្សាក្រោយពេលបង្រៀនចប់។ កំណត់ត្រានេះត្រូវរក្សាទុកនៅសាលា ដើម្បីរៀបចំធ្វើរបាយការណ៍ និងដើម្បីឲ្យមើលឃើញពីការរីកចម្រើននៃការកែលម្អការបង្រៀន និងរៀន ព្រមទាំងការប្រែប្រួលគុណភាពនៃការពិភាក្សាក្នុងរយៈពេលមួយឆ្នាំសិក្សា។

**៤. ការធ្វើសកម្មភាពកែលម្អបន្ត (Action)**

នេះជាពេលត្រូវអនុវត្តនូវអ្វីដែលបានរៀនពីការសិក្សាស្រាវជ្រាវមេរៀនក្នុងដំណាក់កាលមុនៗមក ដោយក្នុងដំណាក់កាលនេះ សមាជិកនៃក្រុមសិក្សាស្រាវ-ជ្រាវមេរៀនម្នាក់ៗ ទោះបីជាអ្នកបង្រៀនក្តី មិនបង្រៀនក្តី ត្រូវបានលើកទឹកចិត្តឲ្យកែលម្អការងាររបស់ខ្លួនជាបន្ត។ ការសិក្សាអំពីការបង្រៀនត្រូវរួមបញ្ចូលទាំងវិធីសាស្ត្របង្រៀនដែលបានពិភាក្សា និងកែលម្អ ដើម្បីធានាប្រសិទ្ធភាពការរៀនរបស់សិស្ស។ ដូចនេះគ្រូត្រូវសាកល្បងនូវអ្វីដែលបានរៀនពីការសិក្សាស្រាវជ្រាវមេរៀន។ មុនពេលបង្រៀនត្រូវ

ចាំចំណុចដែលបានពិភាក្សា និងបានសន្និដ្ឋានក្នុងការពិភាក្សា និងធ្វើឲ្យការបង្រៀនរបស់គ្រូកាន់តែប្រសើរឡើង។

**ការណែនាំសម្រាប់នាយកសាលា:** សម្រាប់នាយកសាលាគរុកោសល្យនេះជាបរិយាកាសល្អមួយ ដើម្បីវាយតម្លៃជាវិជ្ជមានលើការកែលម្អការបង្រៀនតាមរយៈការសិក្សាស្រាវជ្រាវមេរៀន ដោយនាយកសាលាត្រូវកែទម្លាប់របស់គ្រូឧទ្ទេស និងលើកទឹកចិត្តឲ្យពួកគេហ៊ានពិភាក្សាផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមក និងយកលទ្ធផលទាំងនោះមកធ្វើការវាយតម្លៃគ្រូឧទ្ទេស។ ការធ្វើបែបនេះនឹងបង្កើតឲ្យមាននូវសកម្មភាពសហការគ្នាព្រមទាំងការប្រកួតប្រជែងគ្នារវាងគ្រូឧទ្ទេសនិងគ្រូឧទ្ទេស ដើម្បីកែលម្អការបង្រៀន។

**ការងារត្រូវធ្វើបន្ត:** ប្រសិនបើក្រុមសិក្សាស្រាវជ្រាវមេរៀនបានអនុវត្តដំណើរការទាំងអស់ដូចបានបរិយាយខាងលើហើយ ត្រូវបន្តធ្វើផែនការសម្រាប់អនុវត្តវដ្តក្រោយៗទៀត។ ត្រូវប្រជុំគ្នាដើម្បីជ្រើសរើសអ្នកត្រូវបង្រៀនបន្ត ហើយណែនាំឲ្យគាត់រៀបចំមេរៀនរបស់គាត់។

## ឃ. គន្លឹះដើម្បីធ្វើឲ្យការសិក្សាស្រាវជ្រាវមេរៀនមានប្រសិទ្ធភាព

ដើម្បីឲ្យការសិក្សាស្រាវជ្រាវមេរៀនមានប្រសិទ្ធភាព យើងគួរគប្បីយកចិត្តទុកដាក់លើចំណុចមួយចំនួនដូចខាងក្រោម៖

### ១. ការសម្របសម្រួលដើម្បីឲ្យការពិភាក្សាទទួលបានគុណភាពល្អ

ក្នុងការពិភាក្សាក្រោយពេលបង្រៀនចប់ គ្រូប្រហែលជាមានការភ្ញាក់ផ្អើលជាមួយនឹងអនុសាសន៍ ក៏ដូចជាសំណូមពរផ្សេងៗដែលលើកឡើងដោយសហការី ក្នុងការកែលម្អការបង្រៀន និងរៀន។ ទោះជាយ៉ាងណាក៏ដោយ បើលោកគ្រូអ្នកគ្រូមានបំណងកែលម្អគុណភាពនៃការពិភាក្សា ត្រូវពិនិត្យមើលអនុសាសន៍ទាំងនោះជាមុនសិនថា៖

-មានប្រយោជន៍ទាំងអ្នកបង្រៀន ទាំងអ្នកចូលរួមទាំងអស់ផង។

-អាចអនុវត្តបានទាំងមេរៀនដែលបង្រៀន ទាំងមេរៀនផ្សេងៗទៀត។

-នាំឲ្យមានការពិភាក្សាយ៉ាងសកម្មនៅក្នុងចំណោមអ្នកចូលរួមទាំងអស់។

ខាងក្រោមនេះ ជាប្រភេទអនុសាសន៍ និងសំណូមពរដែលបានផ្តល់នៅក្នុងការពិភាក្សាក្រោយពីបង្រៀនចប់។

## តារាងទី៥៖ ប្រភេទនៃអនុសាសន៍ដែលបានផ្តល់ក្នុងការពិភាក្សា ក្រោយពីការបង្រៀនចប់

| | ប្រភេទ | កំណត់ចំណាំ |
|---|---|---|
| ១ | **ការទិទៀន**<br>អនុសាសន៍ដែលរកឃើញពីកំហុសរបស់គ្រូបង្រៀន និងការបង្រៀនរបស់គាត់ ដោយគ្មានយោបល់ដើម្បីផ្លាស់ប្តូរ និងសំណូមពរដើម្បីស្តាបនា | អនុសាសន៍ទាំងនេះគួរត្រូវជៀសវាង ព្រោះវានឹងធ្វើឲ្យគ្រូបាក់ទឹកចិត្ត និងមិនបង្រៀនលើកក្រោយទៀត |
| ២ | **សំណូមពរលើវិធីសាស្ត្របង្រៀន**<br>អនុសាសន៍ទៅលើការបង្រៀន ដូចជា តើត្រូវធ្វើពិសោធន៍ដូចម្តេច? គ្រូបង្រៀនពីអ្វីនិងបង្រៀនយ៉ាងដូចម្តេច? តើសកម្មភាពអ្វីត្រូវដាក់បញ្ចូល? មាន ឬមិនមានយោងទៅដល់របៀបរៀនរបស់សិស្ស? | ការពិភាក្សានឹងកាន់តែស៊ីជម្រៅទៅលើខ្លឹមសារ និងប្រធានបទ<br>↑↓<br>ការពិភាក្សានឹងបានផ្តល់គំនិតល្អៗ ដល់គ្រូបង្រៀនផ្សេងៗជាច្រើនទៀត |
| ៣ | **ការវាយតម្លៃអំពីភាពសមស្របនៃការបង្រៀន**<br>អនុសាសន៍ទៅលើភាពសមស្របនៃការបង្រៀន ដោយផ្អែកលើការសង្កេតសិស្ស និងលំនាំនៃការរៀនរបស់ពួកគេ ដូចជាការលំបាក ការភាន់ច្រឡំ ការទាញសេចក្តីសន្និដ្ឋាន ការប្រាស្រ័យទាក់ទងរបស់ពួកគេ ។ល។ | |
| ៤ | **ការវិភាគអំពីរចនាសម្ព័ន្ធមេរៀន**<br>អនុសាសន៍លើរចនាសម្ព័ន្ធនិងប្លង់មេរៀន ដូចជាទំនាក់ទំនងរវាងគោលបំណង សំណួរ សកម្មភាព ការសន្និដ្ឋាន ទំនាក់ទំនងរវាងមេរៀននេះនឹងមេរៀនមុន ។ល។ | |
| ៥ | ការផ្តល់ទស្សនទានពីចំណេះដឹងស៊ីជម្រៅ (កែលម្អស៊ីជម្រៅ)<br>អនុសាសន៍អំពីកម្រិតនៃចំណេះដឹងស៊ីជម្រៅ ដូចជាថាតើយើងយល់ឃើញយ៉ាងដូចម្តេចចំពោះមេរៀននេះតាមទស្សនវិស័យគោលវិធីសិស្សមជ្ឈមណ្ឌល ដោយផ្អែកលើទស្សនវិជ្ជាអប់រំដែលយើងបានពិនិត្យលើការបង្រៀននិងរៀនក្នុងម៉ោងបង្រៀននេះ | |

ប្រភព: ក្រសួង អយក, (២០១១)

ប្រភេទនៃអនុសាសន៍ទាំងប្រាំខាងលើនេះ មិនបានបង្ហាញពីកម្រិតនៃអនុសាសន៍ ឬទំនាក់ទំនងល្អអាក្រក់នោះទេ ជាពិសេសប្រភេទ ២ដល់៥ ហើយទាំងអស់នេះ គឺមានសារៈសំខាន់ដូចគ្នា។ ប្រសិនបើអនុសាសន៍ស្ទើរតែទាំងអស់ស្ថិតនៅក្នុងប្រភេទ ២ នោះលទ្ធផលនៃការពិភាក្សាប្រហែលជាមានប្រយោជន៍សម្រាប់តែមេរៀនដដែលនៅឆ្នាំក្រោយប៉ុណ្ណោះ។ បើអនុសាសន៍ផ្តោតតែទៅលើទស្សនវិជ្ជាអប់រំដូចនៅប្រភេទ ៥ នោះការពិភាក្សានឹងមានភាពអរូបីខ្លាំង ហើយអ្នកចូលរួមប្រហែលជាមិនយល់ច្បាស់ពីរបៀបដែលពួកគេអាចកែលម្អគុណភាពនៃការបង្រៀនបានទេ។

ជាបទពិសោធ អនុសាសន៍ភាគច្រើនស្ថិតនៅប្រភេទ២។ អ្នកសង្កេតភាគច្រើនតែងគិតថា ការពិភាក្សានេះមិនមែនសម្រាប់ខ្ញុំទេ គឺសម្រាប់គ្រូឡើងបង្រៀនដើម្បីកែលម្អការបង្រៀនរបស់គាត់តែប៉ុណ្ណោះ។ ដូចនេះអ្នកសង្កេតទាំងនោះគិតថាពួកគាត់មិនទទួលបានផលប្រយោជន៍អ្វីទាំងអស់ពីការពិភាក្សាគ្នានេះ។ តែការរៀនសូត្រពីគ្នាទៅវិញទៅមកមានប្រយោជន៍ដល់គ្រូទាំងអស់ដែលបានចូលរួម។

**២. របៀបដោះស្រាយការខ្វែងគំនិតគ្នារបស់អ្នកចូលរួម**

គន្លឹះសម្រាប់ដោះស្រាយការខ្វែងគំនិតគ្នា ត្រូវពឹងផ្អែកលើទំហំដែលយើងបានសង្កេតពីសកម្មភាពសិស្ស។ ការធ្វើឲ្យមានភាពយុត្តិធម៌ដោយផ្អែកទៅលើការសង្កេតសិស្សនៅចំពោះមុខជាការសំខាន់។ សូមពិនិត្យមើលគំនូសខាងក្រោម៖

រូបភាពទី៦៖ គំនូសតាងលំនាំគំរូសម្របសម្រួលការខ្វែងគំនិតដែលមានប្រសិទ្ធភាព




ប្រភព: ក្រសួង អយក. (២០១១)

### ៣. កាលវិភាគនៃការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន

ក្រុមសិក្សាស្រាវជ្រាវមេរៀននីមួយៗ ត្រូវឆ្លងកាត់វដ្តនៃការសិក្សាស្រាវជ្រាវមេរៀននៅក្នុងឆមាសនីមួយៗ។ សាលារៀននីមួយៗអាចចាប់ផ្តើមធ្វើការសិក្សាស្រាវជ្រាវមេរៀនមួយក្រុមសម្រាប់មួយមុខវិជ្ជា ហើយពង្រីកទៅមុខវិជ្ជាដទៃទៀត ដោយធ្វើជាជំហានតូចៗនិងត្រូវបន្តទៅមុខជានិច្ច។ ការចាប់ផ្តើមធ្វើការងារធំភ្លាមៗពេកនឹងធ្វើឲ្យយើងគ្រប់គ្នាធុញទ្រាន់ ហើយលទ្ធផលនៃសកម្មភាពរបស់ក្រុមសិក្សាស្រាវជ្រាវមេរៀននឹងមិនបានល្អទេ។

ជាមួយគ្នានេះដែរ ការរៀបចំកាលវិភាគសម្រាប់អនុវត្តការសិក្សាស្រាវជ្រាវមេរៀនក៏មានសារៈសំខាន់ផងដែរ។ កាលវិភាគនេះអាចរៀបចំសម្រាប់មួយឆ្នាំសិក្សា ឬអាចធ្វើការផ្លាស់ប្តូរទៅតាមថ្ងៃឈប់សម្រាក ថ្ងៃបុណ្យជាតិ ឬតាមប្រតិទិនរបស់សាលា។ ពេលខ្លះ ផែនការដែលបានគ្រោងទុកត្រូវបានផ្លាស់ប្តូរនៅពាក់កណ្តាលឆមាស ដោយសារមានបញ្ហាកាលវិភាគជាន់គ្នា។

តារាងទី៦៖ ឧទាហរណ៍ការរៀបចំកាលវិភាគសម្រាប់ការសិក្សាស្រាវជ្រាវមេរៀន

| **ឆមាសទី១** | **វិច្ឆិកា** | **ធ្នូ** | **មករា** | **កុម្ភៈ** | **មីនា** |
|---|---|---|---|---|---|
| **ឆមាសទី២** | **មេសា** | **ឧសភា** | **មិថុនា** | **កក្កដា** | **សីហា** |
| សប្តាហ៍ទី១<br>សប្តាហ៍ទី២<br>សប្តាហ៍ទី៣ | -បង្កើតក្រុមសិក្សាស្រាវជ្រាវមេរៀន (វិច្ឆិកា)<br>-ពិនិត្យមើលឡើងវិញនូវផែនការសិក្សាស្រាវជ្រាវមេរៀន (មេសា) | គ្រូដែលបានចាត់តាំងត្រូវរៀបចំកិច្ចតែងការបង្រៀន | គ្រូដែលបានចាត់តាំងត្រូវកែលម្អកិច្ចតែងការ | គ្រូដែលបានចាត់តាំងបញ្ចប់កិច្ចតែងការបង្រៀន និងរៀបចំសម្រាប់ការបង្រៀន | នាយក/នាយិកាធ្វើរបាយការណ៍នៃការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនប្រចាំឆមាស |
| សប្តាហ៍ទី៤ | **[ផែនការ]**<br>ប្រជុំរៀបចំមេរៀនលើកទី១: រៀបចំកាលវិភាគការសិក្សាស្រាវជ្រាវមេរៀនប្រចាំឆមាស | **[ផែនការ]**<br>ប្រជុំរៀបចំមេរៀនលើកទី២: ការពិនិត្យកិច្ចតែងការបង្រៀនពង្រាងលើកទី១ | **[ផែនការ]**<br>ប្រជុំរៀបចំមេរៀនលើកទី៣: ការពិនិត្យកិច្ចតែងការពង្រាងលើកទី២ (ឧ.តាមរយៈការបង្រៀនសាកល្បង) | **[អនុវត្ត]**<br>ការបង្រៀន និងការសង្កេត<br>**[ត្រួតពិនិត្យ]**<br>ការពិភាក្សាក្រោយបង្រៀនចប់ | ធ្វើបទបង្ហាញ និងការពិភាក្សាទៅលើរបាយការណ៍ |

ប្រភព: ក្រសួង អយក, (២០១១)

### ៤. ការធ្វើរបាយការណ៍ស្តីពីការសិក្សាស្រាវជ្រាវមេរៀន

សាលារៀននីមួយៗត្រូវធ្វើរបាយការណ៍សង្ខេបស្តីពីការរីកចម្រើន និងបញ្ហាទាំងឡាយ ដែលកើតមាននៅក្នុងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនប្រចាំឆមាសនីមួយៗ។ របាយការណ៍អាចធ្វើយ៉ាងងាយ ដោយគ្រាន់តែប្រមូលចងក្រងកំណត់ត្រាដែលបានធ្វើនៅក្នុងដំណាក់កាលនីមួយៗ នៃសកម្មភាពការសិក្សាស្រាវជ្រាវមេរៀនដែលក្នុងនោះមានកំណត់ត្រានៃការពិភាក្សា កែលម្អក្រោយពេលបង្រៀនចប់ និងកំណត់ត្រាអំពីការសិក្សាមេរៀន។ សាលាក៏អាចប្រើរបាយការណ៍នេះជាភស្តុតាងសម្រាប់បង្ហាញពីការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនផង និងសម្រាប់ពិនិត្យមើលការរីកចម្រើននៃការអភិវឌ្ឍការបង្រៀន និងរៀនពេញមួយឆ្នាំសិក្សាផងដែរ។

### ៥. ការណែនាំសម្រាប់នាយកសាលា និងការងាររដ្ឋបាល

ភាពជាអ្នកដឹកនាំរបស់នាយកសាលាគឺជាគន្លឹះមួយដ៏សំខាន់ ដើម្បីទទួលបានជោគជ័យក្នុងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន ព្រោះថានាយកសាលាមានលទ្ធភាពច្រើនក្នុងការពិភាក្សាជាមួយនាយករង ប្រធានក្រុមបច្ចេកទេស ប្រធានការិយាល័យសិក្សា ដើម្បីបែងចែកតួនាទីគ្នា ដូចជា ថាអ្នកណាជាអ្នកទាក់ទងសមាជិកក្រុមសិក្សាស្រាវជ្រាវមេរៀនឲ្យមកប្រជុំ? អ្នកណាទទួលដាក់ថ្ងៃ ម៉ោងពេល និងទីកន្លែងប្រជុំ? ចាត់តាំងអ្នកណាជាអ្នកឡើងបង្រៀន? អ្នកណាជាអ្នកសម្របសម្រួល? អ្នកណាជាលេខាកត់ត្រា?

ជាទូទៅ គេត្រូវចំណាយពេលវេលាច្រើនឆ្នាំដើម្បីឲ្យគ្រូបង្រៀនម្នាក់ៗគិតពីការសិក្សាស្រាវជ្រាវមេរៀនរហូតក្លាយទៅជាទម្លាប់ដដែលៗលើការកែលម្អការបង្រៀន និងរៀន។ នៅពេលចាប់ផ្តើមដំបូង គ្រូភាគច្រើនតែងតែគិតថា ការសិក្សាស្រាវជ្រាវមេរៀនជាការបន្ថែមភារកិច្ច និងធ្វើឲ្យរំខានការងារនិងជីវិតផ្ទាល់ខ្លួនថែមទៀតផង។ បើសិនជាមានការលំបាកក្នុងការបង្រើតវដ្តនៃការសិក្សាស្រាវជ្រាវមេរៀន នាយកសាលាអាចកំណត់សមាជិក ដែលមានចំណាប់ចំណូលចិត្តធ្វើ ឬអាចកាត់បន្ថយចំនួនពេលនៃការអនុវត្តក៏បាន។ អ្វីដែលសំខាន់ គឺត្រូវចាប់ផ្តើមអនុវត្តដោយមិនចាំបាច់រង់ចាំរហូតដល់ពេលមានស្ថានភាពល្អណាមួយទើបបង្កើតការសិក្សាស្រាវជ្រាវមេរៀននោះទេ។

តាមរយៈខ្លឹមសារដែលបានលើកយកមកបង្ហាញខាងលើ អ្នកស្រាវជ្រាវអាចសង្ខេបបានថា ការសិក្សាស្រាវជ្រាវមេរៀនជាកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនមួយ ដែលគណៈគ្រប់គ្រងសាលា លោកគ្រូអ្នកគ្រូ និងអ្នកពាក់ព័ន្ធនានាចូលរួមពិភាក្សាគ្នា ដើម្បីជួយឲ្យការបង្រៀនបានល្អប្រសើរ។ ការអនុវត្តកម្មវិធីនេះមាន ៤ ដំណាក់កាលសំខាន់ គឺ

ការរៀបចំមេរៀន (Plan) ការអនុវត្តការបង្រៀននិងការសង្កេត (Do) ការពិភាក្សាកែលម្អលើការបង្រៀន (Check) និងការធ្វើសកម្មភាពកែលម្អការបង្រៀនក្នុងក្រុមរៀងៗ ខ្លួនបន្ទាប់ពីធ្វើការពិភាក្សាកែលម្អក្នុងក្រុមរួច (Action)។ ការសិក្សាស្រាវជ្រាវមេរៀនត្រូវការពេលវេលាយូរអាចបី ឬបួនឆ្នាំ ទើបឃើញលទ្ធផល ពោលគឺមិនអាចទទួលបានលទ្ធផលភ្លាមៗនោះទេ។

ឯកសារពិគ្រោះខាងលើនេះ ពិតជាមានសារៈសំខាន់ណាស់ដល់អ្នកស្រាវជ្រាវក្នុងការយល់កាន់តែច្បាស់ពីខ្លឹមសារនៃប្រធានបទស្រាវជ្រាវនេះ។ អ្នកស្រាវជ្រាវសង្ឃឹមថា ឯកសារទាំងនេះនឹងជួយជាប្រយោជន៍ក្នុងការវិភាគទិន្នន័យ ដែលទទួលបានពីភាគសំណាក និងជាទុនមួយយ៉ាងសំខាន់ក្នុងការកសាងឧបករណ៍ស្រាវជ្រាវ និងក្នុងការសរសេររៀបរៀងខ្លឹមសារតាមផ្នែកនីមួយៗបានល្អប្រសើរជាពុំខាន។

# ជំពូកទី ៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

ក្នុងដំណើរការនៃការស្រាវជ្រាវលើប្រធានបទស្តីពី **"ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង"** នេះ អ្នកស្រាវជ្រាវបានកំណត់ការស្រាវជ្រាវ ដោយផ្តោតទៅលើ វិធីសាស្ត្រនៃការស្រាវជ្រាវ ការជ្រើសរើសភាគសំណាក ការកសាងឧបករណ៍ស្រាវជ្រាវ ការប្រមូលទិន្នន័យ និងការវិភាគទិន្នន័យដូចខាងក្រោមនេះ៖

## ៣.១. វិធីស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទនេះ អ្នកការស្រាវជ្រាវបានប្រើវិធីស្រាវជ្រាវតាមបែបបរិមាណវិស័យផង និងតាមបែបគុណវិស័យផង។ ចំពោះការស្រាវជ្រាវតាមបែបបរិមាណវិស័យមានគោលបំណងសិក្សាទៅលើការយល់ដឹង និងការអនុវត្តការសិក្សាស្រាវជ្រាវនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង ដើម្បីចង់ដឹងពីចំនួនគ្រូឧទ្ទេសដែលបានយល់ដឹង និងចូលរួមអនុវត្តការសិក្សាស្រាវជ្រាវមេរៀន។ ចំណែកឯការស្រាវជ្រាវតាមបែបគុណវិស័យមានគោលបំណងសិក្សាលើទស្សនៈយល់ឃើញ បញ្ហាប្រឈម និងដំណោះស្រាយផ្សេងៗ ក្នុងដំណើរការអនុវត្តកម្មវិធីនេះ ដើម្បីឲ្យអ្នកស្រាវជ្រាវបានដឹងច្បាស់ពីឫសគល់ និងហេតុផលទាំងឡាយ និងទស្សនៈផ្ទាល់ខ្លួនពីអ្នកចូលរួមនៅក្នុងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែងខាងលើនេះ។

## ៣.២. ការជ្រើសរើសភាគសំណាក

ភាគសំណាកដែលត្រូវបានយកមកធ្វើការសិក្សាស្រាវជ្រាវ សម្រាប់ប្រធានបទនេះ គឺអ្នកស្រាវជ្រាវបានជ្រើសរើសតាមគោលដៅដែលបានកំណត់ទុក ដោយសំដៅយកតែភាគសំណាកណា ដែលអ្នកស្រាវជ្រាវពិតជឿជាក់ថា ភាគសំណាកទាំងនោះអាចផ្តល់នូវទិន្នន័យទាំងឡាយបានជាក់លាក់ ច្បាស់លាស់ និងអាចឆ្លើយតបទៅនឹងប្រធានបទនេះបាន។ ដូចនេះភាគសំណាកដែលអ្នកស្រាវជ្រាវយល់ថា អាចផ្តល់បាននូវទិន្នន័យទាំងនោះរួមមាន៖ តំណាងមន្ទីរអប់រំ យុវជន និងកីឡា ចំនួន ០១ រូប នាយករងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន ០២ រូប គ្រូឧទ្ទេសបង្គោល ចំនួន ០២ រូប និងលោកគ្រូអ្នកគ្រូនៅមជ្ឈមណ្ឌល គរុកោសល្យភូមិភាគស្ទឹងត្រែងចំនួន ១៨ រូប សរុបទាំងអស់ ២៣ រូប ។ ភាគសំណាកដែលបានជ្រើសរើសទាំងអស់នេះ សុទ្ធតែជាអ្នកដែលបាន

ចូលរួមយ៉ាងសកម្មនៅក្នុងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង ហើយអ្នកខ្លះទៀតបានទៅទទួលការបំប៉នការសិក្សាស្រាវជ្រាវមេរៀនជាច្រើនលើកពីក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយដៃគូ ដូចជា JICA VVOB និងCCT ជាដើម។ ដោយមូលហេតុនេះហើយ ទើបបានជាអ្នកសិក្សាស្រាវជ្រាវជឿជាក់ថា ភាគសំណាកទាំងនេះពិតជាអាចផ្តល់នូវទិន្នន័យ ដែលទាក់ទងទៅនឹងប្រធានបទខាងលើយ៉ាងពិតប្រាកដ ។

## ៣.៣. ឧបករណ៍ស្រាវជ្រាវ

ក្នុងការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានបង្កើតជាកម្រងសំណួរឡើង ដោយផ្អែកលើវត្ថុបំណងនៃការស្រាវជ្រាវ។ កម្រងសំណួរនេះមានទាំងសំណួរត្រូវសរសេរបំពេញ សំណួរគូសរង្វង់ជុំវិញលេខ ដែលសមស្របនឹងកម្រិតយល់ដឹងរបស់សំណាក និង សំណួរគូសសញ្ញាធីក (✓) ក្នុងប្រអប់។ ជារួម កម្រងសំណួរដែលបានបង្កើតឡើងនេះ មានបួនផ្នែកសំខាន់ គឺ ផ្នែកទីមួយជាការយល់ដឹងលើការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន ដែលបានផ្តោតទៅលើបទពិសោធក្នុងការចូលរួមវគ្គបំប៉នស្តីពីការសិក្សាស្រាវជ្រាវមេរៀន ការផ្តល់និយមន័យ និងគោលបំណងនៃការសិក្សាស្រាវជ្រាវមេរៀន ការគូសរង្វង់ជុំវិញលេខដែលបញ្ជាក់ពីកម្រិតយល់ដឹងរបស់សំណាក និងការគូសលើខ្លឹមសារដែលសំណាកគិតថាយល់ច្បាស់និងមិនទាន់យល់ច្បាស់។ សម្រាប់ផ្នែកទីពីរគឺជាការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន ដែលឆ្លុះបញ្ចាំងឲ្យឃើញពីការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង បង្ហាញពីកម្រិតនៃការចូលរួមរបស់ភាគសំណាក កម្រិតនៃការយល់ស្របរបស់សំណាកលើព័ត៌មានដែលបានផ្តល់ជូនក្នុងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន ការសរសេររៀបរាប់ពីសកម្មភាពសំខាន់ៗដែលបានអនុវត្តនៅក្នុងសាលា សរសេរបំពេញខ្លឹមសារ ឬសកម្មភាពដែលសំណាកពេញចិត្តនិងងាយអនុវត្ត និងការគូសសញ្ញាធីកនៅត្រង់ចំណុចដែលសំណាកយល់ថាងាយអនុវត្ត និងយកទៅអនុវត្ត ឬខ្វែងត្រង់ចំណុចដែលគិតថាពិបាកអនុវត្ត និងមិនយកទៅអនុវត្ត។ ចំណែកផ្នែកទីបី គឺស្តីពីបញ្ហាប្រឈមនិងដំណោះស្រាយ ដោយតម្រូវឲ្យសំណាកលើកឡើងពីបញ្ហាប្រឈម និងដំណោះស្រាយ ដែលអាចកើតមានឡើងក្នុងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅក្នុងសាលា ដូចជា ការអនុវត្តផែនការការចូលរួម ការផ្តល់សម្ភារៈ ការគាំទ្រពីសាលា បញ្ហាប្រឈមផ្ទាល់ខ្លួន ឬនិងក្រុមមុខវិជ្ជា ឬនិងសាលារៀនទាំងមូលក្នុងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន។ ចំណែកផ្នែកទីបួននិយាយអំពីទស្សនៈយល់ឃើញជារួមរបស់ភាគសំណាក មានជាអាទិ៍ ទស្សនៈយល់

ឃើញលើការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនក្នុងសាលា ការជួយអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ការជួយអភិវឌ្ឍការបង្រៀននិងរៀន ការជួយអភិវឌ្ឍវិស័យអប់រំ នៅកម្ពុជា គំនិតផ្តួចផ្តើមក្នុងការធ្វើឲ្យការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅក្នុងសាលា កាន់តែប្រសើរឡើង និងសំណូមពរផ្សេងៗ។ កម្រងសំណួរដែលអ្នកស្រាវជ្រាវបានបង្កើតឡើងដូចបានរៀបរាប់ខាងលើនេះ ត្រូវបានត្រួតពិនិត្យភាពត្រឹមត្រូវយ៉ាងហ្មត់ចត់ និងមានការឯកភាពពីគ្រូដឹកនាំ។

ទិន្នន័យដែលប្រមូលបានមក គឺជាព័ត៌មានសម្រាប់គាំទ្រដល់ការសិក្សាស្រាវជ្រាវមួយនេះ និងអាចជាព័ត៌មានសម្រាប់ដោះស្រាយបញ្ហាដែលកើតមានឡើងក្នុងការអនុវត្តការសិក្សាស្រាវជ្រាវនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង។ ដើម្បីប្រមូលបាននូវទិន្នន័យដ៏ជាក់លាក់ និងជឿជាក់បាន វាជាការចាំបាច់ខ្លាំងណាស់ក្នុងការបង្កើតនូវឧបករណ៍ស្រាវជ្រាវនេះឡើង សម្រាប់ប្រមូលទិន្នន័យពីភាគសំណាកដែលបានកំណត់ជ្រើសរើសរួច ក្នុងគោលបំណងដើម្បីស្វែងរកឱ្យឃើញច្បាស់ពីកម្រិតយល់ដឹងជាក់ស្តែងរបស់ពួកគាត់ បញ្ហាប្រឈម និងដំណោះស្រាយនានា ដើម្បីឲ្យគណៈគ្រប់គ្រង និងអ្នកពាក់ព័ន្ធឆ្លើយតបបានត្រឹមត្រូវទៅ នឹងតម្រូវការជាក់ស្តែងរបស់ពួកគាត់ ព្រមទាំងរកឲ្យឃើញនូវទស្សនៈយល់ឃើញនានារបស់គ្រូឧទ្ទេស នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង ដើម្បីជាត្រីវិស័យចង្អុលបង្ហាញផ្លូវ ឆ្ពោះទៅរកការអនុវត្តប្រកបដោយប្រសិទ្ធភាព និងមានចីរភាព។

## ៣.៤. ការប្រមូលទិន្នន័យ

ក្នុងការស្រាវជ្រាវប្រធានបទខាងលើ អ្នកស្រាវជ្រាវបានប្រមូលទិន្នន័យនិងព័ត៌មានមួយចំនួនពីសៀវភៅ និងឯកសារផ្សេងៗ និងទិន្នន័យដែលបានមកតាមរយៈកម្រងសំណួរ។ ចំពោះទិន្នន័យដែលបានមកពីសៀវភៅនិងឯកសារ អ្នកស្រាវជ្រាវបានដកស្រង់នូវខ្លឹមសារដែលទាក់ទងនឹងប្រធានបទ ដើម្បីយកធ្វើជាឯកសារពិគ្រោះក្នុងការសរសេររៀបរៀងអត្ថបទស្រាវជ្រាវលើកនេះ ដោយភាគច្រើនមាននៅក្នុងសេចក្តីផ្តើម និងរំឭកទ្រឹស្តី ហើយបានសរសេររៀបរៀងទៅតាមលំដាប់លំដោយខ្លឹមសារ។ ឯកសារ និងសៀវភៅទាំងនេះមានទាំង ភាសាខ្មែរ និងភាសាអង់គ្លេស ដែលអ្នកស្រាវជ្រាវរកបានពីបណ្ណាល័យ កន្លែងបម្រើការងារ និងទាញយកពីអ៊ីនធឺណែត។

ដោយឡែក ចំពោះទិន្នន័យដែលបានមកតាមរយៈកម្រងសំណួរវិញ អ្នកស្រាវជ្រាវបានអនុវត្តតាមជំហានបន្តបន្ទាប់។ ដើម្បីឱ្យការចុះប្រមូលទិន្នន័យមានលក្ខណៈផ្លូវការ និងដើម្បីឱ្យដំណើរការប្រមូលទិន្នន័យមានភាពរលូនល្អនោះ អ្នក

ស្រាវជ្រាវបានយកលិខិតសុំអនុញ្ញាតពីវិទ្យាស្ថានជាតិអប់រំទៅសុំជួបជាមួយថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង និងគណៈគ្រប់គ្រងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង ដើម្បីជម្រាបពីគោលបំណង និងសុំអនុញ្ញាតធ្វើការប្រមូលទិន្នន័យនៅទីតាំង និងភាគសំណាកដែលបានកំណត់ទុករួចជាស្រេច។ អ្នកស្រាវជ្រាវបានស្នើសុំដល់ភាគសំណាកឲ្យបំពេញកម្រងសំណួរតាមពេលកំណត់ជាក់លាក់ ដោយក្នុងនោះដែរ អ្នកស្រាវជ្រាវបានពន្យល់ណែនាំពីរបៀបបំពេញកម្រងសំណួរជារួមក្នុងសាលប្រជុំដើម្បីឲ្យប្រាកដប្រជាថាទិន្នន័យដែលនឹងទទួលបានមកគឺជាទិន្នន័យល្អ ប្រកបដោយភាពជាក់លាក់ និងជឿទុកចិត្តបាន សម្រាប់គាំទ្រដល់ប្រធានបទស្រាវជ្រាវខាងលើ។ បន្ទាប់មក អ្នកស្រាវជ្រាវបានប្រមូលកម្រងសំណួរ រួចយកទិន្នន័យក្នុងកម្រងសំណួរមករៀបរៀងសរសេរតាមវត្ថុបំណងនៃការស្រាវជ្រាវ និងតាមលំដាប់លំដោយខ្លឹមសារ។

សូមបញ្ជាក់ថា ក្នុងការប្រមូលទិន្នន័យ អ្នកស្រាវជ្រាវបានប្រជុំណែនាំ និងពន្យល់ពីរបៀបបំពេញកម្រងសំណួរ ក្នុងបរិយាកាសស្និទ្ធស្នាលប្រកបដោយភាតរភាព និងបានស្នើសុំភាគសំណាកឲ្យបំពេញតាមភាពជាក់ស្ដែង តាមខ្លឹមសារនីមួយៗ ដោយមិនតម្រូវឲ្យដាក់ឈ្មោះ ឬបង្ហាញព័ត៌មានដែលនាំឲ្យគេស្គាល់ពីអត្តសញ្ញាណរបស់ភាគសំណាកឡើយ ដោយហេតុថាអ្នកស្រាវជ្រាវជានាយកនៃគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀនមួយនេះ ដើម្បីចៀសវាងការមានឥទ្ធិពលទៅលើការបំពេញកម្រងសំណួរ។ អាស្រ័យហេតុនេះ អ្នកស្រាវជ្រាវសូមបញ្ជាក់អះអាងថា ទិន្នន័យដែលលោកគ្រូអ្នកគ្រូបានបំពេញក្នុងកម្រងសំណួរជាគំនិតផ្ទាល់ខ្លួនរបស់ពួកគាត់ពិតប្រាកដ គឺមិនស្ថិតក្រោមឥទ្ធិពល ឬការបង្គាប់បញ្ជាពីអ្នកស្រាវជ្រាវដែលជានាយកនៃគ្រឹះស្ថាននេះឡើយ។

## ៣.៥. ការវិភាគទិន្នន័យ

ដោយសារការស្រាវជ្រាវប្រធានបទខាងលើនេះ ជាការស្រាវជ្រាវតាមបែបបរិមាណវិស័យផង និងតាមបែបគុណវិស័យផងនោះ អ្នកស្រាវជ្រាវបានធ្វើការវិភាគទិន្នន័យ ដែលទទួលបានមកពីកម្រងសំណួរតាមបែបបរិមាណវិស័យនិងគុណវិស័យដែរ។ ចំពោះការវិភាគតាមបែបបរិមាណវិស័យ អ្នកស្រាវជ្រាវបានយកទិន្នន័យពីកម្រងសំណួរមករៀបចំតាមលំដាប់លំដោយខ្លឹមសារ ដោយផ្ដោតជាសំខាន់លើផ្នែកទីមួយ និងទីពីរនៃកម្រងសំណួរ ដើម្បីដឹងពីចំនួន និងកម្រិតនៃការយល់ដឹង និងការអនុវត្តរបស់គ្រូឧទ្ទេសនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែងបានច្បាស់លាស់។ អ្នកស្រាវ-ជ្រាវបានធ្វើការវិភាគទិន្នន័យរក ប្រេកង់ ដោយប្រើកម្មវិធី SPSS ដើម្បីឲ្យការវិភាគទទួលបានការជឿទុកចិត្តខ្ពស់ និងប្រើកម្មវិធី MS Excel ជាជំនួយក្នុងការធ្វើតារាងសង់

ក្រាប (Chart)។ លទ្ធផលនៃការវិភាគដែលទទួលបានតាមរយៈ Chart ត្រូវបានវិភាគបកស្រាយហេតុផល ដោយឈរលើមូលដ្ឋានទទ្បីករណ៍ជាក់ស្តែង។

ដោយឡែកសម្រាប់ការវិភាគតាមបែបគុណវិស័យវិញ អ្នកស្រាវជ្រាវបានផ្តោតជាចម្បងលើផ្នែកទីបី និងទីបួន ដែលលើកឡើងពីបញ្ហាប្រឈម និងទស្សនៈយល់ឃើញនានារបស់សំណាក ពាក់ព័ន្ធនឹងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅទីនោះ។ ទិន្នន័យដែលបានមកពីសំណាកតាមរយៈកម្រងសំណួរត្រូវបានប្រមូលផ្តុំគំនិត ដោយទិន្នន័យណាដែលដូចគ្នាត្រូវដាក់ជាមួយគ្នាយកជាគំនិតរួមតាមប្រភេទខ្លឹមសារ លំដាប់លំដោយខ្លឹមសារ ហើយទាញយកមកវិភាគទៅតាមផ្នែកនីមួយៗ ដើម្បីបង្ហាញឲ្យឃើញពីឫសគល់នៃបញ្ហាប្រឈម និងតម្រូវការជាក់ស្តែង ព្រមទាំងគំនិតយល់ឃើញចំពោះការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនក្នុងវិស័យអប់រំ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង។

# ជំពូកទី ៤
# លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

# ជំពូកទី៤
# លទ្ធផល និងការពិភាក្សា

លទ្ធផលនៃការស្រាវជ្រាវលើប្រធានបទស្តីពី **"ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន នៅខេត្តស្ទឹងត្រែង ករណីសិក្សាៈ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង"** អ្នកស្រាវជ្រាវបានយកទិន្នន័យ ដែលទទួលបានពីកម្រងសំណួរ យកមកសរសេររៀបរៀងជាអត្ថបទទៅតាមជំហាននីមួយៗនៃការសិក្សាមេរៀន ដែលស្តែងឲ្យឃើញពីកម្រិតយល់ដឹង ការអនុវត្ត បញ្ហាប្រឈម និងទស្សនៈយល់ឃើញជារួម។ តែមុននឹងបង្ហាញពីចំណុចទាំងនេះ អ្នកស្រាវជ្រាវសូមលើកយកស្ថានភាពទូទៅ នៃការអនុវត្តការសិក្សាមេរៀននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង មកបង្ហាញជាមុនសិន ដើម្បីជាមូលដ្ឋានដល់ការវិភាគ និងជាការស្វែងយល់ពីបរិបទនៅទីនោះផង។

## ៤.១. ស្ថានភាពទូទៅនៃការសិក្សាមេរៀន

### ៤.១.១. អំពីការចូលរួមវគ្គបំប៉ន

លទ្ធផលពីកម្រោងសំណួរបង្ហាញថាស្ទើរតែ ១០០% នៃភាគសំណាកឆ្លើយថាសាលាពិតជាបានរៀបចំការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន នៅក្នុងសាលាប្រាកដមែន (ក្រាបទី១) ។ ទិន្នន័យនេះបានសបញ្ជាក់ឲ្យឃើញថា ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូសហការបានផ្សព្វផ្សាយការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនបានទូលំទូលាយរហូតដល់សាលាគរុកោសល្យ ហើយក៏បង្ហាញឲ្យឃើញពីឆន្ទៈរបស់គណៈគ្រប់គ្រងសាលា ក្នុងការប្តេជ្ញាចិត្តអនុវត្តកម្មវិធីនេះនៅក្នុងសាលារបស់ខ្លួនផងដែរ។ តាមរយៈសកម្មភាពនេះ អាចនិយាយបានថា ជាជំហានមួយឆ្ពោះទៅរកការពង្រឹងសមត្ថភាពគ្រូ និងធានាប្រសិទ្ធភាពនៃការបង្រៀន ដើម្បីឆ្លើយតបទៅនឹងកំណែទម្រង់វិស័យអប់រំ ដែលនឹងអាចធ្វើឲ្យសម្រេចគោលនយោបាយអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

លទ្ធផលនៃការស្រាវជ្រាវក្នុងផ្នែកនេះ បានបង្ហាញដូចក្រាបខាងក្រោមៈ




ក្រាបទី១: ការចូលរួមវគ្គបំប៉នការសិក្សាស្រាវជ្រាវមេរៀនរបស់គ្រូ

តាមរយៈក្រាបទី១ បង្ហាញឲ្យឃើញថា គ្រូនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែងភាគច្រើន បានឆ្លងកាត់នូវវគ្គបំប៉នស្តីពីការសិក្សាស្រាវជ្រាវមេរៀន (95.70%) ដែលវគ្គបំប៉នទាំងនោះត្រូវបានរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយដៃគូអភិវឌ្ឍនានា។ តែយ៉ាងណាក៏ដោយ នៅមានគ្រូមួយចំនួនតូចទៀត មិនបានទទួលការបំប៉ននៅឡើយ (4.30%)។ ជារួមអាចនិយាយបានថា ក្រសួងអប់រំ យុវជន និងកីឡា ពិតជាមានការយកចិត្តទុកដាក់ខ្លាំងលើការលើកកម្ពស់សមត្ថភាពគ្រូបង្រៀន តាមរយៈការផ្សព្វផ្សាយការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ដើម្បីឆ្លើយតបទៅនឹងកំណែទម្រង់វិស័យអប់រំ។

ផ្អែកលើទិន្នន័យដែលប្រមូលបានពីភាគសំណាក អ្នកចូលរួមភាគច្រើនរហូតដល់ 91.30% អាចឲ្យនិយមន័យនៃការសិក្សាស្រាវជ្រាវមេរៀនបានត្រឹមត្រូវ។ ពួកគាត់ទាំងនោះបានឲ្យនិយមន័យការសិក្សាស្រាវជ្រាវមេរៀន ដែលអ្នកស្រាវជ្រាវបានកំណត់អត្ថន័យជារួមថា ជាដំណើរការអភិវឌ្ឍវិជ្ជាជីវៈរបស់ក្រុមគ្រូបង្រៀនដែលមានមុខវិជ្ជាដូចគ្នា ដើម្បីជួយធ្វើឲ្យការបង្រៀនរបស់ខ្លួនបានល្អប្រសើរឡើង។ ការលើកឡើង

នេះមានខ្លឹមសារប្រហាក់ប្រហែល នឹងទស្សនៈដែលបានលើកបង្ហាញក្នុងជំពូកទី២ របស់អ្នកសក្សាស្រាវជ្រាវជាច្រើនរូបដែរ។

ចំណែក 8.70% នៅពុំទាន់ឆ្លើយបានពេញលេញនៅឡើយ ដោយពួកគាត់បានបញ្ចេញទស្សនៈយល់ឃើញថា ការសិក្សាស្រាវជ្រាវមេរៀន គឺជាការបង្កើតនូវចំណេះដឹងថ្មី ឬ ចំណេះដឹងមានស្រាប់។ ខ្លឹមសារលើកឡើងនេះពុំទាន់មានអ្នកសិក្សាស្រាវជ្រាវណាមួយបានអះអាងបែបនេះនៅឡើយ។ តាមរយៈចម្លើយនេះ ធ្វើឲ្យអ្នកស្រាវជ្រាវហ៊ានសន្និដ្ឋានថា ពួកគាត់នៅពុំទាន់បានយល់ច្បាស់ពីការសិក្សាស្រាវជ្រាវមេរៀននៅឡើយទេ។

ជារួមអ្នកស្រាវជ្រាវអាចទាញសេចក្តីសន្និដ្ឋានបានថា អ្នកចូលរួមអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង ស្ទើរតែទាំងអស់បានយល់ដឹង និងឲ្យនិយមន័យការសិក្សាស្រាវជ្រាវមេរៀនបានក្នុងកម្រិតល្អ។ ចំណែកមួយចំនួនតូចទៀត គណៈគ្រប់គ្រងសាលាគួរយកចិត្តទុកដាក់បំប៉នពួកគាត់ឡើងវិញមុននឹងចាប់ផ្តើមការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅឆ្នាំសិក្សាបន្ទាប់។

ចំពោះគោលបំណងនៃការសិក្សាស្រាវជ្រាវមេរៀនវិញ អ្នកស្រាវជ្រាវរកឃើញថា គ្រូៗមានការយល់ដឹងលើគោលបំណងនៃការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនដូចៗគ្នា ដែលអាចនិយាយជារួមថា គោលបំណងនៃការសិក្សាស្រាវជ្រាវមេរៀនគឺដើម្បីជួយអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនឲ្យកាន់តែល្អប្រសើរឡើង។ ក្នុងន័យបែបនេះ ការសិក្សាស្រាវជ្រាវមេរៀនដើរតួនាទីដ៏សំខាន់ ក្នុងការពង្រឹងសមត្ថភាពបង្រៀនរបស់គ្រូៗ ដែលជាកត្តាជួយធ្វើឲ្យការបង្រៀនរបស់គ្រូបានប្រសើរឡើង ហើយក៏នឹងធ្វើឲ្យការរៀនរបស់សិស្សបានល្អដែរ។ ការជួយអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន (ចំណេះដឹង បំណិន និងឥរិយាបទ) គឺធ្វើឡើងតាមរយៈការចូលរួមចែករំលែកបទពិសោធ និងវិធីសាស្ត្រ ឬល្បិចនៃការបង្រៀន និងការបង្កើតនូវវប្បធម៌រៀនពីគ្នាទៅវិញទៅមក ចេះស្រាវជ្រាវបន្ថែមនូវអ្វីដែលមិនទាន់យល់ច្បាស់ ដែលជាធាតុផ្សំដ៏ល្អ សម្រាប់ជំរុញគ្រូឧទ្ទេសក្នុងក្រុមមុខវិជ្ជាមានឱកាសក្នុងការកែលម្អការបង្រៀនរបស់ខ្លួន ដើម្បីធានាប្រសិទ្ធភាពនៃការបង្រៀន និងរៀន។

សរុបមក ការលើកឡើងខាងលើនេះអាចបញ្ជាក់ថា គ្រូៗមានយល់ដឹងច្បាស់ពីគោលបំណងនៃការសិក្សាស្រាវជ្រាវមេរៀន និងមានភាពស្រដៀងគ្នានឹងការលើកឡើងរបស់ Peter (2019) ដែរ ដោយលោកបានសរសេរថា ការសិក្សាស្រាវជ្រាវមេរៀន គឺជាវិធីសិក្សាស្វែងយល់ពីវិជ្ជាជីវៈប្រកបដោយសក្តានុពល ដែលអាចធ្វើឲ្យ

ប្រសើរឡើងនូវការបង្រៀននិងរៀនចំណេះដឹងអនុវត្ត និងចំណេះដឹងមុខវិជ្ជារបស់គ្រូបង្រៀន។

### ៤.១.២. ការយល់ដឹងជារួមលើខ្លឹមសារ

ដោយឡែក សម្រាប់កម្រិតយល់ដឹងលើខ្លឹមសារការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនរបស់ភាគសំណាក មានបង្ហាញដូចក្រាបខាងក្រោម (ក្រាបទី២)៖




ក្រាបទី២: កម្រិតយល់ដឹងលើខ្លឹមសារការសិក្សាមេរៀន

ទិន្នន័យខាងលើបង្ហាញឲ្យឃើញថា ការយល់ដឹងរបស់គ្រូៗនៅពុំទាន់មានភាពស្មើៗគ្នានៅឡើយទៅលើខ្លឹមសារសំខាន់ៗនៃការសិក្សាស្រាវជ្រាវមេរៀន។ តែទោះជាយ៉ាងណាក៏ដោយ ក៏ពុំស្ថិតនៅក្រមកម្រិតមធ្យមដែរ ពោលគឺមានការយល់ដឹងចាប់ពីមធ្យមឡើង។ ជារួម គ្រូៗនៅមានកម្រិតយល់ដឹងលើការសិក្សាស្រាវជ្រាវមេរៀនក្នុងកម្រិតល្អច្រើនជាងគេ។ ជាការកត់សម្គាល់របស់អ្នកស្រាវជ្រាវគួររៀបចំឲ្យមានការបំប៉នជាថ្មី មុននឹងដំណើរការនៃការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅឆ្នាំសិក្សាក្រោយ ជាពិសេសអ្នកដែលមិនបានទទួលវគ្គបំប៉ន ដើម្បីជាប្រយោជន៍ដល់គ្រូៗមួយចំនួនដែលនៅមិនទាន់យល់ដឹងច្បាស់លាស់លើខ្លឹមសារទាំងនោះ។ ម្យ៉ាងទៀត វាក៏អាចជាបញ្ហាដល់ការអនុវត្តការសិក្សាមេរៀនក្នុងសាលាផងដែរ ដែលគ្រូៗមួយចំនួនតូចនៅមិនទាន់យល់ច្បាស់ដូចនេះ ឬអាចនិយាយបានទៀតថា ពួកគាត់គ្រាន់តែមកចូលរួម

ប៉ុណ្ណោះ ហើយមិនបានដឹងឲ្យប្រាកដថាខ្លួនគាត់ត្រូវធ្វើអ្វី? ធ្វើយ៉ាងដូចម្តេច? ជាដើម។ ហេតុនេះហើយ ក្នុងនាមអ្នកស្រាវជ្រាវយល់ឃើញថា មានតែការបំប៉នបន្ថែមទេ ទើបជាមធ្យោបាយល្អក្នុងការបំពេញចន្លោះខ្វះខាត ដើម្បីឈានទៅរកការអនុវត្តការសិក្សាមេរៀនមួយដ៏ល្អ និងមានភាពរឹងមាំនាពេលអនាគត់។

ខាងលើនេះ ជាបរិបទរួមនៃការសិក្សាមេរៀននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង។ រីឯលទ្ធផលខាងក្រោមនេះ ជាជំហាននៃការសិក្សាមេរៀន ដែលជាវត្ថុបំណងនៃការស្រាវជ្រាវ ។

## ៤.២.ការរៀបចំផែនការមេរៀន (Plan)

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវសូមលើកយកការយល់ដឹង ការអនុវត្ត និងបញ្ហាប្រឈម មកបង្ហាញជាលទ្ធផលនៃការស្រាវជ្រាវ ដូចតទៅ៖

### ៤.២.១. ការយល់ដឹងលើការរៀបចំផែនការមេរៀន

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវបានផ្តោតលើពីរចំណុចសំខាន់ចំនួនបួនសម្រាប់យកមកសិក្សា គឺការចាត់តាំងគ្រូបង្រៀន ការរៀបចំកិច្ចតែងការបង្រៀន ការពិភាក្សាលើកិច្ចតែងការបង្រៀនសាកល្បងក្នុងក្រុមសិក្សាស្រាវជ្រាវមេរៀន និងការសរសេរកិច្ចតែងការសម្រេច។

#### ក. ការចាត់តាំងគ្រូបង្រៀន

ខាងក្រោមនេះ គឺជាលទ្ធផលដែលទទួលបានពីកម្រងសំណួរ (ក្រាបទី៣)៖




ក្រាបទី៣: កម្រិតយល់ដឹងលើការចាត់តាំងគ្រូបង្រៀន

លទ្ធផលខាងលើបង្ហាញថា គ្រូឧទ្ទេសស្ទើរតែទាំងអស់មានការយល់ច្បាស់លើការចាត់តាំងគ្រូសម្រាប់ឡើងបង្រៀនក្នុងការសិក្សាមេរៀន (95.7%) ។ នេះបញ្ជាក់ឲ្យឃើញថា ការបំប៉នស្តីពីការសិក្សាមេរៀនខាងលើ មានប្រសិទ្ធភាពអាចឲ្យដំណើរការសិក្សាមេរៀនបានល្អ។ តែទោះជាយ៉ាងណានៅមានគ្រូដែលមិនទាន់យល់ច្បាស់ (4.3%) គួរត្រូវបានជួយពីក្រុមបន្ថែមទៀត ដើម្បីគាត់បានយល់ច្បាស់។

ដោយឡែក សម្រាប់ការរៀបចំក្រុមសិក្សាមេរៀនតាមមុខវិជ្ជាវិញ គ្រូបានផ្តល់ការយល់ដឹង ដូចក្រាបខាងក្រោម៖




ក្រាបទី៤: ការយល់ដឹងរបស់គ្រូលើការរៀបចំក្រុមសិក្សាមេរៀន

តាមលទ្ធផលក្រាបទី៤ ក៏មានគ្រូឧទ្ទេសភាគច្រើនយល់ដឹងលើការរៀបចំក្រុមសិក្សាស្រាវជ្រាវមេរៀន (87.0%) តែទន្ទឹមនឹងនោះក៏នៅមានគ្រូមួយចំនួនមិនទាន់យល់ច្បាស់នៅឡើយ (13.0%) ថាតើការរៀបចំក្រុមនេះត្រូវធ្វើឡើងតាមក្រុមបច្ចេកទេសនីមួយៗ ឬតាមការចាត់តាំងឡើងដោយការិយាល័យសិក្សា។ បច្ចុប្បន្ន សាលាបានអនុវត្តក្រុមតែពីរទេ គឺក្រុមគណិតវិទ្យា និងក្រុមវិទ្យាសាស្ត្រ តាមការណែនាំរបស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ។

## ខ. ការរៀបចំកិច្ចតែងការបង្រៀន

តាមរយៈទិន្នន័យដែលបានផ្ដល់ដោយភាគសំណាក បានបង្ហាញឲ្យឃើញនូវការយល់ដឹងរបស់គ្រូទៅលើការរៀបចំកិច្ចតែងការបង្រៀន ដូចក្រាបទី៥ខាងក្រោម៖




ក្រាបទី៥: ការយល់ដឹងរបស់គ្រូលើការរៀបចំកិច្ចតែងការបង្រៀន

ផ្នែកនេះក៏ដូចជាផ្នែកមុនដែរ កម្រិតនៃការយល់ដឹងរបស់គ្រូទៅលើការរៀបចំកិច្ចតែងការបង្រៀនមានចំនួនច្រើនរហូតដល់ 95.7% និងមិនទាន់យល់ច្បាស់ត្រឹមតែ 4.3% ។ លទ្ធផលនេះបញ្ជាក់ឲ្យឃើញថា គ្រូមានការយល់ដឹងច្រើនលើការរៀបចំកិច្ចតែងការបង្រៀនសម្រាប់ដំណើរការសិក្សាមេរៀននៅក្នុងសាលារៀន។

## គ. ការពិភាក្សាលើកិច្ចតែងការបង្រៀន

ជាលទ្ធផលដែលទទួលបានពីកម្រងសំណួរ មានដូចក្រាបទី៦ខាងក្រោម៖




ក្រាបទី៦: ការយល់ដឹងរបស់គ្រូលើការពិភាក្សាកិច្ចតែងការបង្រៀន

លទ្ធផលបង្ហាញថា ចំនួនគ្រូឧទ្ទេសដែលបានយល់ច្បាស់ពីការពិភាក្សាលើកិច្ចតែងការបង្រៀនមានរហូតដល់ 95.7% និងមិនទាន់យល់ច្បាស់មានត្រឹមតែ 4.3% ប៉ុណ្ណោះ។ លទ្ធផលនេះបង្ហាញឲ្យឃើញថា ចំនួនគ្រូឧទ្ទេសដែលបានយល់ច្បាស់លើខ្លឹមសារនៃការវិភាគលើកិច្ចតែងការបង្រៀនមានចំនួនច្រើន សម្រាប់ចូលរួមអនុវត្តការងារក្នុងជំហាននេះឲ្យទទួលបានលទ្ធផលល្អ។

**ឃ. ការសរសេរកិច្ចតែងការសម្រេច**

ក្រាបខាងក្រោមនេះបង្ហាញពីលទ្ធផលនៃការយល់ដឹងរបស់គ្រូ៖




ក្រាបទី៧: ការយល់ដឹងរបស់គ្រូលើការសរសេរកិច្ចតែងការសម្រេច

លទ្ធផលនេះនៅតែបង្ហាញថា គ្រូមានការយល់ដឹងច្រើនលើការសរសេរកិច្ចតែងការសម្រេចក្នុងកម្រិតច្រើនដដែល (91.3%) ទោះបីភាគរយអ្នកមិនទាន់យល់ច្បាស់មានការកើនឡើងបន្តិចក៏ពិតមែន។ នេះបង្ហាញពីការយកចិត្តទុកដាក់ចូលរួម និងប្រឹងប្រែងស្វែងយល់បន្ថែមលើការបង្កើនសមត្ថភាពបង្រៀនរបស់គ្រូម្នាក់ៗ។

សរុបជារួមនៅក្នុងផ្នែកនេះ គ្រូមានការយល់ដឹងច្រើនណាស់លើការរៀបចំផែនការមេរៀន ការចាត់តាំងគ្រូបង្រៀន ការពិភាក្សាលើកិច្ចតែងការបង្រៀន និងការសរសេរកិច្ចតែងការសម្រេច។

### ៤.២.២. ការអនុវត្តការរៀបចំផែនការមេរៀន

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវនឹងលើកបង្ហាញអំពីលទ្ធផលនៃការអនុវត្តការរៀបចំផែនការមេរៀន តាមខ្លឹមសារដូចខាងក្រោម៖

#### ក. ការចាត់តាំងគ្រូបង្រៀន

ផ្អែកលើទិន្នន័យដែលទទួលបាន ការចាត់តាំងគ្រូឲ្យឡើងបង្រៀន គឺត្រូវធ្វើឡើងតាមក្រុមមុខវិជ្ជា។ ការិយាល័យសិក្សាដែលជាសេនាធិការផ្នែកបច្ចេកទេស ជាអ្នករៀបចំក្រុមសិក្សាមេរៀនតាមមុខវិជ្ជា ដែលក្នុងការអនុវត្តជាក់ស្តែង មានពីរក្រុម គឺក្រុមគណិតវិទ្យា (មានមុខវិជ្ជាគណិតវិទ្យា និងភាសាខ្មែរ) និងក្រុមវិទ្យាសាស្ត្រ (មានមុខវិជ្ជាវិទ្យាសាស្ត្រ និងសិក្សាសង្គម) ។

ក្រាបទី៨ខាងក្រោមនេះ ជាលទ្ធផលនៃការអនុវត្តការរៀបចំក្រុមសិក្សាមេរៀន៖




ក្រាបទី៨: ការអនុវត្តការរៀបចំក្រុមសិក្សាមេរៀន

តាមក្រាបខាងលើ គ្រូយល់ថា ការរៀបចំក្រុមក្នុងការអនុវត្តការសិក្សាមេរៀន មានភាពល្អប្រសើរច្រើន ដែលស្តែងឲ្យឃើញពីការអនុវត្តតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ។

ក្រៅពីនេះ ការិយាល័យសិក្សាក៏ជាអ្នករៀបចំកាលវិភាគសម្រាប់អនុវត្តផងដែរ។ ក្រុមនីមួយៗត្រូវជួបប្រជុំគ្នាតាមកាលវិភាគដែលបានកំណត់ដោយការិយាល័យសិក្សា។ ត្រង់ចំណុចនេះ សមាជិកក្នុងក្រុមត្រូវចាត់តាំងគ្រូម្នាក់សម្រាប់ឡើងបង្រៀន។ រាល់ការចាត់តាំងគ្រូឲ្យឡើងបង្រៀន ត្រូវមានការឯកភាពពីសាមីខ្លួនផងដែរ និងត្រូវប្តូរវេនគ្នា ចៀសវាងការចាត់តែគ្រូដដែលៗ។ គ្រូដែលត្រូវបានចាត់ឲ្យឡើងបង្រៀនអាចជ្រើសរើសមេរៀនណាមួយក៏បាន តាមដែលខ្លួនគិតថាចាំបាច់ និងសមស្របក្នុងការពិភាក្សា ឬពិភាក្សាគ្នាក្នុងក្រុមជ្រើសរើសមេរៀនសម្រាប់ឡើងបង្រៀនក៏បាន។ បន្ទាប់មក សមាជិកក្នុងក្រុមមុខវិជ្ជាត្រូវនីមួយៗ ត្រូវណាត់ជួបគ្នាតាមកាលវិភាគរបស់សាលា ដើម្បីពិភាក្សាគ្នាលើកិច្ចតែងការបង្រៀន។

**ខ. ការរៀបចំកិច្ចតែងការបង្រៀន**

គ្រូដែលបានចាត់ឲ្យឡើងបង្រៀនត្រូវសិក្សាខ្លឹមសារមេរៀន ដែលខ្លួនបានសម្រេចជ្រើសរើសសម្រាប់ឡើងបង្រៀន ដោយត្រូវសិក្សាស្រាវជ្រាវមេរៀននោះ រចនាសម្ព័ន្ធកម្មវិធីសិក្សា វិភាគអំពីកម្រិតយល់ដឹងរបស់សិស្ស ខ្លឹមសារដែលមានទំនាក់ទំនងគ្នា វិធីបង្រៀន ការវាយតម្លៃ សម្ភារៈឧបទេស ជាដើម។ តមកទើបចាប់ផ្តើមសរសេរកិច្ចតែងការបង្រៀនតាមរយៈពេលកំណត់ ជាធម្មតាគឺ ៥០ នាទី ដូចនៅបឋមសិក្សាដែរ។ កិច្ចតែងការបង្រៀននេះមិនទាន់យកជាការនៅឡើយទេ ពោលគឺគ្រាន់តែជាគំនិតយល់ឃើញពីវិធីបង្រៀនមេរៀនមួយរបស់គ្រូ ដែលបានចាត់ឲ្យឡើងបង្រៀនតែប៉ុណ្ណោះ។ វាគ្រាន់តែជាកិច្ចតែងការព្រាងដែលត្រូវបានគ្រូសរសេរឡើង ដើម្បីយកមកពិភាក្សាគ្នានៅពេលបន្ទាប់ទៀត។

**គ. ការពិភាក្សាលើកិច្ចតែងការបង្រៀន**

លុះដល់ថ្ងៃត្រូវជួបជុំគ្នាតាមកាលវិភាគកំណត់ សមាជិកក្រុមម្នាក់ៗត្រូវមកចូលរួមប្រជុំ ដើម្បីពិភាក្សាគ្នាលើកិច្ចតែងការបង្រៀន ដែលគ្រូបានសរសេរឡើង។ សមាជិកក្រុមសិក្សាមេរៀនត្រូវពិនិត្យលើកិច្ចតែងការបង្រៀនយ៉ាងហ្មត់ចត់ ដើម្បីរកឲ្យឃើញនូវភាពសមស្របដែលអាចនាំឲ្យសម្រេចលទ្ធផលសិក្សារំពឹងទុក។

រូបទី៩ខាងក្រោមនេះ ជាលទ្ធផលនៃការអនុវត្តការពិភាក្សាលើកិច្ចតែងការបង្រៀន ដែលភាគសំណាកបានផ្តល់តាមរយៈកម្រងសំណួរៈ




ក្រាបទី៩: ការអនុវត្តការពិភាក្សាលើកិច្ចតែងការបង្រៀន

តាមទិន្នន័យក្នុងក្រាបខាងលើ ការអនុវត្តការពិភាក្សាហាក់នៅមិនទាន់បានល្អនៅឡើយ ដោយសារក្នុងក្រុមមុខវិជ្ជានីមួយៗមានគ្រូចម្រុះមុខវិជ្ជា ជាហេតុធ្វើឲ្យការពិភាក្សាលើកិច្ចតែងការមិនសូវបានល្អ។ គ្រូដែលមិនមែនជាឯកទេសខ្លួន មិនសូវបញ្ចេញមតិយោបល់អ្វីច្រើន ព្រោះខ្លួនយល់មិនបានស៊ីជម្រៅលើឯកទេសផ្សេង។ ម្យ៉ាងគ្រូខ្លះយកតែគំនិតខ្លួនជាត្រូវ ជាហេតុនាំឲ្យមានខ្វែងគំនិតគ្នាច្រើនក្នុងពេលពិភាក្សា។ ឯគ្រូខ្លះទៀតចូលរួមមិនសូវបានទៀងទាត់ ធ្វើឲ្យបាត់បង់ការចូលរួមជាគំនិតយោបល់កែលម្អគ្នា។

ជាធម្មតា ការចូលរួមក្នុងដំណាក់កាលនេះគឺមានសារៈសំខាន់ខ្លាំងណាស់ ព្រោះគេត្រូវការយោបល់ពីសមាជិកក្រុមផ្សេងៗទៀត សម្រាប់ជួយកែលម្អកិច្ចតែងការបង្រៀនឲ្យកាន់តែប្រសើរឡើង។

ក្រាបទី១០ខាងក្រោមនេះ ជាលទ្ធផលនៃការចូលរួមប្រជុំធ្វើការសិក្សាស្រាវជ្រាវរបស់គ្រូៗនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង ជាបុគ្គល និងជាក្រុម៖




ក្រាបទី១០: កម្រិតនៃការចូលរួមជាបុគ្គល

ផ្អែកតាមលទ្ធផលខាងលើនេះ អាចនិយាយបានថា គ្រូមួយចំនួននៅពុំទាន់បានចូលរួមពេញលេញ ដោយមានគ្រូអវត្តមានខ្លះក្នុងពេលអនុវត្តការសិក្សាមេរៀននៅក្នុងក្រុមមុខវិជ្ជារបស់ខ្លួន និងអាចជាហេតុធ្វើឲ្យគ្រូទាំងនោះពុំអាចទទួលបានចំណេះដឹងថ្មីបន្ថែម និងបទពិសោធល្អៗពីសមាជិកក្រុម ឬអាចនិយាយបានទៀតថា ការចូលរួមមិនទៀងទាត់ អាចជាឧបសគ្គមួយសម្រាប់អភិវឌ្ឍវិជ្ជាជីវៈរបស់ពួកគាត់នាពេលអនាគត់។ គណៈគ្រប់គ្រងសាលាត្រូវជំរុញគ្រូទាំងនេះឲ្យចូលរួមការសិក្សាមេរៀនឲ្យបានច្រើនថែមទៀត អាចមានជាវិធានការផងដែរបើចាំបាច់ ដើម្បីជំរុញការចូលរួមទាំងអស់គ្នា។

ក្រាបទី១១ខាងក្រោមនេះ បង្ហាញពីការចូលរួមរបស់ក្រុមសិក្សាមេរៀនទាំងមូល៖




ក្រាបទី១១: ការចូលរួមរបស់ក្រុមសិក្សាមេរៀន

និយាយជារួមថា ការចូលរួមអនុវត្តការសិក្សាស្រាវជ្រាវមេរៀនរបស់ក្រុមមុខវិជ្ជានីមួយៗ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែងស្ថិតក្នុងកម្រិតច្រើន មានន័យថាមានអ្នកចូលរួមច្រើន ដែលអាចធ្វើឲ្យដំណើរការការសិក្សាមេរៀនប្រព្រឹត្តទៅបាន។ តែទោះបីយ៉ាងណាក៏ដោយ នៅមានសមាជិកក្រុមមួយចំនួនតូចទៀត ដែលមិនទាន់បានចូលរួមពេញលេញនៅឡើយ។ សម្រាប់ការអនុវត្តការសិក្សាមេរៀនបន្តនៅឆ្នាំសិក្សាក្រោយ សមាជិកទាំងនោះគួរប្តូរឥរិយាបទ និងមានមនសិការចូលរួមការសិក្សាមេរៀនឲ្យបានទៀងទាត់តាមផែនការរបស់សាលា ហើយគណៈគ្រប់គ្រងសាលាត្រូវជំរុញនិងលើកទឹកចិត្តបន្ថែមទៀត។

នៅពេលមានការចូលរួមពីសមាជិកក្រុមច្រើន នោះការពិភាក្សាក៏បានល្អ ដោយសារមានគំនិតច្រើនជួយគ្នា។ នៅពេលនេះ គេអាចបង្រៀនសាក់ល្បងក្នុងក្រុមមុខវិជ្ជាខ្លួនសិនមុននឹងបង្រៀនជាក់ស្តែងជាមួយសិស្ស។ ក្រាបទី១២ខាងក្រោមនេះ ជាលទ្ធផលនៃការអនុវត្តការបង្រៀនសាកល្បងក្នុងក្រុម៖




ក្រាបទី១២: ការអនុវត្តបង្រៀនសាកល្បងក្នុងក្រុម

ផ្អែកតាមក្រាបខាងលើ ទោះបីនៅមានចំណុចខ្វះខាតដែលធ្វើឲ្យការអនុវត្តការបង្រៀនសាក់ល្បងមិនសូវបានល្អក៏ដោយ តែជាទូទៅ មានចំណុចល្អច្រើនដែលអាចនិយាយបានថា មានការបង្រៀនសាក់ល្បងក្នុងក្រុមសិនមុននឹងយកមេរៀននិងកិច្ចតែងការបង្រៀនទៅបង្រៀនផ្ទាល់ជាមួយសិស្ស។

**ឃ. ការសរសេរកិច្ចតែងការសម្រេច**

ក្រោយពេលបង្រៀនសាកល្បងក្នុងក្រុមសិក្សាស្រាវជ្រាវមេរៀនចប់ សមាជិកក្រុមត្រូវប្រជុំគ្នា និងផ្តល់មតិកែលម្អនានាលើកិច្ចតែងការបង្រៀន និងសកម្មភាពបង្រៀនរបស់គ្រូដែលបានចាត់ឲ្យឡើងបង្រៀន ដោយផ្អែកលើចំណុចខ្វះខាតដែលសមាជិកក្រុមបានសង្កេតឃើញ។ គ្រូត្រូវកែលម្អកិច្ចតែងការរបស់ខ្លួន ដោយផ្អែកលើអនុសាសន៍ទាំងនោះ ដើម្បីធ្វើឲ្យកិច្ចតែងការនេះមានភាពល្អប្រសើរឡើង។ កិច្ចតែងការដែលបានកែលម្អនាពេលនេះ ជាកិច្ចតែងការដែលនឹងត្រូវយកទៅបង្រៀនជាមួយសិស្សផ្ទាល់នៅពេលក្រោយ។

ទាំងនេះ គឺជាអ្វីដែលគ្រូនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែងបានអនុវត្តនៅក្នុងការរៀបចំផែនការមេរៀន សម្រាប់ដំណើរការសិក្សាមេរៀន។ និយាយជា

រួម ទាំងការយល់ដឹង ទាំងការអនុវត្តរបស់គ្រូមានភាពវិជ្ជមានច្រើន។ តែយ៉ាងណាក៏នៅមានបញ្ហាប្រឈមមួយចំនួនដែរ។

**៤.២.៣. បញ្ហាប្រឈម**

ផ្អែកតាមទិន្នន័យដែលទទួលបានពីភាគសំណាក អ្នកស្រាវជ្រាវនឹងលើកយកនូវបញ្ហាប្រឈមមួយចំនួនមកបង្ហាញ ក្នុងការអនុវត្តការរៀបចំផែនការមេរៀន ដូចខាងក្រោម៖

**ក. ការឈប់ឥតព្រាងទុក**

ក្នុងការអនុវត្តផែនការសិក្សាមេរៀន តែងជួបប្រទះនឹងបញ្ហាការឈប់ឥតព្រាងជាញឹកញាប់ ដូចជា កម្មវិធីផ្សេងៗរបស់អាជ្ញាធរខេត្ត ឬកម្មវិធីរបស់សាលាជាដើម។ ម្យ៉ាងទៀត ពេលខ្លះត្រូវផ្អាក់ការសិក្សាមេរៀនដោយសារគ្រូឧទ្ទេសត្រូវទៅចូលរួមសិក្ខាសាលានៅក្រៅខេត្ត។ ជាបញ្ហាមួយដែរនោះ គឺគ្រូអនុវត្តមុខវិជ្ជាដដែលៗ មិនមានការផ្លាស់ប្តូរ ឬរៀបចំឆ្លាស់មុខវិជ្ជាឡើងបង្រៀន។

ជាដំណោះស្រាយចំពោះបញ្ហាឈប់ឥតព្រាងទុក គឺត្រូវលើកថ្ងៃទៅអនុវត្តនៅថ្ងៃក្រោយ ដែលទំនេរជំនួសវិញ ដើម្បីបំពេញបន្ថែមក្នុងផែនការ។ ដោយឡែកចំពោះការអនុវត្តមុខវិជ្ជាដដែលៗច្រើនពេក អាចធ្វើឲ្យគ្រូមានការធុញថប់នោះ គ្រូៗបានស្នើឲ្យមានការឆ្លាស់មុខវិជ្ជាក្នុងការអនុវត្តការប្រជុំសិក្សាមេរៀន។

**ខ. ការចូលរួមរបស់គ្រូឧទ្ទេស**

បញ្ហាប្រឈមមួយទៀតក្នុងការអនុវត្តការសិក្សាមេរៀន គឺការចូលរួម។ គ្រូខ្លះមកចូលរួមប្រជុំសិក្សាមេរៀនមិនបានទៀងទាត់ មិនបានមកគ្រប់គ្នា ១០០% ទេ ក្នុងការប្រជុំមួយលើកៗ និងគ្រូមួយចំនួនតូចទៀតមិនបានមកចូលរួមគ្រប់សប្តាហ៍កំណត់។ ក្រៅពីនេះនៅមានគ្រូដែលមកចូលរួមប្រជុំហើយ តែមិនសូវចូលរួមសកម្មភាពក្នុងក្រុមសិក្សាមេរៀនរបស់ខ្លួន។ និងគ្រូមួយចំនួនតូចខ្លះទៀតមកចូលរួមយឺត។ កត្តាទាំងនេះអាចជាមូលហេតុធ្វើឲ្យរាំងស្ទះ ដល់ដំណើរការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូទាំងនោះបាន ឬអាចថាជាកត្តារាំងដែលធ្វើឲ្យគ្រូទាំងនោះមានការអភិវឌ្ឍវិជ្ជាជីវៈយឺតក៏ថាបាន។

គ្រូឧទ្ទេសបានស្នើឲ្យមានការដោះស្រាយ ដោយគណៈគ្រប់គ្រងត្រូវជំរុញឲ្យមានការចូលរួម ឬអាចថាជាការរំឭកពួកគាត់ជាប្រចាំ លើកទឹកចិត្តឲ្យមានការចូលរួម និងឧស្សាហ៍បំផុសព័ត៌មានក្នុងក្រុម ដើម្បីឲ្យពួកគាត់បានដឹងមុន។ ចំពោះគ្រូមួយចំនួនដែលមិនសូវចូលរួមអនុវត្តការសិក្សាមេរៀនគួរហៅមកសួរនាំ បើមិនប្តូរឥរិយាបទ គួរប្តូរឲ្យអ្នកផ្សេងចូលជំនួស ឬគួរដាក់វិន័យរដ្ឋបាល។

### គ. បញ្ហាប្រឈមក្នុងក្រុមមុខវិជ្ជា

បញ្ហាប្រឈមក្នុងក្រុមមុខវិជ្ជាមានជាអាទិ៍៖ ការខ្វែងគំនិតគ្នាខ្លះពេលវិភាគកិច្ចតែងការបង្រៀន ដោយសមាជិកខ្លះព្យាយាមនិយាយយកត្រូវតែខ្លួនឯង ខណៈដែលសមាជិកក្រុមខ្លះទៀតមិនសូវផ្តល់យោបល់ និងមិនសូវយកចិត្តទុកដាក់បញ្ចេញមតិយោបល់។ ឯពេលខ្លះ សមាជិកក្រុមមានចំនួនតិច ហើយគ្រូឯកទេសក៏មានចំនួនតិចទៀត ដែលជាហេតុនាំឲ្យមានការផ្តល់យោបល់មិនបានទូលំទូលាយ។ មួយវិញទៀត អ្នកឡើងបង្រៀនមុខដដែលៗ ពុំសូវមានអ្នកស្ម័គ្រចិត្តឡើងបង្រៀន ព្រោះម្នាក់ៗចាំតែចាប់កំហុសអ្នកបង្រៀន។

ជាដំណោះស្រាយដែលបានអនុវត្ត គឺសុំការអន្តរាគមន៍ពីអ្នកសម្របសម្រួលក្រុម និងពីនាយកសាលាឲ្យជំរុញដល់គ្រូទាំងអស់ចូលរួមដោយយកចិត្តទុកដាក់ ធ្វើការឆ្លុះបញ្ចាំង និងផ្តល់ព័ត៌មានត្រឡប់។ ក្នុងករណីមានការខ្វែងគំនិតគ្នា ត្រូវយកមតិនីមួយៗមកពិភាក្សាគ្នា ដើម្បីរកចំណុចឯកភាពគ្នា និងមានការជួយអន្តរាគមន៍ពីអ្នកសម្របសម្រួលតាមក្រុមនីមួយៗ ដើម្បីបន្តការងារទៅមុខ។

បញ្ហាប្រឈមដែលបានលើកឡើងខាងលើនេះ តែងតែកើតមាននៅក្នុងក្រុមសិក្សាមេរៀន តែមិនមែនជាបញ្ហាធំដែលធ្វើឲ្យតាំងស្ទះដល់ដំណើរការសិក្សាមេរៀនឡើយ គ្រាន់តែជាភាពរអាក់រអួលមួយដែលពេលខ្លះធ្វើឲ្យដំណើរការសិក្សាមេរៀនមិនសូវបានរលូនល្អ ឬថា ធ្វើឲ្យសមាជិកក្នុងក្រុមមិនសូវពេញចិត្ត។ តែជាទូទៅ ក្រុមសិក្សាមេរៀនបានដំណើរការទៅមុខជានិច្ច និងមានលទ្ធផលជាវិជ្ជមានលើការងាររបស់ខ្លួន។

## ៤.៣. ការអនុវត្តការបង្រៀន និងការសង្កេត (Do)

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវនឹងបង្ហាញលទ្ធផលនៃការស្រាវជ្រាវដែលទាក់ទងនឹងការយល់ដឹងទៅលើការបង្រៀន និងការសង្កេត ការអនុវត្តការបង្រៀននិងការសង្កេត និងបញ្ហាប្រឈមដែលកើតមានឡើង ក្នុងដំណើរការសិក្សាមេរៀន។

### ៤.៣.១.ការយល់ដឹងលើការបង្រៀន និងការសង្កេត

ផ្អែកលើទិន្នន័យដែលទទួលបានពីភាគសំណាក លទ្ធផលនៃការស្រាវជ្រាវលើការយល់ដឹងរបស់គ្រូលើការបង្រៀន និងការសង្កេត មានដូចក្រាបទី១៣ខាងក្រោម៖




ក្រាបទី១៣: ការយល់ដឹងរបស់គ្រូលើការបង្រៀន និងការសង្កេត

លទ្ធផលដែលស្តែងចេញតាមរយៈក្រាបខាងលើ បង្ហាញថា គ្រូមានការយល់ដឹងលើការបង្រៀន និងការសង្កេត ក្នុងដំណើរការសិក្សាមេរៀន កម្រិតច្បាស់លាស់មានចំនួនច្រើនលើសលប់ (95.7%)។ តែទោះជាយ៉ាងណាក៏នៅមានគ្រូដែលមិនទាន់យល់ច្បាស់ (4.3%) ដែលគាត់គឺជាគ្រូថ្មី ទើបតែចូលរួមក្នុងសិក្សាមេរៀនក្នុងឆ្នាំសិក្សា២០១៨-២០១៩។ ជារួម គ្រូឧទ្ទេសពិតជាមានការយល់ដឹងច្បាស់លាស់ សម្រាប់អនុវត្តការសិក្សាមេរៀនឲ្យដំណើរការល្អ។

## ៤.៣.២.ការអនុវត្តការបង្រៀន និងការសង្កេត

បន្ទាប់ពីការបង្រៀនសាក់ល្បងក្នុងក្រុម និងការកែលម្អកិច្ចតែងការបង្រៀនរួចរាល់ហើយ គ្រូដែលបានចាត់ឲ្យឡើងបង្រៀននោះ ត្រូវឡើងបង្រៀនជាមួយសិស្សតាមកាលវិភាគកំណត់។ គ្រូដែលបានចាត់ឲ្យឡើងបង្រៀនត្រូវរៀបចំសម្ភារៈឧបទេសឯកសារ ឬ សន្លឹកកិច្ចការផ្សេងៗ សម្រាប់ដំណើរការបង្រៀន។ រីឯអ្នកសម្របសម្រួលត្រូវចាត់អញ្ជើញសិស្សមួយថ្នាក់ណាមួយ និងប្រកាសប្រាប់សមាជិកក្រុមឲ្យមកចូលរួមពិនិត្យលើការបង្រៀន។

ចំពោះគ្រូដែលជាសមាជិកក្រុម និងជាអ្នកសង្កេតការបង្រៀន ត្រូវផ្តោតការយកចិត្តទុកដាក់លើសកម្មភាពបង្រៀន និងរៀន។ អ្នកសង្កេតត្រូវកត់ត្រារាល់សកម្មភាពឃ្លាប្រយោគ ដែលសិស្សបានធ្វើ ទំនាក់ទំនងរវាងគ្រូនិងសិស្ស សិស្សនិងសិស្ស ដើម្បីជាមូលដ្ឋានក្នុងការផ្តល់យោបល់កែលម្អ។

ក្រាបទី១៤ ខាងក្រោមនេះគឺជាលទ្ធផលនៃការអនុវត្តការបង្រៀន និងការសង្កេត ដែលគ្រូបានអនុវត្តនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង៖




ក្រាបទី១៤: ការអនុវត្តការបង្រៀន និងសង្កេត

ផ្អែកតាមទិន្នន័យក្នុងក្រាបខាងលើ បង្ហាញថា ការអនុវត្តការបង្រៀន និងការសង្កេតការបង្រៀនមានភាពល្អប្រសើរ ដោយសារគ្រូចំនួនធំបានយល់ និងបានអនុវត្តតាមការណែនាំរបស់អ្នកសម្របសម្រួលវគ្គ និងក្រសួងអប់រំ យុវជន និងកីឡា។

សរុបមក គ្រូពិតជាមានការអនុវត្តការបង្រៀន និងការសង្កេតការបង្រៀនបានល្អ ដោយគ្រូដែលត្រូវឡើងបង្រៀនបានរៀបចំខ្លឹមសារមេរៀន សម្ភារៈឧបទេស និងបានធ្វើសកម្មភាពបង្រៀនទៅតាមកិច្ចតែងការបង្រៀនដែលបានកែសម្រួលរួច។ ក្រៅពីនេះ សមាជិកក្រុមសិក្សាស្រាវជ្រាវមេរៀនបានជួបប្រជុំគ្នា និងបានផ្តល់មតិកែលម្អលើសកម្មភាពបង្រៀន កែសម្រួលកិច្ចតែងការបង្រៀន សម្រាប់យកទៅបង្រៀនជាមួយសិស្សនៅសន្ទាប់ក្រោយ។ ដែលសកម្មភាពទាំងនេះពិតជាសមស្របតាមការណែនាំ និងការចង់បានរបស់ក្រសួងអប់រំ យុវជន និងកីឡា។

### ៤.៣.៣. បញ្ហាប្រឈម

ទោះបីមានការយល់ដឹង និងការអនុវត្តការបង្រៀន និងការសង្កេតបានល្អក៏ដោយ តែក៏នៅមានបញ្ហាប្រឈមខ្លះៗ កើតឡើងផងដែរ។

#### ក. បញ្ហាសម្ភារៈឧបទេស

ក្នុងចំណុចនេះ គ្រូបានលើកឡើងថា បញ្ហាប្រឈមគឺសម្ភារៈខ្លះពិបាកផលិត ព្រោះត្រូវការសម្ភារៈពិតជាក់ស្តែង តែមិនមានលក់នៅទីផ្សារក្នុងស្រុក ដោយផលិតបាន

តែសម្ភារៈងាយៗ។ នៅមិនទាន់មានអ្នកផ្តួចផ្តើមគំនិតផលិត ដោយការផលិតមានតែអ្នកបង្រៀនម្នាក់ឯង ជាហេតុធ្វើឲ្យសម្ភារៈឧបទេសពុំសូវសំបូរបែប។ សមាជិកក្នុងក្រុមមិនជួយគ្នាផលិត យកតែរៀងៗខ្លួន ជាហេតុធ្វើឲ្យមិនមានសម្ភារៈតាមខ្លឹមសារមេរៀនគ្រប់គ្រាន់។

ជាដំណោះស្រាយ គ្រូបានប្រើ ICT ជាជំនួយក្នុងការបង្រៀន ដូចជា ទាញយករូបភាព និងឃ្លីបវីដេអូពីអ៊ីនធឺណែត មកបង្ហាញ ឬបញ្ចាំងឲ្យសិស្សមើល។ គណៈគ្រប់គ្រងជំរុញសមាជិកដទៃទៀតចូលរួមផលិត ឬអាចរកសម្ភារៈងាយៗជុំវិញខ្លួនតាមលទ្ធភាព។ ម្យ៉ាងទៀត ការផលិតសម្ភារៈឧបទេសត្រូវការពេលវេលា និងចេះភាសាអង់គ្លេសផងដែរ ព្រោះឯកសារ ឬរូបភាពដែលបានមកភាគច្រើនជាភាសាអង់គ្លេស។ ដូចនេះ គ្រូក្នុងក្រុមត្រូវជួយគ្នា និងស្នើសុំសាលាផ្តល់ថវិកាសម្រាប់ទិញសម្ភារៈមកផលិតជាដើម។

**ខ. បញ្ហាក្នុងក្រុមមុខវិជ្ជា**

បញ្ហាប្រឈមផ្ទាល់ខ្លួនរបស់សមាជិកក្រុមសិក្សាមេរៀនដែលជួបប្រទះកន្លងមក គឺពុំសូវទទួលបានចំណេះដឹងថ្មីច្រើនពីសមាជិកក្រុម ដោយសារសមាជិកក្នុងក្រុមមានមុខវិជ្ជាឯកទេសខុសៗគ្នាចូលរួមក្នុងក្រុមតែមួយ ហើយមេរៀនក្នុងមុខវិជ្ជាធំៗមួយចំនួនពិបាកយល់ ជាហេតុធ្វើឲ្យមានអារម្មណ៍ធុញទ្រាន់លើការអនុវត្តការសិក្សាមេរៀនពេលខ្លះ។ ម្យ៉ាងទៀត គ្រូឧទ្ទេសពុំសូវមានពេលច្រើនក្នុងការជជែកពិភាក្សាគ្នា ដើម្បីឲ្យការអនុវត្តការសិក្សាមេរៀន ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ចំពោះដំណោះស្រាយបញ្ហាប្រឈមខាងលើ សមាជិកក្រុមមុខវិជ្ជាបានស្វែងយល់ដោយខ្លួនឯង និងសិក្សាឯកសារផ្សេងៗបន្ថែម ស្នើសុំជំនួយពីអ្នកសម្របសម្រួលក្រុម និងប្រើការព្យាយាមចូលរួមអនុវត្តការងារនេះ ព្យាយាមសួរនាំបន្ថែមក្រោយពេលបញ្ចប់សកម្មភាពនីមួយៗ និងរៀនទទួលយកគំនិតអ្នកដទៃ។ គណៈគ្រប់គ្រងជួយជំរុញទឹកចិត្តឲ្យគ្រូឲ្យចូលរួមក្នុងសកម្មភាពសិក្សាស្រាវជ្រាវមេរៀនជាប្រចាំ។

## ៤.៤. ការពិភាក្សាលើការបង្រៀន និងរៀន (Check)

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវនឹងបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវតាមកម្រិតយល់ដឹង ការអនុវត្ត និងបញ្ហាប្រឈម ដែលកើតមានក្នុងការពិភាក្សាលើការបង្រៀន និងរៀន ដូចមានក្នុងខ្លឹមសារខាងក្រោម៖

### ៤.៤.១. ការយល់ដឹងលើការពិនិត្យការបង្រៀន និងរៀន

ការពិភាក្សាលើការបង្រៀន និងរៀន ជាដំណាក់កាលបន្ទាប់ពីការបង្រៀនជាមួយសិស្សចប់។ សមាជិកក្រុមសិក្សាស្រាវជ្រាវមេរៀនទាំងអស់ត្រូវប្រជុំពិភាក្សាគ្នាដើម្បីពិនិត្យលើការបង្រៀន និងរៀន។

ត្រង់ផ្នែកនេះ អ្នកស្រាវជ្រាវសូមលើកបង្ហាញនូវការយល់ដឹងជារួមរបស់គ្រូដែលបានផ្ដល់តាមរយៈកម្រងសំណួរ៖




ក្រាបទី១៥: ការយល់ដឹងលើការពិភាក្សាការបង្រៀន និងរៀន

តាមរយៈលទ្ធផលនេះ បង្ហាញថា គ្រូមានការយល់ដឹងលើការពិនិត្យការបង្រៀន និងរៀនចំនួនច្រើន និងមានកម្រិតយល់ដឹងខ្ពស់ (95.7%) រីឯគ្រូដែលនៅមិនទាន់យល់ច្បាស់ មានកម្រិតទាប (4.3%)។ នេះសបញ្ជាក់ថា គ្រូបានទទួលចំណេះដឹងពីការបំប៉នការសិក្សាមេរៀនបានល្អ និងមានបទពិសោធល្អពីការចូលរួមធ្វើការសិក្សាស្រាវជ្រាវមេរៀន។

### ៤.៤.២. ការអនុវត្តការពិភាក្សាលើការបង្រៀន និងរៀន

ការអនុវត្តការពិភាក្សាលើការបង្រៀន និងរៀននេះ ធ្វើឡើងក្នុងគោលបំណងដើម្បីកែលម្អការបង្រៀន និងរៀន វិធីសាស្ត្របង្រៀនរបស់គ្រូដែលឡើងបង្រៀនផង និងដើម្បីផ្ដល់ឱកាសឲ្យសមាជិកក្រុមសិក្សាមេរៀន និងគ្រូផ្សេងទៀតបានស្វែងយល់ និង

ផ្លាស់ប្តូរចំណេះដឹង បទពិសោធន៍ពីគ្នាទៅវិញទៅមក សម្រាប់ជាប្រយោជន៍ដល់ការអភិវឌ្ឍការបង្រៀនរបស់ខ្លួនឯងផង។

ក្នុងការអនុវត្តជាក់ស្តែង សាលាបានចាត់ឲ្យមានគ្រូឧទ្ទេសបង្គោល និងអ្នកសម្របសម្រួលតាមក្រុមសិក្សាមេរៀននីមួយៗ។ ការពិភាក្សាមានដំណើរការរលូនល្អ ហើយសមាជិកក្រុមទទួលបានចំណេះដឹងច្រើន ឬតិច គឺអាស្រ័យលើគុណភាពនៃការដឹកនាំសម្របសម្រួល ពីសំណាក់គ្រូឧទ្ទេសបង្គោល និងអ្នកសម្របសម្រួល។

ខាងក្រោមនេះជាលទ្ធផលដែលបង្ហាញពីការពេញចិត្ត របស់គ្រូទៅលើការដឹកនាំសម្របសម្រួលរបស់គ្រូឧទ្ទេសបង្គោល និងអ្នកសម្របសម្រួលក្រុមសិក្សាមេរៀន៖




ក្រាបទី១៦: ការពេញចិត្តលើការដឹកនាំរបស់គ្រូឧទ្ទេសបង្គោល

តួលេខនេះបង្ហាញថា គ្រូភាគច្រើនពេញចិត្តនឹងការដឹកនាំការសិក្សាមេរៀននៅក្នុងក្រុមរបស់ពួកគាត់ ដែលអាចបញ្ជាក់បានថាគ្រូឧទ្ទេសបង្គោលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងារសម្រាប់ក្រុមសិក្សាមេរៀននេះ។

ដោយឡែក សម្រាប់អ្នកសម្របសម្រួលក្រុមវិញ បង្ហាញលទ្ធផលដូចខាងក្រោម៖




ក្រាបទី១៧: ការពេញចិត្តចំពោះអ្នកសម្របសម្រួល

តាមរយៈលទ្ធផលខាងលើបង្ហាញថា គ្រូមានការពេញចិត្តចំពោះការសម្របសម្រួលរបស់អ្នកសម្របសម្រួលក្នុងក្រុមសិក្សាមេរៀនរបស់ពួកគាត់ណាស់។ អ្នកសម្របសម្រួលបានល្អអាចជួយឲ្យសមាជិកក្នុងក្រុមទទួលបានចំណេះដឹងថ្មីៗ បន្ថែមទៀត ជាពិសេសគឺធ្វើឲ្យការសិក្សាមេរៀនបានដំណើរការរលូនល្អ។

ដើម្បីឲ្យការពិភាក្សាប្រព្រឹត្តទៅដោយរលូន គ្រូបានគោរពនូវគោលការណ៍មួយចំនួន មានជាអាទិ៖ ការផ្តល់យោបល់ត្រូវផ្អែកលើភស្តុតាងជាក់ស្តែងពីការសង្កេតការបង្រៀន និងរៀន ការបញ្ជាក់ឲ្យច្បាស់ពីចំណុចត្រូវកែលម្អ ការរិះគន់ទៅលើអ្នកបង្រៀនត្រូវបានហាមឃាត់ ប្រធានក្រុមត្រូវរក្សានិងចែករបាយការណ៍ពិភាក្សាជូនដល់សមាជិកទាំងអស់។

ក្រាបទី១៨ ខាងក្រោមនេះ ជាលទ្ធផលនៃការស្រាវជ្រាវដែលបង្ហាញពីការអនុវត្តការពិភាក្សាលើការបង្រៀន និងរៀនរបស់គ្រូ៖




ក្រាបទី១៨: ការអនុវត្តការពិភាក្សាលើការបង្រៀន និងរៀន

តាមលទ្ធផលដែលស្តែងចេញក្នុងក្រាបខាងលើ សបញ្ជាក់ឲ្យឃើញថា គ្រូភាគច្រើនបំផុតគិតថា ការអនុវត្តការពិភាក្សាលើការបង្រៀន និងរៀន ធ្វើបានល្អ (91.3%) តែទន្ទឹមនឹងនេះក៏នៅមានគ្រូមួយចំនួនថាអនុវត្តមិនសូវបានល្អ (8.7%)។ មូលហេតុដែលគ្រូឧទ្ទេសយល់ថា ការអនុវត្តមិនសូវបានល្អនោះគឺ ដោយសារការចូលរួមមតិយោបល់ពីសំណាក់សមាជិកក្រុមសិក្សាមេរៀនមិនទាន់បានផុលផុស និងពេលខ្លះមានគ្រូអវត្តមានទៀតផង។

ចំពោះការអនុវត្តជាក់ស្តែង អ្នកសម្របសម្រួលបានចាត់ឲ្យមានលេខាកត់ត្រាមួយនាក់ ដែលជ្រើសរើសក្នុងចំណោមសមាជិកក្រុម មិនមែនជាអ្នកឡើងបង្រៀនសម្រាប់កត់ត្រារាល់ការពិភាក្សាទាំងអស់។ កំណត់ត្រានេះត្រូវរក្សាទុកនៅសាលាសម្រាប់ធ្វើជារបាយការណ៍ផ្ញើជូនថ្នាក់លើ និងដើម្បីជាការឆ្លុះបញ្ចាំងពីការរីកចម្រើនលើការកែលម្អការបង្រៀន និងរៀន និងការប្រែប្រួលគុណភាពនៃការពិភាក្សាពេញមួយឆ្នាំសិក្សា។ ជំហានបន្ទាប់មកទៀត គឺបានឲ្យគ្រូឧទ្ទេសដែលឡើងបង្រៀនបង្ហាញចំណាប់អារម្មណ៍អំពីការបង្រៀនរបស់គាត់ ដោយត្រូវពន្យល់ប្រាប់ពីចំណុចដែលគាត់គិតថាធ្វើបានល្អ និងចំណុចដែលគាត់គិតថាពិបាក។ តមក ទៀត សមាជិកក្រុមទាំងមូលពិភាក្សា

គ្នាអំពីការបង្រៀន និងរៀន ដោយសង្កត់ធ្ងន់លើចំណុចល្អ និងចំណុចត្រូវកែលម្អជាមួយគំនិតដែលអាចសាកល្បងបាន។ ត្រង់ចំណុចនេះ សមាជិកម្នាក់ៗត្រូវមានមតិយ៉ាងហោចមួយលើចំណុចល្អ និងចំណុចកែលម្អ អាចផ្តល់ជាឧទាហរណ៍បន្ថែម និងបង្កើតបរិយាកាសល្អក្នុងការពិភាក្សាជាមួយសមាជិកក្រុមដទៃទៀត។ ចុងក្រោយ ទើបបូកសរុបលទ្ធផលនៃការពិភាក្សា ហើយចែករំលែកដល់សមាជិកក្រុម ដើម្បីធ្វើជាមូលដ្ឋានក្នុងការកែលម្អការបង្រៀនរៀងៗខ្លួន។

សរុបមក ការអនុវត្តការពិភាក្សាលើការបង្រៀន និងរៀន មានដំណើរការរលូនល្អ ដោយសារមានការចាត់តាំងគ្រូឧទ្ទេសបង្គោល អ្នកសម្របសម្រួលក្នុងក្រុមឲ្យជួយសម្រួលដល់ការពិភាក្សាតាមលំដាប់សកម្មភាព ដើម្បីគ្រូទទួលបាននូវចំណេះដឹងថ្មីបន្ថែមសម្រាប់យកទៅអភិវឌ្ឍការបង្រៀនរបស់ខ្លួន។

**៤.៤.៣. បញ្ហាប្រឈម**

ទោះបីការអនុវត្តការពិភាក្សាការបង្រៀន និងរៀន ខាងលើមានភាពល្អប្រសើរហើយក៏ពិតមែន តែក៏នៅមានបញ្ហាប្រឈមខ្លះៗ ដែលកើតមានឡើងផងដែរ។

**ក. បញ្ហាការចូលរួម**

ថ្វីបើការចូលរួមមានចំនួនច្រើនហើយក៏ពិតមែន តែពេលខ្លះនៅមានគ្រូមួយចំនួនតូចអវត្តមានពីការប្រជុំ ពោលគឺការចូលរួមមិនបានទៀងទាត់នៅឡើយ។ ម្យ៉ាងវិញទៀត ដោយសារក្រុមនីមួយៗមានគ្រូចម្រុះមុខវិជ្ជាច្រើន ធ្វើឲ្យគ្រូមួយចំនួនមិនសូវមានមតិយោបល់ ព្រោះខុសឯកទេស មិនសូវយល់ខ្លឹមសារ និងវិធីបង្រៀនមេរៀននោះ។ ជាដំណោះស្រាយកន្លងមក គឺតម្រូវឲ្យគ្រូព្យាយាមរៀនសូត្រពីគ្នាទៅវិញទៅមក និងលើកទឹកចិត្តឲ្យគ្រូយកតែចំណុចណា ឬខ្លឹមសារណាដែលអាចយកទៅអនុវត្តក្នុងការបង្រៀនមុខវិជ្ជារបស់ខ្លួន។

**ខ. បញ្ហាការគាំទ្រពីគណៈគ្រប់គ្រងសាលា**

បញ្ហាប្រឈមនៅត្រង់ចំណុចនេះគឺថា សាលានៅពុំទាន់មានលទ្ធភាពគ្រប់គ្រាន់នៅឡើយ នៅខ្វះធនធានសម្ភារៈ និងថវិកា សម្រាប់លើកទឹកចិត្តអ្នកចូលរួម។

ដំណោះស្រាយក្នុងឆ្នាំសិក្សាកន្លងមក គឺគណៈគ្រប់គ្រងបានទទួលជំនួយថវិកាពីគម្រោង Cambodian Charitably Trust (CCT) រយៈពេល ១៦ សប្តាហ៍ ក្រៅពីនោះ គណៈគ្រប់គ្រងបានប្រើថវិកាកម្មវិធីរបស់សាលាផ្ទាល់សម្រាប់ដោះស្រាយអាហារសម្រន់ និងសម្ភារៈតិចតួច តែថវិកានេះជួយបានតែមួយផ្នែកតូចប៉ុណ្ណោះ។ យ៉ាងណាក៏ដោយ គណៈគ្រប់គ្រងនៅតែព្យាយាមដោះស្រាយជូនបានមួយចំណែកដែរ។

## ៤.៥. ការធ្វើសកម្មភាពកែលម្អបន្ត (Action)

សកម្មភាពកែលម្អបន្ត គឺជាការអនុវត្តនូវអ្វីៗដែលបានរៀនពីការសិក្សាមេរៀននៅក្នុងដំណាក់កាលមុន ដោយសមាជិកក្រុមម្នាក់ៗត្រូវបានលើកទឹកចិត្តឲ្យអនុវត្តការកែលម្អការបង្រៀនរបស់ខ្លួនជាបន្ត។ ក្នុងផ្នែកនេះ អ្នកស្រាវជ្រាវនឹងលើកឡើងពីការយល់ដឹង ការអនុវត្ត និងបញ្ហាប្រឈមមកបង្ហាញដូចតទៅ៖

### ៤.៥.១. ការយល់ដឹងលើសកម្មភាពកែលម្អបន្ត

ក្រោយពីបានប្រជុំកែលម្អលើការបង្រៀន និងរៀនរួចមក គ្រូត្រូវយកគំនិតល្អៗពីការសិក្សាមេរៀនមកអនុវត្តក្នុងការងាររបស់ខ្លួន ដើម្បីជួយឲ្យការបង្រៀនបានប្រសើរឡើង។ ខាងក្រោមនេះជាលទ្ធផលនៃការយល់ដឹងរបស់គ្រូលើសកម្មភាពកែលម្អបន្ត៖




ក្រាបទី១៩: ការយល់ដឹងរបស់គ្រូលើសកម្មភាពកែលម្អបន្ត

តាមលទ្ធផលក្រាបទី១៩ បង្ហាញថា គ្រូឧទ្ទេសមានការយល់ដឹងច្រើនលើសកម្មភាពកែលម្អបន្ត ដោយពួកគាត់ភាគច្រើនបានចូលរួមការអនុវត្តការសិក្សាមេរៀនពីរបីឆ្នាំមកហើយ និងធ្លាប់បានយកអនុសាសន៍ខ្លះមកអនុវត្តក្នុងការបង្រៀនផងដែរ។ ដោយឡែក គ្រូឧទ្ទេសមួយចំនួនតូចនៅមិនទាន់យល់ច្បាស់ ដោយហេតុថា ពួកគាត់មិនសូវបានអនុវត្តការងារនេះញឹកញាប់ ណាមួយត្រូវបង្រៀនច្រើនមុខវិជ្ជាទៀត។

### ៤.៥.២. ការអនុវត្តសកម្មភាពកែលម្អបន្ត

ដើម្បីធានាប្រសិទ្ធភាពការរៀនរបស់សិស្ស សមាជិកក្រុមសិក្សាមេរៀនត្រូវបានជំរុញឲ្យអនុវត្តការកែលម្អបន្ត។ គ្រូត្រូវសាកល្បងនូវអ្វីដែលបានរៀនសូត្រ ដោយត្រូវចងចាំចំណុចដែលបានពិភាក្សាគ្នា ដើម្បីយកមកអនុវត្តឲ្យការបង្រៀនរបស់ខ្លួនល្អឡើង។ បន្ទាប់ពីបានបញ្ចប់ដំណើរការដូចបានរៀបរាប់ខាងលើនេះមក គ្រូតម្រូវឲ្យរៀបចំផែនការអនុវត្តការសិក្សាមេរៀននៅវដ្តបន្តបន្ទាប់ទៀត តាមជំហានទីមួយៗដូចខាងលើមកវិញ។

ក្រាបទី២០ ខាងក្រោមនេះជាលទ្ធផលនៃការអនុវត្តសកម្មភាពកែលម្អបន្ត ដែលអ្នកស្រាវជ្រាវទទួលបានពីភាគសំណាក៖




ក្រាបទី២០: ការអនុវត្តសកម្មភាពកែលម្អបន្តរបស់គ្រូ

ផ្អែកតាមក្រាបខាងលើបង្ហាញថា គ្រូភាគច្រើនបានអនុវត្តសកម្មភាពកែលម្អបន្ត បន្ទាប់ពីបានទទួលអនុសាសន៍ល្អពីការសិក្សាមេរៀននៅក្នុងដំណាក់កាលមុន។ ម្យ៉ាងទៀត អាចនិយាយបានថា គ្រូមានការប្រែប្រួលការបង្រៀនតាមរយៈការសាកល្បង

អនុវត្តវិធីបង្រៀនថ្មីៗ ដែលទទួលបានពីការសិក្សាស្រាវជ្រាវមេរៀន ហើយជាបណ្តើរៗ នឹងធ្វើឲ្យមានការប្រែប្រួលគុណភាពបណ្តុះបណ្តាលនាពេលខាងមុខ។

ទោះបីយ៉ាងណាក៏ដោយ នាយកសាលាត្រូវយកចិត្តទុកដាក់ និងផ្តល់ការគាំទ្របន្ថែមទៀតទៅលើសកម្មភាពកែលម្អបន្តនេះ ព្រោះនេះជាឱកាសល្អមួយសម្រាប់វាយតម្លៃជាវិជ្ជមានលើការអនុវត្តរបស់គ្រូដែលបានមកពីការសិក្សាមេរៀន។ នាយកសាលាត្រូវកែទម្លាប់គ្រូ និងព្យាយាមលើកទឹកចិត្តឲ្យគគ្រូហ៊ានបញ្ចេញមតិយោបល់ផ្លាស់ប្តូរគ្នាទៅវិញទៅមក។ ដើម្បីជាសក្ខីភាពចំពោះការយកចិត្តទុកដាក់ និងការគាំទ្រពីគណៈគ្រប់គ្រងសាលាទៅលើការអនុវត្តសកម្មភាពកែលម្អបន្តនៃការសិក្សាមេរៀន អ្នកស្រាវជ្រាវសូមលើកមកបង្ហាញតាមរយៈក្រាបដូចខាងក្រោម៖




ក្រាបទី២១: ការគាំទ្រពីគណៈគ្រប់គ្រងសាលា

តាមរយៈក្រាបខាងលើបង្ហាញថា គណៈគ្រប់គ្រងសាលាពិតជាបានយកចិត្តទុកដាក់ និងផ្តល់ការគាំទ្រពេញទំហឹង ដល់សកម្មភាពកែលម្អបន្តនៃការសិក្សាស្រាវជ្រាវមេរៀននៅក្នុងសាលា។ ក្នុងបរិយាកាសបែបនេះនឹងធ្វើឲ្យការបង្រៀនរបស់គ្រូ និងការរៀនរបស់សិស្សមានការប្រែប្រួលគុណភាពជាក់ជាពុំខាន។

#### ៤.៥.៣. បញ្ហាប្រឈម

ថ្វីបើការអនុវត្តសកម្មភាពកែលម្អបន្តខាងលើមានដំណើរការល្អ និងមានការគាំទ្រពីគណៈគ្រប់គ្រងសាលាក៏ពិតមមែន តែក៏នៅមានបញ្ហាប្រឈមខ្លះៗផងដែរ។

ការអនុវត្តសកម្មភាពកែលម្អបន្តរបស់គ្រូនៅពុំទាន់បានពេញលេញល្អ ដោយគ្រូបានផ្តោតលើការបញ្ចប់មេរៀនក្នុងកម្មវិធីបណ្តុះបណ្តាល ជាជាងការប្រើវិធីបង្រៀនដែលបានពីការពិភាក្សាក្នុងការសិក្សាមេរៀន។

ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែងនេះ ពុំមានការពិនិត្យតាមដានញឹកញាប់ពីមន្ត្រីជំនាញរបស់មន្ទីរ និងពីក្រសួងអប់រំ យុវជន និងកីឡា ជាហេតុធ្វើឲ្យការអនុវត្តពុំសូវទទួលបានជោគជ័យច្រើនក្នុងការបង្រៀន។

គណៈគ្រប់គ្រងសាលានៅពុំទាន់មានលទ្ធភាពច្រើន ក្នុងការជួយគាំទ្រលើការសិក្សាមេរៀនទាំងថវិកា និងសម្ភារៈ។

សរុបមក ក្នុងការធ្វើសកម្មភាពកែលម្អបន្តនេះ គ្រូមានការយល់ដឹងល្អ និងមានការអនុវត្តល្អ តែក៏នៅមានបញ្ហាប្រឈមខ្លះៗតាមមកផងដែរ ដែលទាមទារឲ្យគណៈគ្រប់គ្រងសាលា និងអ្នកពាក់ព័ន្ធនានាចូលរួមចំណែកជួយគាំទ្របន្ថែមទៀត។

### ៤.៦. លទ្ធផលសិក្សារបស់គរុសិស្ស

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវបានសិក្សាទៅលទ្ធផលសិក្សារបស់គរុសិស្សជំនាន់ទី៣៦ និងទី៣៧ ក្នុងឆ្នាំសិក្សា ២០១៧-២០១៨ និង២០១៨-២០១៩ ព្រោះឆ្នាំសិក្សានេះជារយៈពេលដែលគ្រូនៅមជ្ឈមណ្ឌលគរុកោសល្យភាមិភាគស្ទឹងត្រែង មានការអនុវត្តការសិក្សាមេរៀន។ ក្នុងការសិក្សានេះ អ្នកស្រាវជ្រាវបានលើកយកលទ្ធផលនៃការធ្វើកម្មសិក្សាគរុកោសល្យ និង លទ្ធផលសិក្សាប្រចាំឆ្នាំមកឆ្លុះបញ្ចាំងមើលវឌ្ឍនភាព ដូចខាងក្រោម៖

#### ៤.៦.១. លទ្ធផលកម្មសិក្សា

នៅក្នុងចំណុចនេះ អ្នកស្រាវជ្រាវបានសិក្សាទៅលើលទ្ធផលកម្មសិក្សាគរុកោសល្យ របស់គរុសិស្សជំនាន់ទី៣៦ ឆ្នាំទី១ ឆ្នាំសិក្សា២០១៧-២០១៨ និងឆ្នាំទី២ ឆ្នាំសិក្សា២០១៨-២០១៩ ដោយប្រៀបធៀបលទ្ធផលសម្រេចបានរបស់គរុសិស្សក្នុងជំនាន់តែមួយ តែឆ្នាំសិក្សាខុសគ្នា គឺលទ្ធផលកម្មសិក្សាឆ្នាំទី១ និងឆ្នាំទី២៖




ក្រាបទី២២: លទ្ធផលកម្មសិក្សារបស់គរុសិស្សជំនាន់ទី៣៦

ទិន្នន័យនេះបង្ហាញឲ្យឃើញថា គរុសិស្សជំនាន់ទី៣៦ រៀននៅឆ្នាំទី២ ឆ្នាំសិក្សា២០១៨-២០១៩ មានលទ្ធផលកម្មសិក្សាគរុកោសល្យល្អជាងលទ្ធផលដែលពួកគេទទួលបាននៅឆ្នាំទី១ ឆ្នាំសិក្សា២០១៧-២០១៨ ដោយនៅឆ្នាំសិក្សា២០១៧-២០១៨ មានត្រឹមតែកម្រិតល្អបង្គួរប៉ុណ្ណោះ (97.97%) ចំណែកនៅឆ្នាំសិក្សា២០១៨-២០១៩ មានលទ្ធផលកម្មសិក្សាដល់កម្រិតល្អ (51.42%)។ នេះសបញ្ជាក់ថា លទ្ធផលកម្មសិក្សារបស់គរុសិស្សជំនាន់ទី៣៦ មានការរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំ។ ភាពរីកចម្រើននេះអាចថាមកពីគ្រូឧទ្ទេសបានខិតខំបង្រៀនប្រសើរជាងមុន តាមរយៈការពិភាក្សាដែលបានមកពីការប្រជុំការសិក្សាស្រាវជ្រាវមេរៀន ឬអាចនិយាយបានថា ដោយសារគ្រូឈរថ្នាក់មានការយកចិត្តទុកដាក់លើការកម្មសិក្សាការី-ការិនីជាងមុន ព្រោះគ្រូឈរថ្នាក់ក៏ជាអ្នកដែលបានចូលរួមអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែងដែរ ហើយគោលបំណងនៃការចូលរួមនេះ គឺដើម្បីជំរុញការធ្វើកម្មសិក្សារបស់គរុសិស្សឲ្យមានភាពស៊ីចង្វាក់គ្នារវាងសាលាគរុកោសល្យនិងសាលាសហការ។

ម្យ៉ាងវិញទៀត បើធ្វើការសិក្សាលើលទ្ធផលនៃកម្មសិក្សាគរុកោសល្យរបស់គរុសិស្សជំនាន់ទី៣៦ ឆ្នាំទី១ និងគរុសិស្សជំនាន់ទី៣៧ ឆ្នាំទី១ ដែលស្ថិតក្នុងឆ្នាំសិក្សាផ្សេងគ្នាលទ្ធផលបង្ហាញដូចខាងក្រោម៖




ក្រាបទី២៣: លទ្ធផលកម្មសិក្សាគរុសិស្សជំនាន់ទី៣៦ និង៣៧

លទ្ធផលនេះបង្ហាញថា គរុសិស្សជំនាន់ទី៣៧ មានកម្រិតលទ្ធផលកម្មសិក្សាល្អជាងកម្រិតលទ្ធផលរបស់គរុសិស្សជំនាន់ទី៣៦។ តាមទិន្នន័យ លទ្ធផលកម្មសិក្សារបស់គរុសិស្ស ជំនាន់ទី៣៦ មានកម្រិតមធ្យម 2.03% និងកម្រិតល្អបង្គួរ 97.97% ពុំមានកម្រិតល្អទេ ខុសពីលទ្ធផលកម្មសិក្សាគរុសិស្សជំនាន់ទី៣៧ ដែលពុំមានកម្រិតមធ្យម តែមានកម្រិតល្អបង្គួរ 14.44% និងកម្រិតល្អ 85.56%។ ទាំងនេះសបញ្ជាក់ពីវឌ្ឍនភាពនៃការធ្វើកម្មសិក្សាគរុកោសល្យរបស់គរុសិស្សជំនាន់ក្រោយ ដែលអាចនិយាយបានថាជាលទ្ធផលបានមកពីការសិក្សាមេរៀនរបស់គ្រូនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង និងគ្រូនៅតាមសាលាសហការក៏ថាបាន។

### ៤.៦.២. លទ្ធផលសិក្សាប្រចាំឆ្នាំ

ខាងក្រោមនេះ អ្នកស្រាវជ្រាវនឹងលើកបង្ហាញពីលទ្ធផលសិក្សាប្រចាំឆ្នាំរបស់គរុសិស្សជំនាន់ទី៣៦ ឆ្នាំទី១ ឆ្នាំសិក្សា២០១៧-២០១៨ និងឆ្នាំទី២ ឆ្នាំសិក្សា២០១៨-២០១៩៖




ក្រាបទី២៤: លទ្ធផលសិក្សារបស់គរុសិស្សជំនាន់ទី៣៦

តាមក្រាបខាងលើ លទ្ធផលសិក្សារបស់គរុសិស្សជំនាន់ទី៣៦ នៅឆ្នាំសិក្សា ២០១៧-២០១៨ និង២០១៨-២០១៩ មានការប្រែប្រួលតិចតួចតែប៉ុណ្ណោះ គឺនៅត្រង់និទ្ទេសល្អបង្គួរ។ ចំណែកនិទ្ទេសល្អ គឺមិនខុសគ្នាទេ (0.95%) រីឯនិទ្ទេសមធ្យមមានការថយចុះបន្តិច។

មួយវិញទៀត បើធ្វើការសិក្សាទៅលើលទ្ធផលសិក្សាប្រចាំឆ្នាំរបស់គរុសិស្សជំនាន់ទី៣៦ និង៣៧ លទ្ធផលបង្ហាញឲ្យឃើញដូចខាងក្រោម៖




ក្រាបទី២៥: លទ្ធផលសិក្សារបស់គរុសិស្សជំនាន់ទី៣៦ និង៣៧

ទិន្នន័យក្នុងក្រាបខាងលើបង្ហាញថា គរុសិស្សជំនាន់ទី៣៧ មានលទ្ធផលសិក្សាល្អជាងគរុសិស្សជំនាន់ទី៣៦ ដែលអាចបញ្ជាក់តាមក្រាបទី២៥។ គរុសិស្សជំនាន់ទី៣៦ មាននិទ្ទេសមធ្យម 3.80% ខណៈដែលគរុសិស្សជំនាន់ទី៣៧ 0.0% រីឯនិទ្ទេសល្អបង្គួរ គរុសិស្សជំនាន់ទី៣៦មាន 95.23% ច្រើនជាងគរុសិស្សជំនាន់ទី៣៧ ដែលមាន 72.26% តែនិទ្ទេសល្អវិញ គរុសិស្សជំនាន់ទី៣៧ មានរហូតដល់ 27.74% ខណៈដែលគរុសិស្សជំនាន់ទី៣៦ មានតែ 0.95% តែប៉ុណ្ណោះ។ ទាំងនេះពិតជាបញ្ជាក់ឲ្យឃើញថាលទ្ធផលសិក្សារបស់គរុសិស្សនៅឆ្នាំបន្ទាប់មានវឌ្ឍនភាពកើនឡើងជាលំដាប់។

សរុបមក លើផ្នែកលទ្ធផលសិក្សារបស់គរុសិស្សនេះ ពិតជាមានការប្រែប្រួលទាំងលទ្ធផលនៃការធ្វើកម្មសិក្សាគរុកោសល្យ និងលទ្ធផលសិក្សាប្រចាំឆ្នាំ ដែលអាចនិយាយបានថា គុណភាពនៃការបង្រៀនរបស់គ្រូមានភាពប្រសើរជាងមុនយ៉ាងពិតប្រាកដ។ ដូច្នេះ ដើម្បីធានានិរន្តភាពនៃការសិក្សាស្រាវជ្រាវមេរៀនរបស់គ្រូឧទ្ទេសនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង តើលោកគ្រូអ្នកគ្រូឧទ្ទេសមានទស្សនៈយល់ឃើញជារួមដូចម្ដេចខ្លះ? តើពួកគាត់មានសំណូមពរបែបណាខ្លះ?

## ៤.៧. ទស្សនៈយល់ឃើញជារួម

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវបានប្រមូលគំនិតយល់ឃើញរបស់ភាគសំណាកមករៀបរៀងជាអត្ថបទស្រាវជ្រាវទៅតាមខ្លឹមសារ ដូចខាងក្រោម៖

### ៤.២.១. ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនក្នុងសាលារៀន

ជារួម អ្នកស្រាវជ្រាវបានយកគំនិតយល់ឃើញរបស់ភាគសំណាកមកវិភាគនិងរៀបចំចាត់ជាក្រុមគំនិត ដូចខាងក្រោម៖

-ការអនុវត្តការសិក្សាមេរៀននៅក្នុងសាលារៀនជាការល្អបំផុត ពីព្រោះវាបានជួយឲ្យការបង្រៀនរបស់គ្រូម្នាក់ប្រសើរជាងមុន មានប្រសិទ្ធភាពជាងមុន ដោយគ្រូៗបានរៀនសូត្រពីគ្នាទៅវិញទៅមក ចែករំលែកបទពិសោធន៍គ្នា និងជួយបំពេញរាល់ចំណុចខ្វះខាតរបស់គ្រូ។ ម្យ៉ាងទៀត វាជួយទាញបម្រុងប្រយ័ត្នរបស់គ្រូតាមមុខវិជ្ជា និងផ្តល់ផលជាវិជ្ជាមានដល់គ្រូតាមរយៈការជួយលើកកម្ពស់សមត្ថភាពគ្រូបង្រៀន ឲ្យមានការរីកចម្រើនទាំងផ្នែកចំណេះដឹង និងផ្នែកវិធីសាស្ត្រ ដែលជាការជួយពង្រឹងបន្ថែមលើសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន ដើម្បីធានាដល់គុណភាពបណ្តុះបណ្តាលគ្រូ។

-សកម្មភាពសិក្សាស្រាវជ្រាវមេរៀនបានជួយពង្រឹងសាមគ្គីភាព និងបង្កើនទំនាក់ទំនងការងារផ្សេងៗនៅក្នុងអង្គភាព។

-គរុសិស្សទទួលបានវិធីបង្រៀន និងបទពីសោធល្អៗ ផងដែរពីការចូលរួមការសិក្សាស្រាវជ្រាវមេរៀន សម្រាប់យកទៅអនុវត្តក្នុងការបង្រៀនរបស់ខ្លួន។ វាក៏ជួយឲ្យគរុសិស្សយល់ខ្លឹមសារមេរៀនកាន់តែច្បាស់លាស់ តាមរយៈការសិក្សាស្រាវជ្រាវដោយខ្លួនឯង។

និយាយឲ្យខ្លី គឺថាការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅក្នុងសាលាបានជួយកសាងសមត្ថភាពគ្រូក្នុងការបង្រៀន បង្កើនសាមគ្គីភាពក្នុងសាលារៀន និងជួយឲ្យគរុសិស្សទទួលបានចំណេះដឹងរឹងមាំ។

### ៤.៤.២ កម្រិតនៃការជួយអភិវឌ្ឍការបង្រៀន

គ្រូៗនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង មានទស្សនៈយល់ឃើញថា ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនពិតជាបានជួយអភិវឌ្ឍការបង្រៀនមែន ដោយបានលើកជាហេតុផលថា ការសិក្សាស្រាវជ្រាវមេរៀន បានជួយឲ្យមានការរៀនសូត្រចំណេះដឹងថ្មីៗ និងបទពិសោធន៍ល្អៗពីមិត្តរួមក្រុម ដូចជា គ្រូទទួលបានវិធីបង្រៀនប្លែកៗ បទពិសោធល្អៗ សម្រាប់បន្តដល់គរុសិស្ស បានជួយបន្ថែមចំណេះដឹងមានស្រាប់ និងចំណេះដឹងពីមុខវិជ្ជាដទៃទៀត ព្រមទាំងបានបន្សល់ទុកនូវស្នាដៃស្រាវជ្រាវនានា បទពិសោធនៃការបង្រៀន និងកិច្ចតែងការបង្រៀនល្អៗ។ ម្យ៉ាងទៀត វាក៏ជួយឲ្យគ្រូយល់ពីរបៀបបង្រៀនមេរៀននីមួយៗ មានប្រសិទ្ធភាព ងាយស្រួលបង្រៀនជាងមុន តាមរយៈការផ្លាស់ប្តូរយោបល់គ្នា មានចំណុចត្រូវកែលម្អ និងរៀនសូត្របន្ថែមពីគ្នា ជាហេតុធ្វើឲ្យគ្រូមានការប្រែប្រួលក្នុងការបង្រៀនសិស្ស ដោយមានការសិក្សាស្រាវជ្រាវទាំងគ្រូ ទាំងគរុសិស្ស ហើយគរុសិស្សទទួលបានចំណេះដឹងល្អជាងកាលមិនទាន់អនុវត្តការសិក្សាមេរៀន គរុសិស្សសប្បាយរីករាយក្នុងការសិក្សា។

និយាយជារួម ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនពិតជាបានជួយគ្រូច្រើនផ្នែក អភិវឌ្ឍវិជ្ជជីវៈការបង្រៀនរបស់គ្រូបានល្អប្រសើរជាងមុនខ្លាំង ពិសេសផ្នែកវិធីសាស្រ្តបង្រៀន ដែលជាការលើកកម្ពស់ការបង្រៀនរបស់គ្រូ ដោយរួមបញ្ចូលទាំងការផលិតសម្ភារៈឧបទេស សម្រាប់ដំណើរការបង្រៀនផង។

### ៤.៤.៣ ការជួយអភិវឌ្ឍការបង្រៀននិងរៀនក្នុងសាលា

ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនបានធ្វើឲ្យគ្រូចាប់ផ្តើមយល់ដឹងពីសារៈសំខាន់នៃការសិក្សាស្រាវជ្រាវមេរៀន គ្រូយកចិត្តទុកដាក់បង្រៀនជាងមុន គ្រូផលិតសម្ភារៈបង្រៀនបានល្អជាងមុន ជាពិសេស គ្រូផ្លាស់ប្តូរឥរិយាបទជាបណ្តើរក្នុងការបង្រៀនពីបែបប្រពៃណីមកជា ការបង្រៀនបែបរិះរក បែបស្រាវជ្រាវ។ មួយវិញទៀត ការ

សិក្សាមេរៀនធ្វើឲ្យការបង្រៀនរបស់គ្រូមានការផ្លាស់ប្តូរ និងអភិវឌ្ឍល្អជាងមុន ដោយគ្រូមានគំនិតច្នៃប្រឌិតជាងមុន។ ទាំងនេះនឹងធ្វើឲ្យគ្រូទាំងអស់ក្នុងសាលាមានសមត្ថភាពវិជ្ជាជីវៈល្អឡើង មានគុណភាពបង្រៀនល្អ ដោយគ្រូមានការប្រែប្រួលច្រើនពីចំណេះដឹងចាស់មកចំណេះដឹងថ្មី។

ចំណែកឯការរៀនរបស់គរុសិស្សក៏នឹងទទួលបានលទ្ធផលល្អដែរ។ គរុសិស្សរៀនដោយមានការទទួលខុសត្រូវ តាមរយៈវិធីសាស្រ្តក្នុងការបង្រៀនល្អៗ វិធីសាស្រ្តបង្រៀនថ្មីៗ ជាមូលហេតុនាំឲ្យគរុសិស្សទទួលបានបំណិនល្អពីគ្រូ មានការចូលរួម និងការសហការ ទើបគរុសិស្សទទួលបានការបណ្តុះបណ្តាលល្អ និងមានគុណភាពខ្ពស់។

ម្យ៉ាងទៀត ការអនុវត្តការសិក្សាមេរៀន នឹងធ្វើឲ្យសាលាប្រែក្លាយជាសាលាដែលមានគុណភាពល្អក្នុងការអប់រំបណ្តុះបណ្តាល នឹងអាចជាសាលាដែលផ្តល់នូវគុណភាពអប់រំបណ្តុះបណ្តាលខ្ពស់ គរុសិស្សចូលចិត្តរៀន មានភាពស្ទិទ្ធស្នាលក្នុងការសិក្សា ដោយសារសកម្មភាពបង្រៀន និងរៀនមានលក្ខណៈសកម្ម។ ទៅថ្ងៃខាងមុខ ទីនេះនឹងក្លាយជាសាលា ដែលមានគុណវុឌ្ឍិគ្រូបង្រៀនល្អ គ្រូមានសមត្ថភាពគ្រប់គ្រាន់ និងគុណភាពបណ្តុះបណ្តាល ក្រោមការជំរុញលើកទឹកចិត្តពីគណៈគ្រប់គ្រងសាលា ដើម្បីលើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀនឲ្យកាន់តែប្រសើរឡើង។

សរុបមក ការអនុវត្តការសិក្សាមេរៀនពិតជាបានជួយកសាងសមត្ថភាពវិជ្ជា-ជីវៈគ្រូបង្រៀន ដើម្បីពង្រឹងលើការងារបង្រៀន និងរៀន ដែលអាចឲ្យគរុសិស្សទទួលបានចំណេះដឹងរឹងមាំ តាមរយៈការអនុវត្តវិធីបង្រៀនមេរៀនបែបសកម្ម។ ការសិក្សាស្រាវជ្រាវមេរៀននេះ ក៏នឹងជួយប្រែក្លាយមុខមាត់សាលាទៅជាសាលាដែលមានគុណភាពល្អក្នុងការបណ្តុះបណ្តាលផងដែរ។

### ៤.៤.៤ ការជួយអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា

ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននេះ មានផលជាវិជ្ជមានជួយដល់ការអភិវឌ្ឍវិស័យអប់រំនៅក្នុងសាលា និងនៅក្នុងប្រទេសកម្ពុជា ដោយសារការសិក្សាមេរៀនជួយលើកកម្ពស់ការបណ្តុះបណ្តាលគ្រូបង្រៀននៅតាមសាលាគរុកោសល្យ ដែលអាចឲ្យគរុសិស្សយកចំណេះដឹងនេះ ទៅអនុវត្តក្នុងវិជ្ជាជីវៈគ្រូបង្រៀនរបស់ខ្លួននាពេលខាងមុខ។ សកម្មភាពបង្រៀនដែលកើតចេញពីការសិក្សាមេរៀនបែបនេះនឹងជួយបង្កើនចំណេះដឹងដល់គ្រូ និងសិស្ស ជួយឲ្យសិស្សទទួលបានចំណេះដឹងពេញលេញ ក្លាហានតាមរយៈការរៀនដោយមានម្ចាស់ការ រៀនតាមបែបសកម្ម ចាប់បានខ្លឹមសារមេរៀន និង

ទទួលបានចំណេះដឹងល្អៗ ដែលនឹងជួយធ្វើឲ្យគុណភាពអប់រំបានប្រសើរឡើងនាពេលអនាគត់។

ម្យ៉ាងវិញទៀត សកម្មភាពអនុវត្តការសិក្សាមេរៀនក៏នឹងជួយឲ្យការបណ្តុះបណ្តាលមានប្រសិទ្ធភាព ដោយសារគ្រូកាន់តែខិតខំប្រឹងប្រែង កែលម្អការបង្រៀនរបស់ខ្លួនឲ្យកាន់តែអភិវឌ្ឍឈានឡើង ដើម្បីឲ្យសាលារៀនកាន់តែរីកចម្រើនថែមទៀតផ្នែកបច្ចេកទេសបង្រៀន ក្នុងការជួយបង្កើនធនធានមនុស្ស និងជួយអភិវឌ្ឍវិស័យអប់រំនៅកម្ពុជាកាន់តែមានគុណភាព ប្រសិទ្ធភាព និងរីកចម្រើនដូចប្រទេសក្នុងតំបន់ ព្រមទាំងឆ្លើយតបនឹងគោលនយោបាយអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ជារួម ការសិក្សាស្រាវជ្រាវមេរៀនពិតជាជួយដល់ការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា តាមរយៈការបង្កើនសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន ស្របតាមកំណែទម្រង់វិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រង់ចំណុចទី៤ ស្តីពីការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន។

### ៤.៤.៥ គំនិតដែលធ្វើឲ្យការអនុវត្តប្រសើរឡើង

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវបានប្រមូលផ្តុំគំនិតយល់ឃើញរបស់ភាគសំណាក រួចយកមករៀបចំសរសេរជាលទ្ធផលនៃការស្រាវជ្រាវ ដូចខាងក្រោម៖

១.ភាគសំណាកបានបញ្ចេញទស្សនៈយល់ឃើញថា ដើម្បីឲ្យការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនបានល្អប្រសើរនោះ គួរតែប្បីមានការយកចិត្តទុកដាក់ពីក្រសួងអប់រំ យុវជន និងកីឡា ដៃគូសហការ និងគណៈគ្រប់គ្រងសាលា ក្នុងរូបភាពមួយដែលមានការលើកទឹកចិត្ត ជាថវិកាសម្រាប់អ្នកចូលរួម អ្នកត្រូវឡើងបង្រៀន និងអ្នកធ្វើផែនការ។ ពួកគាត់យល់ថា ការជួយបង្កើនថវិកាឧបត្ថម្ភដល់អ្នកចូលរួមទាំងអស់ឲ្យបានសមរម្យ នឹងជួយឲ្យការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនក្នុងសាលាកាន់តែប្រសើរឡើង។ មួយវិញទៀត ពួកគាត់បានយល់ថា ការគាំទ្រផ្នែកសម្ភារៈផ្សេងៗពីក្រសួងអប់រំ យុវជន និងកីឡាក្តី ដៃគូសហការក្តី ឬពីគណៈគ្រប់គ្រងសាលាក្តី សុទ្ធតែជាបច្ច័យល្អក្នុងការជំរុញការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន។

២.ជាមួយគ្នានេះដែរ ភាគសំណាកបានផ្តល់ទស្សនៈយល់ឃើញថា ក្រៅពីថវិកា និងសម្ភារៈ ក្រសួងអប់រំ និងដៃគូសហការគួររៀបចំឲ្យមានវគ្គបំប៉នផ្នែកវិធីសាស្ត្របង្រៀនបន្ថែមទៀត ដើម្បីជាទុនឲ្យគ្រូមានចំណេះដឹងផ្នែកវិធីសាស្ត្របង្រៀនសំបូរបែបសម្រាប់ប្រើក្នុងការបង្រៀន និងសម្រាប់ចែករំលែកគ្នាក្នុងក្រុមពេលប្រជុំសិក្សាស្រាវ-ជ្រាវមេរៀន។ ជាការបន្ថែម ពួកគាត់បានស្នើសុំឲ្យមានការបំប៉ននូវខ្លឹមសារការសិក្សា

ស្រាវជ្រាវមេរៀនបន្ថែមទៀត ដើម្បីពង្រឹងចំណេះដឹងមានស្រាប់របស់គ្រូឧទ្ទេសនៅសាលាគរុកោសល្យ។

៣.ម្យ៉ាងទៀត គណៈគ្រប់គ្រងសាលាគួរចេញជាវិញ្ញាបនបត្របញ្ជាក់ពីការចូលរួមរបស់គាត់ក្នុងរយៈពេលមួយឆ្នាំសិក្សា ដើម្បីបង្ហាញពីការយកចិត្តទុកដាក់ក្នុងការចូលរួម។ ឬអាចចេញជាលិខិតសរសើរសម្រាប់ពួកគាត់ក៏បាន។ ក្រៅពីនេះ គណៈគ្រប់គ្រងសាលាគួរស្វែងរកប្រភពថវិកា សម្រាប់ធ្វើទស្សនកិច្ចសិក្សាស្វែងយល់លើការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនជាមួយសាលាគរុកោសល្យដទៃ ឬសាលារៀនចំណេះទូទៅណាដែលមានការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន ដើម្បីដកស្រង់បទពិសោធ និងរៀនសូត្រពីគ្នាទៅវិញទៅមក សំដៅធ្វើឲ្យការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនក្នុងសាលាបានប្រសើរឡើង។ ក្នុងករណីមានបញ្ហាកើតមានឡើងត្រូវពិភាក្សាគ្នារកដំណោះស្រាយ។

៤.ទិន្នន័យពីភាគសំណាកយល់ឃើញថា ដើម្បីឲ្យការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនបានល្អប្រសើរជាងនេះ គ្រូត្រូវចូលរួមទាំងអស់គ្នា និងយកចិត្តទុកដាក់រៀនសូត្រពីគ្នាទៅវិញទៅមក ចេះចែករំលែកចំណេះដឹងនិងបទពិសោធន៍ឲ្យគ្នា មានភាពអត់ធ្មត់ស្រាវជ្រាវ និងអនុវត្តការសិក្សាស្រាវជ្រាវមេរៀនជាប្រចាំ និងចូលរួមឲ្យបានទៀងទាត់តាមផែនការ ដែលខាងសាលាក៏ដូចជាក្រុមសិក្សាមេរៀនតាមមុខវិជ្ជាបានដាក់ជូន។ ក្រៅពីនេះ ពួកគាត់ក៏សុំឲ្យមានការចូលរួមពីគ្រូសាលាសហការឲ្យបានច្រើនផងដែរ ព្រោះជាសាលាដែលគរុសិស្សត្រូវធ្វើកម្មសិក្សា។

ជារួមគំនិតយល់ឃើញខាងលើជាគំនិតល្អ និងមានប្រយោជន៍ខ្លាំងសម្រាប់ធ្វើជាមូលដ្ឋានក្នុងការដឹកនាំការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនផង និងជាធាតុចូលសម្រាប់ប្រើក្នុងការធ្វើផែនការផង។ សរុបមក ការបំប៉នផ្នែកវិធីសាស្ត្របង្រៀនជាការងារមួយចាំបាច់ក្នុងការលើកកម្ពស់សមត្ថភាពបង្រៀនរបស់គ្រូ។ សមត្ថភាពគ្រូបង្រៀនជាសមាសភាគមួយនៅក្នុងកំណែទាំង ១៥ ចំណុចរបស់ក្រសួងអប់រំ យុវជន និងកីឡា គុណភាពគ្រូល្អធ្វើឲ្យគុណភាពរៀនរបស់សិស្សល្អដូចគ្នាដែរ។ ដូចនេះ ការចូលរួមសិក្សាស្រាវជ្រាវមេរៀនជាភារកិច្ចរបស់គ្រូម្នាក់ៗ ដើម្បីពង្រឹងសមត្ថភាពបង្រៀនរបស់ខ្លួនឲ្យឆ្លើយតបទៅនឹងគោលនយោបាយអប់រំទី១ ដែលក្រសួងអប់រំដាក់ចេញ។ ការផ្តល់ថវិកាដល់អ្នកចូលរួមធ្វើការសិក្សាស្រាវជ្រាវមេរៀន អាចមិនមែនជាឧបសគ្គឡើយ ព្រោះការងារនេះធ្វើឡើងក្នុងអង្គភាពខ្លួនឯង និងអាចធ្វើតាមក្រុមមុខវិជ្ជានៅពេលណាមួយ ឬម៉ោងទំនេរក៏បាន។ ដូចបានលើកឡើងនៅក្នុងជំពូកទី២ នៅប្រទេសឥណ្ឌូនេស៊ី

គ្រូត្រូវតែចូលរួមក្នុងការសិក្សាស្រាវជ្រាវមេរៀន ព្រោះវាជាច្បាប់តម្រូវឲ្យចូលរួម ដើម្បីធានាគុណភាពអប់រំរបស់ប្រទេស។ តែទោះជាយ៉ាងណាក៏ដោយ លទ្ធភាពនៃការចេញលិខិតបញ្ជាក់ ឬលិខិតសរសើរ គណៈគ្រប់គ្រងសាលាអាចធ្វើបាន សម្រាប់ជាគ្រឿងសម្គាល់ការចូលរួម និងការខិតខំប្រឹងប្រែងរបស់គ្រូ ឬអាចបញ្ជាក់ពីចំនួនក្រេឌីតរបស់គ្រូស្របតាមគន្លងអាជីពគ្រូបង្រៀន។

**៤.៤.៦ ការបំប៉នផ្សេងៗ**

ដើម្បីឲ្យដំណើរការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនបានល្អប្រសើរ គ្រូៗដែលជាភាគសំណាក់បានបញ្ចេញនូវទស្សនៈយល់ឃើញរបស់ខ្លួនថា គួររៀបចំឲ្យមានជាសិក្ខាសាលា ឬវគ្គបំប៉នផ្សេងៗដែលគាំទ្របន្ថែមដល់ពួកគាត់។ ក្រោយពីបានប្រមូលផ្តុំនូវទស្សនៈយល់ឃើញរបស់ភាគសំណាក់រួចមក អ្នកស្រាវជ្រាវបានរៀបចំចាត់ជា ៤ ក្រុមគំនិត ដូចមានបង្ហាញខាងក្រោមៈ

ទី១ ភាគសំណាកភាគច្រើនប្រាថ្នាចង់ឲ្យមានការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនជាបន្តទៀត និងអនុវត្តឲ្យបានទៀតទាត់ជារៀងរាល់ឆ្នាំ ដើម្បីពង្រឹង និងពង្រីកចំណេះដឹងមានស្រាប់ និងផ្សាភ្ជាប់ទំនាក់ទំនងទៅជាមួយគ្រូផ្សេងៗទៀត ដើម្បីជួយបង្កើនសមត្ថភាពក្នុងការបង្រៀន និងរៀន ដោយតម្រូវឲ្យមានការបំប៉នឲ្យបានគ្រប់មុខវិជ្ជាធំៗទាំងអស់។

ទស្សនៈយល់ឃើញខាងលើនេះពិតជាប្រពៃណាស់ ព្រោះវាជាការចាំបាច់ដែលត្រូវបង្កើនសមត្ថភាពរបស់គ្រូ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការបង្រៀន។ ម្យ៉ាងទៀត ការចូលរួមក្នុងក្រុមសិក្សាស្រាវជ្រាវមេរៀនអាចជួយឲ្យគ្រូរៀនសូត្របានច្រើនពីគ្រូដទៃទៀតក្នុងក្រុមរបស់ខ្លួន តាមរយៈការចែករំលែកបទពិសោធ និងល្បិចបង្រៀនផ្សេងៗ ដល់ក្រុម។ មួយវិញទៀត ទស្សនៈយល់ឃើញនេះពិតជាស្របតាមទ្រឹស្តីនៃការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន ដែលតម្រូវឲ្យគ្រូត្រូវចូលរួមក្នុងក្រុមមុខវិជ្ជារបស់ខ្លួន និងរៀនសូត្រពីគ្នាទៅវិញទៅមក ហើយដំណើរការនេះត្រូវប្រើពេលយូររហូតដល់ ២ឬ៣ ឆ្នាំទើបឃើញលទ្ធផល។ ដូច្នេះហើយ គ្រូម្នាក់ៗត្រូវមានការព្យាយាម អំណត់ ក្នុងការស្វែងរកនូវចំណេះដឹងថ្មី បទពិសោធល្អៗ ពីសមាជិកក្រុមឯទៀត ដើម្បីយកមកអភិវឌ្ឍវិជ្ជាជីវៈបង្រៀនរបស់ខ្លួនស្របតាមកាលៈទេសៈ និងការអភិវឌ្ឍនៃវិស័យអប់រំ ទាំងក្នុងបរិបទប្រទេស និងបរិបទសាកលលោក។

ទី២ ពួកគាត់មានទស្សនៈយល់ឃើញថា ការបំប៉នផ្នែកវិធីសាស្ត្របង្រៀនជាការចាំបាច់ណាស់ ព្រោះវាអាចធ្វើឲ្យការបង្រៀននិងរៀនមានប្រសិទ្ធភាពកើនឡើង។ អ្វី

ដែលគ្រូចង់បាននៅក្នុងផ្នែកនេះ គឺការបំប៉នបន្ថែមនូវវិធីសាស្ត្របង្រៀនតាមបែបរិះរក របៀបសរសេរកិច្ចតែងការបង្រៀន បំណិនដោះស្រាយបញ្ហា ឬការសម្របសម្រួល។ ជាការកត់សម្គាល់រួម ខ្លឹមសារទាំងនេះពិតជាសារៈសំខាន់ក្នុងការជួយជំរុញការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅក្នុងសាលា ព្រោះថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា កំពុងយកចិត្តទុកដាក់ និងជំរុញឲ្យគ្រូអនុវត្តវិធីបង្រៀនតាមបែបរិះរក និងវិធីបង្រៀនផ្សេងទៀតដែលធ្វើឲ្យសិស្សមានការគិតត្រិះ រិះពិចារណា និងចេះស្រាវជ្រាវ សំដៅឆ្លើយតបទៅនឹងគោលដៅអប់រំប្រកបដោយចីរភាព ឆ្នាំ2030 ទាំងអស់គ្នា។

ទី៣ គឺការផលិតសម្ភារៈឧបទេស។ ការលិតសម្ភារៈឧបទេសក្នុងការបង្រៀន នៅតែជាបញ្ហាមួយដែលគ្រូបង្រៀនអនុវត្តពុំទាន់បានទូលំទូលាយ និងអស់លទ្ធភាពនៅឡើយ។ សម្ភារៈឧបទេស គឺជាសមាសភាគមួយក្នុងចំណោមសមាសភាគទាំង ៤ ដែលជួយធានាដល់គុណភាពអប់រំ។ ម្យ៉ាងទៀត ការផលិតសម្ភារៈឧបទេសក៏ជាផ្នែកមួយនៃកិច្ចការបង្រៀនផងដែរ ដើម្បីជួយឲ្យសិស្សងាយយល់ និងងាយចាប់បានខ្លឹមសារមេរៀន។ នៅក្នុងការប្រជុំសិក្សាស្រាវជ្រាវមេរៀន ជាពិសេសក្នុងក្រុមមុខវិជ្ជា ការរៀបចំសម្ភារៈឧបទេសក្នុងការបង្រៀនជាការចាំបាច់ណាស់ ដើម្បីឲ្យបានដឹងពីប្រសិទ្ធភាពនៃការបង្រៀនមេរៀនមួយ តាមវិធីជាក់លាក់ណាមួយដែលក្រុមបានជ្រើសរើស។ ដូច្នេះទស្សនៈយល់ឃើញនេះជាសញ្ញាល្អប្រាប់ដល់នាយកសាលាឲ្យជួយពង្រឹងលើផ្នែកនេះតាមរយៈការបើកវគ្គបំប៉នជាដើម។

ទី៤ គឺវិធីវាយតម្លៃ ដែលភាគសំណាកចង់បាន។ ក្នុងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន ការវាយតម្លៃការបង្រៀនរបស់សមាជិកក្នុងក្រុមជាការងារដ៏មានសារៈប្រយោជន៍ ដើម្បីធ្វើការឆ្លុះបញ្ចាំង និងផ្តល់ព័ត៌មានត្រឡប់ទៅឲ្យអ្នកឡើងបង្រៀន។ ការវាយតម្លៃបានល្អអាចផ្តល់ព័ត៌មានត្រឡប់បានល្អ ត្រូវចំណុចសម្រាប់កែលម្អ និងអាចឲ្យសមាជិកក្រុមរៀនសូត្រនូវបទពិសោធ និងចំណេះដឹងថ្មីបាន។ ការលើកឡើងនូវចំណុចត្រង់នេះបញ្ជាក់ឲ្យឃើញថា គ្រូនៅមានបញ្ហាក្នុងការវាយតម្លៃការបង្រៀនរបស់សមាជិកក្រុមផងដែរ។ ដូចនេះ គណៈគ្រប់គ្រងសាលាគួរស្វែងរកដៃគូ ឬអ្នកជំនាញមកបំប៉នដល់គ្រូ ដើម្បីឲ្យពួកគាត់មានសមត្ថភាពពេញលេញក្នុងវិជ្ជាជីវៈគ្រូបង្រៀន និងក្នុងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន។

### ៤.៤.៧ សំណូមពរផ្សេងៗ

ផ្អែកលើទិន្នន័យ ដែលអ្នកស្រាវជ្រាវទទួលបានពីកម្រងសំណួរអាចបញ្ជាក់ឲ្យឃើញថា ភាគសំណាកដែលជាបុគ្គលិកអប់រំនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ

ស្ទឹងត្រែងចំនួន 12 នាក់ ឬស្មើនឹង 52.17% មិនមានសំណូមពរទាល់តែសោះ ទាក់ទងនឹងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន។ ជាការកត់សម្គាល់បុគ្គលិកទាំងនោះភាគច្រើនជាអ្នកដែលមានអតីតភាពការងារយូរនៅក្នុងសាលា និងមានបទពិសោធច្រើនក្នុងការងារបណ្តុះបណ្តាល ជាពិសេសផ្នែកវិធីសាស្រ្តបង្រៀន ព្រមទាំងបានឆ្លងកាត់វគ្គសិក្ខាសាលា និងវគ្គបំប៉នផ្សេងៗ ពីក្រសួងអប់រំ យុវជន និងកីឡា និងអង្គការដៃគូជាច្រើនមកហើយ។ ក្រៅពីនេះ អាចនិយាយបានថា ពួកគាត់ជាមន្រ្តីដែលតួនាទីក្នុងសាលាផង ហើយខ្លះជាអ្នកដឹកនាំបច្ចេកទេស និងជាអ្នកសម្របសម្រួលការងារក្នុងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនថែមទៀតផង។

ក្រៅពីចំនួនខាងលើ ភាគសំណាកចំនួន 11 នាក់ ឬស្មើនឹង 47.82% បានលើកជាសំណូមពរផ្សេងៗ ក្នុងគោលបំណងដើម្បីធ្វើឲ្យការអនុវត្តការសិក្សាស្រាជ្រាវមេរៀនបានល្អប្រសើរឡើងនៅឆ្នាំបន្តបន្ទាប់ទៀត។ ចំពោះសំណូមពរណាដែលមានខ្លឹមសារប្រហាក់ប្រហែលគ្នាត្រូវបានដាក់ជាមួយគ្នា ឯសំណូមពរណាដែលទាក់ទងគ្នាត្រូវបានដាក់បញ្ចូលជាមួយគ្នា ដូចមានបង្ហាញខាងក្រោមៈ

-សូមឲ្យមានអាហារសម្រន់ និងថវិកាសមរម្យ ដើម្បីជាការលើកទឹកចិត្តដល់គ្រូឧទ្ទេសទាំងអស់ដែលចូលរួម និងអ្នកឡើងបង្រៀន (ក្រៅពីគម្រោង CCT)។

-សូមឲ្យគណៈគ្រប់គ្រង យកចិត្តទុកដាក់លើការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនរវាងសាលាគរុកោសល្យ និងសាលាសហការឲ្យបានល្អ ដើម្បីងាយស្រួលដល់គរុសិស្សពេលចុះកម្មសិក្សាគរុកោសល្យ ដោយឲ្យគ្រូសាលាសហការបានចូលរួមទាំងអស់គ្នា។

-សូមឲ្យមានការបង្កើតក្រុមសិក្សាស្រាវជ្រាវមេរៀនតែមួយក្រុម ដើម្បីឲ្យគ្រូអាចចូលរួមបាន និងអនុវត្តបានគ្រប់មុខវិជ្ជាធំទាំងបួន (ខ្មែរ គណិត វិទ្យាសាស្រ្ត និងសិក្សាសង្គម)។

-សូមឲ្យមានវគ្គបំប៉នផ្សេងៗ ដែលជួយដល់ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន ពិសេសការអប់រំសតវត្សទី21។

-សូមឲ្យមានការចុះជួយពិនិត្យការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន តាមសាលាឲ្យបានញឹកញាប់។

សំណូមពរខាងលើ ពិតជាល្អប្រសើរសម្រាប់ជំរុញដំណើរការការសិក្សាស្រាវជ្រាវមេរៀនឲ្យមាននិរន្តភាព និងបង្កើនប្រសិទ្ធភាពនៃការអនុវត្ត ដូចជា រៀបចំឲ្យមានការលើកទឹកចិត្តជាថវិកា អាហារសម្រន់ ការសហការល្អជាមួយគ្រូសាលាសហការ

និងការរៀបចំឲ្យ មានវគ្គបំប៉នផ្សេងៗដែលជួយដល់ការសិក្សាស្រាវជ្រាវមេរៀន ដោយគណៈគ្រប់គ្រងសាលាត្រូវយកចិត្តទុកដាក់ពង្រឹងថែមទៀត។ តែក៏នៅមានសំណូមពរខ្លះដែលហួសពីព្រំដែននៃសមត្ថកិច្ចរបស់នាយកសាលាផងដែរ ដូចជា បញ្ហាថវិកាសម្រាប់ឧបត្ថម្ភអ្នកចូលរួម ការតម្រូវឲ្យគ្រូសាលាសហការមកចូលរួមជាមួយគ្រូសាលាគរុកោសល្យទៀងទាត់ និងការសុំឲ្យសាលាផ្សេងៗអនុវត្តការសិក្សាស្រាវជ្រាវមេរៀន ជាដើម។ ហេតុផលគឺថា គណៈគ្រប់គ្រងសាលាពុំមានលទ្ធភាពក្នុងការដោះស្រាយរកថវិកាឧបត្ថម្ភដល់អ្នកចូលរួមប្រជុំការសិក្សាស្រាវជ្រាវមេរៀនបានទេ ព្រោះជាគោលការណ៍ណែនាំ ការប្រជុំក្នុងអង្គភាពមានត្រឹមតែអាហារសម្រន់ប៉ុណ្ណោះ។ ឯការសុំឲ្យសាលាផ្សេងៗអនុវត្តការសិក្សាស្រាវជ្រាវមេរៀន និងមកចូលរួមជាមួយសាលាគរុកោ-សល្យគ្រប់ពេលនោះ ក៏មិនអាចដោះស្រាយបានដែរ ព្រោះសាលាទាំងនោះមិនស្ថិតក្នុងដែនគ្រប់គ្រងរបស់សាលាគរុកោសល្យទេ ហើយម្យ៉ាងវិញទៀតក៏ពុំមានលិខិតស្នាមណែនាំពីថ្នាក់លើដែរ។ ហើយវារឹតតែពិបាក់ ព្រោះសាលារៀនទាំងនោះក៏មានកិច្ចការត្រូវធ្វើក្នុងសាលារៀនរបស់គេដែរ។

តែទោះជាយ៉ាងនេះក្តី សំណូមពរខាងលើនេះពិតជាមានសារៈសំខាន់ខ្លាំងសម្រាប់អ្នកស្រាវជ្រាវនាពេលនេះ និងជាព័ត៌មានចាំបាច់ផងដែរសម្រាប់នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង ដើម្បីជាត្រីវិស័យបង្ហាញផ្លូវក្នុងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅក្នុងសាលានេះ ឲ្យកាន់តែប្រសើរឡើងនៅឆ្នាំសិក្សាបន្តបន្ទាប់ទៀត។

# ជំពូកទី ៥
# សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ជំពូកទី៥
# សន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

តាមរយៈលទ្ធផលនៃការស្រាវជ្រាវខាងលើ អ្នកស្រាវជ្រាវអាចធ្វើការសន្និដ្ឋានបានថា គ្រូឧទ្ទេសនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែងមានការយល់ដឹងច្រើនទៅលើខ្លឹមសារនៃការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន ដោយសារគ្រូទាំងនោះភាគច្រើនបំផុតបានឆ្លងកាត់ការបំប៉នពីក្រសួងអប់រំ យុវជន និងកីឡា ដៃគូសហការ និងជាពិសេសពីសាលាផ្ទាល់តែម្តង។ ចំពោះការរៀបចំផែនការមេរៀន (Plan) គ្រូមានការយល់ដឹងច្រើន ដូចជាការចាត់តាំងគ្រូត្រូវឡើងបង្រៀន (95.7%) ការរៀបចំកិច្ចតែងការបង្រៀន (95.7%) ការពិភាក្សាលើកិច្ចតែងការបង្រៀន (95.7%) និងការសរសេរកិច្ចតែងការសម្រេច (91.3%)។ រីឯការអនុវត្តការរៀបចំផែនការបង្រៀនវិញ គ្រូអនុវត្តបានល្អណាស់ ដោយកបានចាត់គ្រូឲ្យឡើងបង្រៀន បានចាត់គ្រូដែលត្រូវឡើងបង្រៀនឲ្យរៀបចំសរសេរកិច្ចតែងការបង្រៀន គ្រូៗបានចូលរួមពិភាក្សាលើកិច្ចតែងការបង្រៀនយ៉ាងហ្មត់ចត់ក្នុងក្រុមសិក្សាមេរៀនរបស់ខ្លួន និងបានសរសេរកិច្ចតែងការសម្រេចមួយក្រោយពេលពិភាក្សាចប់។ សកម្មភាពទាំងនេះឆ្លុះបញ្ចាំងឲ្យឃើញពីដំណើរវិវត្តន៍បន្តិចម្តងៗរបស់គ្រូលើការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន។

សម្រាប់ការអនុវត្តការបង្រៀន និងការសង្កេត (Do) គ្រូមានការយល់ដឹងច្រើនទៅលើខ្លឹមសារនេះ (95.7%) រីឯការអនុវត្តវិញ គ្រូបានបង្រៀនផ្ទាល់ជាមួយគរុសិស្សបន្ទាប់ពីបានបង្រៀនសាកល្បងក្នុងក្រុម និងបានកែលម្អកិច្ចតែងការរួច។ គ្រូពិតជាអនុវត្តបានល្អនៅក្នុងផ្នែកនេះ (91.3%) ដោយមានការចាត់គ្រូជាអ្នកសង្កេតលើការបង្រៀន និងការរៀនរបស់សិស្សយ៉ាងយកចិត្តទុកដាក់។ ដោយឡែកសម្រាប់ការពិភាក្សាលើការបង្រៀន និងរៀន (Check) ឃើញថា គ្រូមានការយល់ដឹងច្បាស់លាស់អំពីការពិភាក្សាបន្ទាប់ពីការបង្រៀនជាមួយសិស្សចប់ (95.7%)។ រីឯការអនុវត្ត គ្រូបានអនុវត្តការពិភាក្សាដោយចាត់ឲ្យមានអ្នកសម្របសម្រួល លេខាកត់ត្រា ដើម្បីរក្សាដំណើរពិភាក្សាឲ្យមានការរលូនល្អ។ ជាលទ្ធផល គ្រូអនុវត្តសកម្មភាពខាងលើបានល្អ (91.3%)។ ចំពោះការធ្វើសកម្មភាពកែលម្អបន្ត (Action) គ្រូមានការយល់ដឹងលើខ្លឹមសារនៃការកែលម្អការបង្រៀនរបស់ខ្លួន តាមរយៈអនុសាសន៍ដែលទទួលបានពីការពិភាក្សា (91.3%) និងចូល

រួមអនុវត្តបានល្អ (95.7%) ដោយគ្រូចាប់ផ្តើមមានការប្រែប្រួលលើការបង្រៀនរបស់ខ្លួនជាបណ្តើរៗ។

សរុបមក តាមរយៈការអនុវត្តការសិក្សាមេរៀន គ្រូមានការយល់ដឹងលើខ្លឹមសារនៃការសិក្សាមេរៀន និងបានចូលរួមអនុវត្តកម្មវិធីនេះនៅក្នុងវិជ្ជាជីវៈគ្រូបង្រៀនរបស់ខ្លួនបានក្នុងកម្រិតល្អ។ នេះជាលទ្ធផលមួយដែលឆ្លុះបញ្ចាំងឲ្យឃើញពីការខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការលើកកម្ពស់សមត្ថភាពគ្រូបង្រៀន ដូចបានលើកឡើងនៅក្នុងកំណែទម្រង់ទាំង ១៥ ចំណុច ស្រាប់។ កិច្ចដំណើរការនេះអាចប្រព្រឹត្តទៅបានអាស្រ័យដោយមានការចូលរួមគាំទ្រពីអ្នកពាក់ព័ន្ធនានា អង្គការដៃគូ (CCT) មន្ទីរអប់រំយុវជន និងកីឡាខេត្ត គណៈគ្រប់គ្រងសាលាដែលបានជួយជ្រោមជ្រែងទាំងសម្ភារៈ និងស្មារតី ដើម្បីជំរុញដំណើរការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀននៅក្នុងសាលារបស់ខ្លួន។ ជាងនេះទៅទៀត គឺមានការគាំទ្រនិងការចូលរួមពីសំណាក់គ្រូឧទ្ទេសក្នុងសាលាដែលជាអ្នកធ្វើឲ្យដំណើរការសិក្សាមេរៀនប្រព្រឹត្តទៅដោយរលូន និងធានាបន្តនិរន្តភាពរហូតទៅ។

ជាមួយនឹងលទ្ធផលសម្រេចបានមកនេះ ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង ក៏មានជួបប្រទះបញ្ហាប្រឈមផងដែរ។ បញ្ហាប្រឈមមួយចំនួនដែលកើតមានក្នុងការអនុវត្តការសិក្សាមេរៀននៅទីនោះ មានជាអាទិ៍៖ គ្រូឧទ្ទេសមួយចំនួនតូចចូលរួមពុំបានទៀងទាត់ក្នុងការសិក្សាស្រាវជ្រាវមេរៀន ជាហេតុនាំឲ្យខ្លួនគាត់មានការខ្វះខាត ក្នុងការបញ្ចេញមតិយោបល់កែលម្អសមាជិកក្រុមផ្សេងទៀត និងអាចធ្វើឲ្យគាត់អនុវត្តពុំសូវបានល្អក្នុងការបង្រៀន។ មួយទៀត គឺសាលានៅពុំទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការគាំទ្រផ្នែកសម្ភារៈ និងថវិកា ដើម្បីជាការលើកទឹកចិត្តដល់ក្រុមសិក្សាស្រាវជ្រាវមេរៀន។ ម្យ៉ាងទៀត នៅសាលាគរុកោសល្យមានមុខវិជ្ជាតូចៗច្រើន តែការអនុវត្តការសិក្សាមេរៀនធ្វើចំពោះតែមុខវិជ្ជាធំៗតែប៉ុណ្ណោះ ជាហេតុធ្វើឲ្យគ្រូដែលបង្រៀនមុខវិជ្ជាតូចៗមានការលំបាកក្នុងការចូលរួមមតិយោបល់ក្នុងក្រុមមុខវិជ្ជាខ្លួន។ ទាំងនេះជាបញ្ហាប្រឈមខ្លះៗដែលកើតមានក្នុងដំណើរការសិក្សាមេរៀននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង។

ចំពោះទស្សនៈយល់ឃើញជារួមវិញ គ្រូភាគច្រើនបំផុតមានសុទិដ្ឋិនិយមនឹងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅក្នុងសាលារបស់ពួកគាត់ ដោយមានទស្សនៈយល់ឃើញថា ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនក្នុងសាលារៀនជារឿងល្អបំផុត ព្រោះវាបានលើកកម្ពស់សមត្ថភាពគ្រូបង្រៀនបានល្អ បង្កើនទំនាក់ទំនងនិងសាមគ្គីភាពល្អ

ហើយគរុសិស្សទទួលបានចំណេះដឹងរឹងមាំ។ ក្រៅពីនេះ ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនពិតជាបានជួយអភិវឌ្ឍការបង្រៀនរបស់គ្រូ តាមរយៈចំណេះដឹងថ្មីៗ បទពិសោធល្អៗពីមិត្តរួមក្រុម និងវិធីសាស្ត្របង្រៀនប្លែកៗ ដោយរួមបញ្ចូលទាំងការផលិតសម្ភារៈឧបទេសសម្រាប់ដំណើរការបង្រៀនផង ។ ជាងនេះទៅទៀត ការសិក្សាមេរៀននឹងជួយអភិវឌ្ឍការបង្រៀន និងរៀននៅក្នុងសាលា ដោយគ្រូមានការផ្លាស់ប្តូរឥរិយាបទជាបណ្តើរៗក្នុងការបង្រៀន ពីការបង្រៀនបែបប្រពៃណីមកជាការបង្រៀនតាមបែបរិះរក និងបែបស្រាវជ្រាវ ហើយការរៀនរបស់គរុសិស្សទៀតសោកមានការទទួលខុសត្រូវម្ចាស់ការ មានការចូលរួម និងមានការសហការគ្នា។ កត្តាទាំងនេះនឹងជំរុញសាលាឲ្យក្លាយទៅជាសាលាដែលមានការបណ្តុះបណ្តាលគ្រូ ប្រកបដោយគុណភាពនាពេលខាងមុខ។ ជាមួយគ្នានេះដែរ ការសិក្សាមេរៀននឹងជាចំណែកមួយចូលរួមអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា តាមរយៈការជួយឲ្យគ្រូកាន់តែខិតខំប្រឹងប្រែងកែលម្អការបង្រៀនរបស់ខ្លួនឲ្យអភិវឌ្ឍឈានឡើង ដើម្បីបង្កើនធនធានមនុស្សមួយដែលមានចំណេះដឹងពេញលេញ រៀនតាមបែបសកម្ម រៀនដោយមានម្ចាស់ការ មានភាពក្លាហាន ដែលទាំងនេះនឹងជួយឲ្យគុណភាពអប់រំកម្ពុជាបានប្រសើរឡើងនាពេលអនាគត់។ ជាទស្សនៈយល់ឃើញមួយថា ដើម្បីឲ្យការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនបានល្អនាពេលខាងមុខ ក្រសួងអប់រំយុវជន និងកីឡា ដៃគូសហការ និងគណៈគ្រប់គ្រងសាលាគួរមានការលើកទឹកចិត្តជាថវិកា ឬសម្ភារៈបន្ថែមទៀត និងគួររៀបចំឲ្យមានវគ្គបំប៉នផ្សេងៗទាក់ទងនឹងវិធីសាស្ត្របង្រៀន។ គ្រូៗបានស្នើដល់សមាជិកក្រុមទាំងអស់ចូលរួមការសិក្សាមេរៀនឲ្យបានទៀងទាត់តាមផែនការ និងស្នើសុំឲ្យគណៈគ្រប់គ្រងចេញជាលិខិតបញ្ជាក់ការចូលរួមការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនក្នុងសាលា ព្រោះនេះជាវិធីលើកទឹកចិត្តមួយយ៉ាងល្អប្រសើរ។

## ៥.២ សំណូមពរ

នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវមានសំណូមពរពីរ គឺសំណូមពរសម្រាប់អនុវត្ត និងសំណូមពរសម្រាប់ស្រាវជ្រាវបន្ត។

### ៥.២.១ សំណូមពរសម្រាប់អនុវត្ត

ដើម្បីឲ្យការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែងមានភាពរលូនល្អ និងធានាចីរភាពយូរអង្វែង អ្នកស្រាវជ្រាវមានជាសំណូមពរមួយចំនួនដូចខាងក្រោមៈ

១.គ្រូឧទ្ទេសគ្រប់រូបគួរមានមនសិការវិជ្ជាជីវៈ ស្រលាញ់ការបង្រៀន និងចូលរួមក្នុងដំណើរការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនឲ្យបានទៀងទាត់ តាមផែនការសាលា និងដោយការយកចិត្តទុកដាក់ទាំងអស់គ្នា។

២.គ្រូឧទ្ទេសបង្គោលគួរពង្រឹងសមត្ថភាពផ្ទាល់ខ្លួនបន្ថែមទៀត តាមរយៈការស្រាវជ្រាវផ្សេងៗ និងការសិក្សាស្វែងយល់ពីសមាជិកក្នុងក្រុមដែលខ្លួនដឹកនាំ ដើម្បីជាការលើកកម្ពស់សមត្ថភាពផ្ទាល់ខ្លួនឲ្យមានការជឿទុកចិត្តពីសមាជិកក្នុងក្រុម។

៣.អ្នកសម្របសម្រួលតាមក្រុមមុខវិជ្ជានីមួយៗ គប្បីយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីជួយសម្រួលដល់ដំណើរការសិក្សាស្រាវជ្រាវរបស់ក្រុមដែលខ្លួនទទួលខុសត្រូវ។

៤.គណៈគ្រប់គ្រងសាលាគម្បីពង្រឹងបន្ថែមទៀតលើកិច្ចសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងក្រសួងអប់រំ យុវជននិងកីឡា ព្រមទាំងដៃគូសហការផ្សេងៗទៀត ដើម្បីចូលរួមជួយគាំទ្រដល់ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន។

៥.ក្រសួងអប់រំ យុវជន និងកីឡាគួរបង្កើតឲ្យមានក្រុមសិក្សាស្រាវជ្រាវមេរៀនប្រចាំនៅថ្នាក់ក្រសួង ហើយសាលាគរុកោសល្យទាំងអស់ក៏គួររៀបចំឲ្យមានក្រុមសិក្សាស្រាវជ្រាវមេរៀនផងដែរ ដើម្បីទំនាក់ទំនង គាំទ្រ និងចែករំលែកព័ត៌មានទៅឲ្យក្រុមតាមសាលាគរុកោសល្យ។

៦.ក្រសួងអប់រំ យុវជន និងកីឡាគួរបង្កើតជាវិបសាយមួយដែលផ្តល់ការគាំទ្របន្ថែមផ្នែកបច្ចេកទេស ដល់បណ្តាក្រុមសិក្សាស្រាវជ្រាវមេរៀននៅតាមបណ្តាសាលាគរុកោសល្យ។

៧.សាលាគរុកោសល្យក្តី ក្រសួងអប់រំ យុវជន និងកីឡាក្តី គួរភ្ជាប់ខ្លួនទៅនឹងក្រុមសិក្សាស្រាវជ្រាវមេរៀនជាមួយបណ្តាប្រទេសផ្សេងៗទៀត ដែលមានការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន ទាំងនៅក្នុងតំបន់ និងនៅលើសាកលលោក ដើម្បីទទួលបាននូវចំណេះដឹង និងបទពិសោធថ្មីៗបន្ថែមទៀត សម្រាប់យកមកអភិវឌ្ឍការសិក្សាស្រាវជ្រាវមេរៀនរបស់ខ្លួន។

៨.ក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត គួរគប្បីចុះជួយ ឬនិងចុះពិនិត្យតាមដានការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅតាមសាលាគរុកោសល្យឲ្យបានយ៉ាងតិចពីរដងក្នុងមួយឆ្នាំ។

### ៥.២.២ សំណូមពរសម្រាប់ស្រាវជ្រាវបន្ត

ដោយការស្រាវជ្រាវនាពេលនេះ គ្រាន់តែជាជ្រុងមួយនៃការសិក្សាស្រាវជ្រាវនៅខេត្តស្ទឹងត្រែងតែប៉ុណ្ណោះ ដូចនេះអ្នកស្រាវជ្រាវសូមណែនាំបន្តដល់អ្នកស្រាវជ្រាវ

ក្រោយៗ គួរពិចារណាស្រាវជ្រាវលើប្រធានបទដែលទាក់ទងនឹងចំណុចមួយចំនួន ដូចខាងក្រោម៖

១. ប្រសិទ្ធភាពនៃការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនក្នុងការបង្រៀន និងរៀន

២. ភាពចាំបាច់នៃការសិក្សាស្រាវជ្រាវមេរៀនក្នុងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ

៣. ប្រសិទ្ធភាពនៃការគ្រប់គ្រងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន

៤. បញ្ហាប្រឈម និងដំណោះស្រាយនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន

៥. គុណភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀន

# ឯកសារយោង

ក្រសួង អយក. (១៩៩៦). **ការណែនាំគរុកោសល្យសម្រាប់គ្រូឧទ្ទេសផ្នែកបឋមសិក្សា ជំនាន់ទី២ និងទី៣**. ភ្នំពេញ. មហាវិទ្យាល័យគរុកោសល្យ។

ក្រសួង អយក. (២០០៨). **កម្រងការងារអធិការកិច្ចសម្រាប់បឋមសិក្សា**. ភ្នំពេញ។

ក្រសួង អយក. (២០១១). **វិធីបង្រៀនបំណិនអានសម្រាប់គរុសិស្សសាលាគរុកោសល្យ និងវិក្រឹតការរាជធានី-ខេត្ត**. ភ្នំពេញ. នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ។

ក្រសួង អយក. (២០១១). **សៀវភៅណែនាំស្តីពីការបង្រៀន និងរៀនតាមបែបរិះរក**. ភ្នំពេញ. នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ។

ក្រសួង អយក. (២០១១). **សៀវភៅណែនាំស្តីពីការសិក្សាស្រាវជ្រាវមេរៀន**. ភ្នំពេញ. នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ។

ក្រសួង អយក. (២០១២). **ការអប់រំបញ្ចូលគ្នា**. ភ្នំពេញ។

លី ហាក់សេង. (២០១២). **តើគ្រូត្រូវធ្វើយ៉ាងណាដើម្បីឲ្យសិស្សមានចំណាប់ក្នុងការសិក្សា?**. ទស្សនាវដ្តីគ្រូបង្រៀន លេខ៤០ ទំព័រ ២៥-២៧. ភ្នំពេញ។

ក្រសួង អយក. (២០១៣). **ប្រព័ន្ធធានាគុណភាពការងារបណ្តុះបណ្តាលគ្រូ**. ភ្នំពេញ. នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ។

ក្រសួង អយក. (២០១៥). **បញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សានិងអប់រំចំណេះទូទៅនៅកម្ពុជា**. ភ្នំពេញ។

ក្រសួង អយក. (២០១៥). **គោលនយោបាយស្តីពីគ្រូបង្រៀន: ផែនការសកម្មភាព**. ភ្នំពេញ។

ក្រសួង អយក. (២០១៦). **ផែនការសកម្មភាពស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ**. ភ្នំពេញ

របាយការណ៍បូកសរុបការងារបណ្តុះបណ្តាលចុងឆ្នាំ. (២០១៧-២០១៨). មជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង។

របាយការណ៍បូកសរុបការងារបណ្តុះបណ្តាលចុងឆ្នាំ. (២០១៨-២០១៩). មជ្ឈមណ្ឌលគរុសល្យភូមិភាគស្ទឹងត្រែង។

រាជរដ្ឋាភិបាល. (២០១៩). **គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត**. ភ្នំពេញ, កម្ពុជា។

Aina; J.K & Olanipekun; S.S. (2015). A Review of Teachers׳ Qualifications and ItsImplication on Students׳ Academic Achievement in Nigerian Schools.

International Journal of Educational Research and Information Science 2015; 2(2): 10-15.

Angeline M. Barrett & Leon Tikly. (2012). Quality in Education from an International perspective: Paper on General Education Quality, Access and Equity. Addis Ababa. Ethopy.

S.G.N Eze. 2017). **Features of Quality Education.** Faculty of Education, ESUT, Enugu. Nigeria.

UNICEF. (2000). **Defining Quality in Education.** Working Paper. United Nations Children׳s Fund. New York. USA.

Frances Haithcock. (2010). **A Guide for Implementing Lesson Study for District and School Leadership Teams in Differentiated Accountability Schools.** Florida. USA.

Cerbin and Kopp. (2011). **Lesson study guide.** Lesson Study Research Group, Columbia University,USA.

Pete Dudley. (2011). **Lesson Study: a handbook.** Lesson Study UK, Retrieved: 16/8/2019 at www.lessonstudy.co.uk.

Maths Development Team. (2017). **A Handbook for Lesson Study: Including a research Lesson Proposal Template.** Lesson Study IRELAND. www.lessonstudy.ie

Karmelita Pjanić. (2014). **The Origins and Products of Japanese Lesson Study.** Teaching Innovations Paper, Volume 27, Issue 3, pp. 84. University of Bihać, Bihać, Bosnia and Herzegovina.

Teacher Development Trust. (2015). **What is Lesson Study?** Retrieved: 16/8/2019 at https://tdtrust.org/what-is-lesson-study.

Peter Dudley. (2019). **What is Lesson Study?** Retrieved: 16/8/2019 at https://lessonstudy.co.uk/what-is-lesson-study/.

The Lesson Study Group. (2018). **What is Lesson Study?** Mills College. Retrieved: 16/8/2019 at https://lessonresearch.net/.

The Lesson Study Group. (2018). **Why is Lesson Study?.** Mills College. Retrieved: 16/8/2019 at https://lessonresearch.net/about-lesson-study/why-lesson-study/.

Naomichi MAKINAE. (2010). **The Origin of Lesson Study in Japan.** Graduate School of Comprehensive Human Science, University of Tsukuba, Tokyo.

Foghlam Alba. (2015). **Lesson Study.** Education Scotland, University of Glasgow.

Brian Doig and Susie Gloves. (2011). **Japanese Lesson Study: Teacher Professional Development through Communities of Inquiry.** Volume 13.1, p 77-93. Deakin University.

Tad Watanabe. (2018). **Japanese Lesson Study in the United States.** Looking back and Looking ahead. Educational Designer, 3(11). Kennesaw State University, USA.

Irene Ong. (2011). **Lesson Study in Action.** North Vista Primary School. Singarpore. Available at: singteach.nie.edu.sg.

N.I.E Singapore. (2007). **Recent Developments in Lesson Study in Singapore**, Country Report. Singapore.

Keiko Mizuno. (2017**). Lesson Study in Indonesia: Enhancing Quality of Learning.** Japan International Cooperation Agency, Indonesia.

Maitree Inprasitha. (2010). **Adapting Lesson Study in APEC Member Economies.** Khon Kaen University. Thailand. Paper on Replicating Exemplary Practices in Mathematics Education.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ ១៨៥៤ អយក.វិ.ស

ថ្ងៃព្រហស្បតិ៍ ៦ កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩

**ជម្រាបមក**
**លោកនាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**
**លោកនាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត**

**កម្មវត្ថុ ៖** ការចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦។

**យោង ៖** កម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ឆ្នាំសិក្សា២០១៨-២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកនាយក និងលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ចំនួន៨១នាក់ ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្ត ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩។

អាស្រ័យហេតុនេះ សូមលោកនាយក និងលោកប្រធានជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមលោកនាយក និងលោកប្រធានទទួលនូវការរាប់អានពីខ្ញុំ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- សាលារាជធានី-ខេត្តពាក់ព័ន្ធ
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
  "ដើម្បីជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# ឧបសម្ព័ន្ធទី ២៖ លិខិតឧទ្ទេសនាមចុះប្រមូលទិន្នន័យ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ:** ១១៩ **វជអ.ភក**

## លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩

និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ នៅវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនិងបាត់ដំបង សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្តនានា ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩៖

| ល.រ | គោត្តនាម និងនាម | ភេទ | សាលាគរុកោសល្យ និង រាជធានី-ខេត្ត |
|---|---|---|---|
| ១ | កុយ វ៉ាឡង់ទីណា | ប | ខេត្តកំពង់ធំ |
| ២ | គុជ សំអែល | ប | ខេត្តស្វាយរៀង |
| ៣ | ឃិន សម្បត្តិ | ប | ខេត្តតាកែវ |
| ៤ | ឯន ណាវី | ប | រាជធានីភ្នំពេញ |
| ៥ | ង៉ែត វ៉ារុធ | ប | ខេត្តតាកែវ |
| ៦ | ងួន ផល្លី | ស | ខេត្តបាត់ដំបង |
| ៧ | ឆន ឈាង | ប | សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម |
| ៨ | ឆាយ បូនី | ស | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង |
| ៩ | ជា គត | ប | ខេត្តតាកែវ |
| ១០ | ជា វណ្ណារ៉ា | ប | ខេត្តកំពង់ឆ្នាំង |
| ១១ | ញ៉ែត សំអុល | ប | ខេត្តតាកែវ |
| ១២ | ទឹម ពិន្ទុ | ប | រាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ពោធិ៍សាត់ កំពង់ស្ពឺ កំពង់ធំ ស្ទឹងត្រែង ឧត្តរមានជ័យ និងខេត្តមណ្ឌលគិរី |
| ១៣ | ទុយ សុវណ្ណារិទ្ធ | ប | រាជធានីភ្នំពេញ ខេត្តកំពង់ចាម បាត់ដំបង និងខេត្តសៀមរាប |
| ១៤ | ជាម ហេង | ប | ខេត្តក្រចេះ |
| ១៥ | ប៊ុម សូគ៉ា | ប | ខេត្តកណ្តាល |
| ១៦ | ផុន វណ្ណៈ | ប | ខេត្តកណ្តាល |
| ១៧ | ផូ សុវណ្ណ | ប | រាជធានីភ្នំពេញ |

1

| | | | |
|---|---|---|---|
| ១៨ | ពុត ពិសី | ប | ខេត្តកំពត |
| ១៩ | ពេជ្រ វង្សី | ស | ខេត្តត្បូងឃ្មុំ |
| ២០ | ភោគ តុលា | ប | ខេត្តស្វាយរៀង |
| ២១ | លី កុសល | ប | ខេត្តកំពង់ចាម |
| ២២ | លឹម សេងហួត | ប | ខេត្តបាត់ដំបង |
| ២៣ | លុន ហ៊ាប | ប | ខេត្តកំពង់ចាម |
| ២៤ | លុយ គឹមសាន | ប | ខេត្តកណ្ដាល |
| ២៥ | វ៉ា សុភក្តិ | ប | ខេត្តព្រៃវែង |
| ២៦ | សន តារាស្មី | ប | ខេត្តកណ្ដាល |
| ២៧ | ស៊ើយ វង្សស៊ី | ប | ខេត្តស្ទឹងត្រែង |
| ២៨ | សាម សុនិត | ប | ខេត្តកំពង់ចាម |
| ២៩ | សុទ្ធ ស្រីនាង | ស | ខេត្តកំពង់ស្ពឺ |
| ៣០ | សៀង គឹមឈៀន | ប | ខេត្តកណ្ដាល |
| ៣១ | ស្រ៊ី មៅ | ប | រាជធានីភ្នំពេញ |
| ៣២ | ហៃល ម៉ូណូ | ប | រាជធានីភ្នំពេញ |
| ៣៣ | ហៃយ ចម្លង | ស | រាជធានីភ្នំពេញ |
| ៣៤ | ឡាយ វីរៈ | ប | ខេត្តឧត្តរមានជ័យ |
| ៣៥ | ឡុង ចំណាន | ប | ខេត្តកំពង់ចាម |
| ៣៦ | អ៊ុន ចាន់ថា | ប | ខេត្តស្វាយរៀង |
| ៣៧ | អ៊ីវ សុធិ | ប | រាជធានីភ្នំពេញ |
| ៣៨ | អ៊ឹម សិរីវឌ្ឍ | ប | ខេត្តតាកែវ |
| ៣៩ | អ៊ុក រិទ្ធី | ប | ខេត្តសៀមរាប |
| ៤០ | អុន សេងទ្រី | ប | ខេត្តកំពង់ធំ |
| ៤១ | អៀង គឹមឈាន | ប | ខេត្តកំពង់ចាម |

ថ្ងៃសុក្រ ១៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័កព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៩

**នាយកវិទ្យាស្ថានជាតិអប់រំ**

**កន្លែងទទួល៖**

-សាលារាជធានី-ខេត្តពាក់ព័ន្ធ

-អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក

-មន្ទីរ អ.យ.ក រាជធានី-ខេត្តពាក់ព័ន្ធ

"ដើម្បីសហការ"

-សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

**បណ្ឌិត.សៀង សុខន្ធា**

## ឧបសម្ព័ន្ធទី ៣៖ កម្រងសំណួរ

| |
|---|
| **ប្រធានបទ៖ ការយល់ដឹងពីការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅខេត្តស្ទឹងត្រែង៖ ករណីសិក្សាមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង**<br>An Understanding of Lesson Study Implementation in Stung Treng៖ Case Study of Stung Treng Regional Teacher Training Center |

### កម្រងសំណួរសម្រាប់សួរគ្រូឧទ្ទេស

ខ្ញុំបាទឈ្មោះ **ស៊ើយ វង្សស៊ី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ កំពុងធ្វើនិក្ខេបបទក្រោមប្រធានបទ "**ការយល់ដឹងពីការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅខេត្តស្ទឹងត្រែង៖ករណីសិក្សាមជ្ឈមណ្ឌលគរុកោសល្យភូមិភាគស្ទឹងត្រែង**" ដើម្បីបញ្ចប់ការសិក្សា។

អាស្រ័យហេតុនេះ សូមលោកគ្រូអ្នកគ្រូផ្តល់ចម្លើយនូវសំណួរខាងក្រោមដោយក្តីអនុគ្រោះ។ គ្រប់ចម្លើយទាំងអស់លោកគ្រូអ្នកគ្រូនឹងត្រូវបានរក្សាជាការសម្ងាត់។ ការចូលរួមរបស់លោកគ្រូអ្នកគ្រូពិតជាមានសារៈសំខាន់ក្រៃលែង ក្នុងការពង្រឹងគុណភាពបណ្តុះបណ្តាលនៅក្នុងអង្គភាព ក៏ដូចជាក្នុងប្រទេសកម្ពុជាយើង។ កម្រងសំណួរនេះបែងចែកជា ៥ផ្នែក គឺ ការយល់ដឹងពីការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន បញ្ហាប្រឈម និងទស្សនៈយល់ឃើញជារួម។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកគ្រូអ្នកគ្រូទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃជាមួយខ្ញុំក្នុងការសិក្សាស្រាវជ្រាវនេះ។

**ឈ្មោះ និង ហត្ថលេខា**

**ស៊ើយ វង្សស៊ី**

## I. ការយល់ដឹងពីការសិក្សាស្រាវជ្រាវមេរៀន

១. តើអ្នកធ្លាប់ចូលរួមវគ្គបំប៉នស្ដីពីការសិក្សាស្រាវជ្រាវមេរៀនដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ដៃគូសហការ ឬ ដោយសាលារៀនរបស់អ្នក ដែរឬទេ?

ធ្លាប់ ☐ មិនធ្លាប់ ☐

២.តើអ្វីជាការសិក្សាស្រាវជ្រាវមេរៀន?

..............................................................................................................................

..............................................................................................................................

៣.តើអ្វីជាគោលបំណងនៃការសិក្សាស្រាវជ្រាវមេរៀន?

..............................................................................................................................

..............................................................................................................................

៤.តើលោកអ្នកបានយល់ដឹងច្បាស់លើខ្លឹមសារនៃការសិក្សាស្រាវជ្រាវមេរៀនកម្រិតណា? (សូមគូសរង្វង់ជុំវិញលេខដែលអ្នកគិតថាសមស្របសម្រាប់អ្នកពីទាបទៅខ្ពស់តាមលេខពី ១ ដល់ ១០)

១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០

ផ្សេងៗ.......................................................................................................................

៥.សូមគូសសញ្ញា ✔ ក្នុងប្រអប់ខាងក្រោមដែលអ្នកគិតថា អ្នកបានយល់ច្បាស់លាស់ និងគូស X ដែលអ្នកមិនសូវយល់ច្បាស់លាស់ ដោយបញ្ជាក់ពីមូលហេតុផង។

| ខ្លឹមសារ និងសកម្មភាព | បញ្ជាក់មូលហេតុ |
|---|---|
| ☐ ក. ការរៀបចំបង្កើតក្រុម LS | |
| ☐ ខ. ការចាត់តាំងគ្រូឡើងបង្រៀន | |
| ☐ គ. ការរៀបចំកិច្ចតែងការបង្រៀន | |
| ☐ ឃ. ការពិភាក្សាលើកិច្ចតែងការបង្រៀន | |
| ☐ ង. ការសរសេរកិច្ចតែងការសម្រេច | |
| ☐ ច. ការបង្រៀននិងការសង្កេត | |
| ☐ ឆ. ការពិនិត្យមេរៀនឡើងវិញក្រោយបង្រៀន | |
| ☐ ជ. ការកែលម្អមេរៀនរបស់គ្រូឧទ្ទេសណាម្នាក់ដោយផ្អែកលើការសម្រេចនៃមេរៀនមុន (កែលម្អបន្ត) | |

## II. ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន

១.តើមានកម្មវិធីសិក្សាស្រាវជ្រាវមេរៀនដែរឬទេនៅសាលារបស់អ្នក?

មាន ☐ មិនមាន ☐

២.តើអ្នកបានចូលរួមញឹកញាប់កម្រិតណា?

(១ មិនបានចូលរួម ២ តិចតួច ៣ ជាមធ្យម ៤ ញឹកញាប់ ៥ តែងចូលរួម)

១ ២ ៣ ៤ ៥

៣.តើគ្រប់ពេលប្រជុំសិក្សាមេរៀនមានវត្តមានសមាជិកចូលរួមកម្រិតណា?

(សូមគូសរង្វង់ជុំវិញលេខខាងមុខពាក្យ ដែលត្រូវនឹងការគិតរបស់អ្នក)

១ តិចតួច ២ ជាមធ្យម ៣ ច្រើន ៤ ច្រើនគួរសម ៥ ច្រើនណាស់

ផ្សេងៗ

......................................................................................................................

......................................................................................................................

៤.សូមគូសបញ្ជាក់រង្វង់ជុំវិញលេខនៃកម្រិតឯកភាពណាមួយ នៅក្នុងតារាងខាងក្រោម ដើម្បីបញ្ជាក់នូវ ការយល់ស្របរបស់អ្នកទៅនឹងព័ត៌មានដូចបានផ្តល់ជូន។

*កំណត់ចំណាំ៖* ១.មិនឯកភាព ២.ឯកភាពតិចតួច ៣.ឯកភាពពាក់កណ្តាល

៤.ឯកភាពច្រើន ៥.ឯកភាពទាំងស្រុង

| ព័ត៌មានដែលបានផ្តល់ជូនលើការអនុវត្ត LS | កម្រិតឯកភាព | | | | |
|---|---|---|---|---|---|
| ១.ការរៀបចំបង្កើតក្រុមតាមមុខវិជ្ជាបានល្អ តាមការណែនាំរបស់ក្រសួង អយក | ១ | ២ | ៣ | ៤ | ៥ |
| ២.មានផែនការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន (LS) ច្បាស់លាស់ | ១ | ២ | ៣ | ៤ | ៥ |
| ៣.គ្រូឧទ្ទេសបង្គោលមានសមត្ថភាព និងចេះបត់បែនតាមកាលៈទេសៈ | ១ | ២ | ៣ | ៤ | ៥ |
| ៤.អ្នកសម្របសម្រួលតាមក្រុមបានយកចិត្តទុកដាក់ជួយសម្រួលដល់ក្រុម LS | ១ | ២ | ៣ | ៤ | ៥ |
| ៥.គណៈគ្រប់គ្រងបានគាំទ្រទាំងសម្ភារៈ និងស្មារតីដល់ការអនុវត្ត LS | ១ | ២ | ៣ | ៤ | ៥ |

៥.សូមគូសសញ្ញា ✓ ក្នុងប្រអប់ខាងក្រោមដែលអ្នកគិតថា អនុវត្តបានល្អ និងគូស X មិនសូវបានល្អ ក្នុងការរៀបចំផែនការមេរៀន ដោយបញ្ជាក់ពីមូលហេតុផង។

| ខ្លឹមសារ និងសកម្មភាព | បញ្ជាក់មូលហេតុ |
|---|---|
| ☐ ក.សកម្មភាពរៀបចំក្រុម LS | |
| ☐ ខ.ការចាត់តាំងគ្រូឡើងបង្រៀន | |
| ☐ គ.ការរៀបចំកិច្ចតែងការបង្រៀន | |
| ☐ ឃ.ការពិភាក្សាលើកិច្ចតែងការ | |
| ☐ ង.ការសរសេរកិច្ចតែងការសម្រេច | |

៦.សូមគូសសញ្ញា ✓ ក្នុងប្រអប់ខាងក្រោមដែលអ្នកគិតថា អនុវត្តខ្លឹមសារនោះបានល្អ និងគូស X អនុវត្តមិនសូវបានល្អ នៅក្នុងក្រុមមុខវិជ្ជារបស់អ្នក។

| ខ្លឹមសារ និងសកម្មភាព | សូមបញ្ជាក់ពីមូលហេតុ |
|---|---|
| ☐ ក. ការរៀបចំផែនការ LS | |
| ☐ ខ. ការរៀបចំកិច្ចតែងការបង្រៀន | |
| ☐ គ. ការផលិតសម្ភារៈបង្រៀន | |
| ☐ ឃ. ការបង្រៀនសាកល្បងក្នុងក្រុម | |
| ☐ ង. ការពិនិត្យការបង្រៀន និងរៀន | |
| ☐ ច. ការបង្រៀន និងការសង្កេត | |
| ☐ ឆ. វិធីនៃការកែលម្អការបង្រៀន (ការកែលម្អបន្ត) | |

## III. បញ្ហាប្រឈម និងដំណោះស្រាយ

តាមចំណុចខាងក្រោម ចូរលើកឡើងពីបញ្ហាប្រឈម និងដំណោះស្រាយ ដែលបានជួបប្រទះ។

១.ការអនុវត្តផែនការនៃការសិក្សាស្រាវជ្រាវមេរៀន?

បញ្ហាប្រឈម:

.......................................................................................................................

.......................................................................................................................

ដំណោះស្រាយ:.......................................................................................................

.......................................................................................................................

២.ការចូលរួមរបស់គ្រូនៅក្នុងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន?
បញ្ហាប្រឈម:

..........................................................................................................................................

..........................................................................................................................................

ដំណោះស្រាយ:

..........................................................................................................................................

..........................................................................................................................................

៣.ការផលិតសម្ភារ:ឧបទេស និងសម្ភារ:បង្រៀន សម្រាប់អនុវត្តការសិក្សាស្រាវជ្រាវមេរៀន?
បញ្ហាប្រឈម:

..........................................................................................................................................

..........................................................................................................................................

ដំណោះស្រាយ:

..........................................................................................................................................

..........................................................................................................................................

៤.ការគាំទ្ររបស់សាលាអ្នក នៅក្នុងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន?
បញ្ហាប្រឈម:

..........................................................................................................................................

..........................................................................................................................................

ដំណោះស្រាយ:

..........................................................................................................................................

..........................................................................................................................................

៥.បញ្ហាប្រឈមរបស់អ្នក ក្នុងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន?
បញ្ហាប្រឈម:

..........................................................................................................................................

..........................................................................................................................................

ដំណោះស្រាយ:.................................................................................................................

..........................................................................................................................................

៦.បញ្ហាប្រឈមក្នុងក្រុមមុខវិជ្ជារបស់អ្នក ក្នុងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន?
បញ្ហាប្រឈម:

..........................................................................................................................................

..........................................................................................................................................

ដំណោះស្រាយ:

..........................................................................................................................................

..........................................................................................................................................

៧.តើមានបញ្ហាប្រឈមអ្វីខ្លះដល់សាលារបស់អ្នក ក្នុងការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន?
បញ្ហាប្រឈម:

..........................................................................................................................................

..........................................................................................................................................

ដំណោះស្រាយ:

..........................................................................................................................................

..........................................................................................................................................

## IV. ទស្សនៈយល់ឃើញជារួម

១.តើអ្នកយល់ឃើញយ៉ាងដូចម្ដេចដែរ ចំពោះការអនុវត្តការសិក្សាស្រាវជ្រាវមេរៀននៅក្នុងសាលារបស់អ្នក?..........................................................................................

..........................................................................................................................................

..........................................................................................................................................

២.តើអ្នកគិតថា ការអនុវត្តការសិក្សាស្រាវជ្រាវបានជួយអភិវឌ្ឍវិជ្ជាជីវៈការបង្រៀនរបស់អ្នកកម្រិតណា?..........................................................................................

..........................................................................................................................................

ព្រោះអ្វី?..........................................................................................................................

..........................................................................................................................................

..........................................................................................................................................

៣.អ្នកគិតថាការអនុវត្ត LS នេះពិតជាបានជួយដល់ការអភិវឌ្ឍនៃការបង្រៀន និងរៀននៅក្នុងសាលារៀន របស់អ្នកយ៉ាងដូចម្ដចខ្លះ?

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

៤.តើអ្នកគិតថាការអនុវត្ត LS នេះ បានជួយដល់ការអភិវឌ្ឍវិស័យអប់រំ នៅកម្ពុជាយ៉ាងដូចម្តេច?

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

៥.តើអ្នកគិតថាយើងគួរកែលម្អយ៉ាងដូចម្តេច ដើម្បីធ្វើឲ្យការអនុវត្ត LS បានល្អប្រសើរជាងពេលនេះ?

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

៦.តើអ្នកចង់ឲ្យមានការបំប៉នអំពីអ្វីទៀត សម្រាប់ពេលក្រោយ ?

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

៧.សំណូមពរផ្សេងៗ

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

## ឧបសម្ព័ន្ធទី ៤៖

### ១-គណៈកម្មការមេប្រយោគ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ៩៧២៩ **អយក.** ១៩

(**ភារសម្ងាត់**)

**លិខិតឧទ្ទេសនាម**

**យោង** ៖ -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** | ខុទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ម៊ុនរឿន** | ខុទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម **យក់ ខ៉ុយ** | ខុទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម **លាង សេងហាក់** | ខុទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តម **ម៉ក់ ខយ** | អគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកដឹកនាំវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិត នៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១១រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ

"ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ - ឯកសារៈវិទ្យាស្ថានជាតិអប់រំ

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

## ២-គណៈកម្មការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** ៩៦២៩ **អយក.** ប្រក
(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យួន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈូក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារៈវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# ៣-គណៈកម្មការកណ្តាល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** ៩៧៣១ **អយក.** ខល
(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម

**យោង** ៖-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការកណ្តាល** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-លោកស្រី ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-លោក ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-លោក ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤-លោក លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោក សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវមកបំពេញភារកិច្ចនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩ និងថ្ងៃបន្តបន្ទាប់ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១១រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh